សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ

កម្មសិក្សា ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ឈ្មោះស្ថាប័ន៖ **ក្រសួងសាធារណការ និងដឹកជញ្ជូន**

រៀបរៀងដោយ
និស្សិតឈ្មោះ ៖ **ល. ម៉ោ ចន្ទសុវណ្ណរិទ្ធ**
**ក. តាន់ សម្បត្តិសុភ័ក្រ្តា**

សាស្ត្រាចារ្យណែនាំ៖
បណ្ឌិត **ឈុន ណារ៉េត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១៣ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេររបាយការណ៍ ២០២០

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics


## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ

កម្មសិក្សា ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ឈ្មោះស្ថាប័ន៖ **ក្រសួងសាធារណការ និងដឹកជញ្ជូន**


រៀបរៀងដោយ
និស្សិតឈ្មោះ ៖ **ល. ម៉ៅ ចន្ទសុវណ្ណរិទ្ធ**
**ក. តាន់ សម្បត្តិសុភ័ក្រ្តា**

សាស្ត្រាចារ្យណែនាំ៖
បណ្ឌិត **ឈុន ណារ៉េត**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១៣ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេររបាយការណ៍ ២០២០

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីរនាក់ ជានិស្សិតកម្មសិក្សានៅនាយកដ្ឋានរដ្ឋបាលកំពង់ផែ នៃ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ។ ក្នុងរយៈពេល ០១ខែ កន្លះ នៃការបំពេញកម្មសិក្សា យើងខ្ញុំបានឆ្លងកាត់នូវការខិតខំប្រឹងប្រែងបំផុត ដើម្បីសម្រេចបាននូវរបាយការណ៍កម្មសិក្សាប្រកបដោយផ្លែផ្កាមួយនេះ។ តាមលទ្ធផលជាវិជ្ជមាននេះ យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

១. យើងខ្ញុំទាំងពីររូប សូមលំឱនកាយ វាចា ចិត្ត និងសម្តែងនូវការដឹងគុណាប្រកបដោយមហាកតញ្ញូតាធម៌ជូនចំពោះអ្នកមានគុណទាំងទ្វេ រួមមាន៖ លោកឪពុក **ម៉ៅ ដា** និងអ្នកម្តាយ **ចាន់ ធី** ព្រមទាំងលោកឪពុក **តាន់ ចរិយា** និងអ្នកម្តាយ **ហ៊ី តារាណេខ** ដែលលោកបានខិតខំចិញ្ចឹមបីបាច់ថែរក្សា អប់រំ និងផ្តត់ផ្គង់ទាំងកម្លាំងកាយនិងចិត្ត ទាំងនៅក្នុងការរស់នៅ និងក្នុងការសិក្សារហូតដល់យើងខ្ញុំទទួលបាននូវលទ្ធផលដូចថ្ងៃនេះ។

២. ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យមួយនេះ និងបង្កភាពងាយស្រួលដល់ការសិក្សារបស់សិស្សានុសិស្សទាំងឡាយ នាពេលកន្លងមក។

៣. សាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងមមាញឹករបស់លោកពីការបង្រៀន ដើម្បីដឹកនាំយើងខ្ញុំឱ្យសរសេររបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមួយនេះឡើងដោយមិនខ្លាចនឿយហត់ ក្នុងការផ្តល់ជាមតិ គំនិតយោបល់ និងយុទ្ធសាស្ត្រសំខាន់ៗជាច្រើនចាប់តាំងពីពេលចាប់ផ្តើម រហូតដល់សម្រេចបានជោគជ័យ។

៤. **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន** ដែលបានផ្តល់លទ្ធភាពក្នុងការអនុញ្ញាតឱ្យយើងខ្ញុំបានសិក្សាឈ្វេងយល់ និងទទួលបានបទពិសោធន៍ការងារ ដើម្បីយកចំណេះដឹងទាំងនេះទៅប្រើប្រាស់ក្នុងការបំពេញការងារនៅក្នុងសង្គមជាតិ ឱ្យកាន់តែមានភាពរីកចម្រើន។

៥. ឯកឧត្តម **អគ្គនាយក** នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ដែលបានអនុញ្ញាតឱ្យរូបយើងខ្ញុំ មានឱកាសបានចុះដកស្រង់បទពិសោធន៍លើការងារជាក់ស្តែង តាមរយៈការចុះធ្វើកម្មសិក្សានៅទីនេះ។

៦. លោក **ស៊ូ ផល្លី** ប្រធាននាយកដ្ឋានរដ្ឋបាលកំពង់ផែ ដែលបានដឹកនាំការបណ្តុះបណ្តាល ណែនាំ ចង្អុលបង្ហាញប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ក្នុងគោលបំណងពង្រឹង និងបង្កើន សមត្ថភាពរបស់យើងខ្ញុំក្នុងអំឡុងពេលកម្មសិក្សា ដើម្បីឈ្វេងយល់អំពីការងាររដ្ឋបាលមួយចំនួន ព្រមទាំងការងារផ្សេងៗទៀតផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **ឯកឧត្តម លោក លោកស្រី និងលោកគ្រូ អ្នកគ្រូ** ដែលបានជួយជ្រោមជ្រែងឱ្យយើងខ្ញុំសម្រេចបានលទ្ធផលផ្លែផ្កា ដូចមាននៅក្នុងរបាយការណ៍នេះ និងសូមគោរពជូនពរ ជួបតែសេចក្តីសុខ សុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អារម្ភកថា

សួស្តីមិត្តនិស្សិត មិត្តអ្នកអានទាំងអស់គ្នា អ្នកសិក្សាស្រាវជ្រាវ និងអ្នកដែលចង់សិក្សាឈ្វេងយល់នូវឯកសារផ្សេងៗជាទីរាប់អាន នេះជាឯកសាររបាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈរបស់យើងខ្ញុំ ដែលបានចុះទៅបំពេញការងាររយៈពេល១ខែ កន្លះ ក្នុងនាមជានិស្សិតកម្មសិក្សានៅនាយកដ្ឋានរដ្ឋបាលកំពង់ផែ នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីដកស្រង់នូវបទពិសោធន៍ការងារ សិក្សាឈ្វេងយល់ និងចងក្រងជារបាយការណ៍មួយក្រោមប្រធានបទ "**ការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ**" នេះឡើង។

ការទទួលបានឱកាសសិក្សានៅទីនេះ គឺជាដំណើរប្រតិបត្តិការគួសវាសប្រកបដោយផែនការហ្មត់ចត់ និងប្រុងប្រយ័ត្នបំផុតរបស់យើងខ្ញុំ ដើម្បីសម្រេចបាននូវគោលដៅ និងការចូលរួមយ៉ាងសកម្មក្នុងកំណែទម្រង់រដ្ឋបាល ហើយអាចក្លាយខ្លួនជាតួអង្គមិនលម្អៀងនៃការប្រែប្រួល ជាអ្នកធានាពហុនិយម និងសង្គមសន្តិភាព ព្រមទាំងជាសសរគោលនៃការធ្វើទំនើបកម្មរបស់ប្រទេស។  ជាពិសេសការចុះកម្មសិក្សា ដែលបានបង្កើតឱ្យមានថាមភាពកាន់តែខ្លាំងឡើង នឹងឆ្លុះបញ្ចាំងមកវិញលើផ្នែកសិក្សាទ្រឹស្តីនៅក្នុងសាលា សម្រាប់បំពេញបាននូវគោលការណ៍ "**ទ្រឹស្តី និង ការអនុវត្ត**" ដើម្បីជាមូលដ្ឋានគ្រឹះនៃការត្រិះរិះពិចារណា និងការធ្វើសេចក្តីសម្រេចក្នុងអាជីពការងារនាពេលអនាគត។ ការចុះកម្មសិក្សានៅ ក្រសួងសាធារណការនិងដឹកជញ្ជូន បានបង្ហាញពីភាពដ៏សម្បូរបែប និងមានលក្ខណៈវិសេសវិសាល ទាំងបទពិសោធន៍ការងារគ្រប់គ្រងរដ្ឋបាល និងការរៀបចំដឹកនាំអនុវត្តគោលនយោបាយតាមវិស័យរបស់អង្គភាពស្ថាប័ន។ កម្មសិក្សានេះ បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនសម្រាប់រូបយើងខ្ញុំផ្ទាល់ ព្រោះថា តាមរយៈការចុះកម្មសិក្សានេះ យើងខ្ញុំអាចធ្វើការសង្កេត និងអនុវត្តការងារជាក់ស្តែងមួយចំនួនដោយទទួលបាននូវចំណេះដឹង ជំនាញ និងបទពិសោធន៍ល្អៗជាច្រើន។ យើងខ្ញុំទាំងពីរនាក់ ក៏មានជំនឿជាក់ផងដែរថារបាយការណ៍កម្មសិក្សានេះ អាចនឹងក្លាយជាឧបករណ៍ស្រាវជ្រាវយ៉ាងសំខាន់សម្រាប់អ្នកសិក្សាដទៃទៀត ដែលមានបំណងសិក្សាឈ្វេងយល់ ឬស្វែងរកព័ត៌មានទាក់ទងទៅនឹងខ្លឹមសារដែលមាននៅក្នុងរបាយការណ៍នេះ ជាពិសេសគឺសម្រាប់សិស្ស និង និស្សិតជំនាន់ក្រោយៗទៀត ដែលមានបំណងធ្វើកម្មសិក្សា ឬចុះស្រាវជ្រាវឯកសារនៅក្រសួងសាធារណការនិងដឹកជញ្ជូន។

ជាមួយគ្នានេះ យើងខ្ញុំជឿជាក់ថា របាយការណ៍កម្មសិក្សានេះ គឺពិតជានៅមានចំណុចខ្វះខាត និងកំហុសឆ្គងត្រង់ប្រការណាមួយជាក់ជាមិនខានឡើយ។ ដូច្នេះ យើងខ្ញុំសូមមេត្តាអធ្យាស្រ័យទុកជាមុន នូវរាល់ចំណុចខ្វះខាត ឬកំហុសឆ្គងផ្សេងៗ ដែលអាចកើតមានដោយអចេតនា។

# មាតិកា

ទំព័រ

សន្ទានុក្រម ........ *iv*

## សេចក្តីផ្តើម

១. លំនាំដើម ........ ១

២.ចំណោទបញ្ហា ........ ២

៣.គោលបំណងនៃកម្មសិក្សា ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៤

៦.១. ការប្រមូលទិន្នន័យ ........ ៤

៦.២. វិធីសាស្ត្រក្នុងការវិភាគទិន្នន័យ ........ ៥

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៥

## ជំពូកទី១
## អំពីស្ថាប័ន និងអង្គភាពគ្រប់គ្រង

១.១.ដំណើរការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ........ ៧

១.១.១. ប្រវត្តិ និងរចនាសម្ព័ន្ធរបស់ក្រសួង ........ ៧

១.១.១.១. ប្រវត្តិរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ........ ៧

១.១.១.២. រចនាសម្ព័ន្ធរបស់ក្រសួងសាធារណកានិងដឹកជញ្ជូន ........ ៨

១.១.២. តួនាទី និងភារកិច្ចរបស់ក្រសួង ........ ៩

១.២. អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ........ ១០

១.៣. នាយកដ្ឋានរដ្ឋបាលកំពង់ផែ ........ ១១

១.៣.១. អំពីតួនាទី និងភារកិច្ចរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ ........ ១១

១.៣.២. អំពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ ........ ១២

១.៣.២.១. ការិយាល័យកិច្ចការទូទៅ ........ ១៣

១.៣.២.២. ការិយាល័យផែនការ និងនីតិកម្ម ........ ១៤

១.៣.២.៣. ការិយាល័យអភិវឌ្ឍកំពង់ផែ ........ ១៤

១.៣.២.៤. ការិយាល័យបច្ចេកទេស ........ ១៥

១.៣.២.៥ ការិយាល័យប្រតិបត្តិការកំពង់ផែ ........ ១៥

## ជំពូកទី២

## ក្របខណ្ឌនៃការផ្ដល់សេវាលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ

**២.១. ទិដ្ឋភាពទូទៅនៃកំពង់ផែ** ........ ១៧

**២.១.១. សញ្ញាណទូទៅរបស់កំពង់ផែ** ........ ១៧

**២.១.២. អំពីនិយមន័យ និងប្រភេទកំពង់ផែនៅកម្ពុជា** ........ ១៨

២.១.២.១. អំពីទិន្នន័យកំពង់ផែនៅកម្ពុជា ........ ១៨

២.១.២.២. អំពីប្រភេទកំពង់ផែនៅកម្ពុជា ........ ១៩

**២.១.៣. លក្ខខណ្ឌដើម្បីប្រកបអាជីវកម្មក្នុងវិស័យកំពង់ផែ** ........ ២០

២.១.៣.១. លិខិតវាយតម្លៃផែនការកម្មកំពង់ផែ ឬលិខិតអនុញ្ញាតបង្កើតកំពង់ផែ ........ ២០

២.១.៣.២. លិខិតអនុញ្ញាតសាងសង់កំពង់ផែ ........ ២២

**២.២. អំពីការផ្ដល់សេវាលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ** ........ ២២

**២.២.១. នីតិវិធីនៃការចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ** ........ ២៣

២.២.១.១. ដំណាក់កាលនៃការស្នើសុំ ........ ២៣

២.២.១.២. ដំណាក់កាលនៃការត្រួតពិនិត្យ ........ ២៥

២.២.១.៣. ដំណាក់កាលនៃការវាយតម្លៃ ........ ២៧

២.២.១.៤. ដំណាក់កាលនៃការអនុម័ត និងប្រគល់ឯកសារលិខិត ........ ២៧

២.២.១.៥. ដំណាក់កាលក្រោយប្រគល់ឯកសារលិខិត ........ ២៨

**២.២.២. គោលការណ៍ដែលអនុវត្តចំពោះមន្ត្រីដែលផ្ដល់សេវា** ........ ២៨

២.២.២.១. ការផ្លាស់ប្ដូរឥរិយាបទរបស់មន្ត្រីរាជការ ........ ២៨

២.២.២.២. ភាពឆ្លើយតប ........ ២៩

២.២.២.៣. ភាពច្បាស់លាស់ក្នុងការផ្ដល់ព័ត៌មាន ........ ២៩

២.២.២.៤. ការសម្របសម្រួល ........ ២៩

## ជំពូកទី៣

## លទ្ធផល នៃការវិភាគលើការផ្ដល់សេវាលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ

**៣.១. លទ្ធផលការងារ និងទិសដៅអនុវត្តបន្ទាប់របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ** ........ ៣០

**៣.១.១. លទ្ធផលការងាររបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែក្នុងការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការផែ** ........ ៣០

៣.១.១.១. លទ្ធផលការងារដែលសម្រេចបាននៅពេលកន្លងមក ........ ៣០

៣.១.១.២.បញ្ហាប្រឈមក្នុងការអនុវត្តការងាររបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ ..................... ៣២

៣.១.១.៣. ដំណោះស្រាយ ........................................................................................... ៣៣

**៣.១.២. ទិសដៅការងារដើម្បីអនុវត្តបន្ទាប់** ........................................................................... ៣៣

**៣.២. ការវិភាគទៅលើការអនុវត្តការងាររបស់នាយកដ្ឋាន និងការផ្តល់លិខិត** ........... ៣៤

**៣.២.១. តារាងនៃការវិភាគ** SWOT ........................................................................................... ៣៤

**៣.២.២. ការបកស្រាយលើលទ្ធផលនៃការវិភាគ** ........................................................................... ៣៥

៣.២.២.១. ភាពខ្លាំងរបស់នាយកដ្ឋានក្នុងការអនុវត្តការងារ ............................................... ៣៥

៣.២.២.២. ភាពខ្សោយរបស់នាយកដ្ឋានក្នុងការអនុវត្តការងារ ........................................... ៣៦

៣.២.២.៣. ភាពគំរាមកំហែង ........................................................................................ ៣៧

៣.២.២.៤. កាលានុវត្តភាព ........................................................................................... ៣៧

**៣.៣. សកម្មភាពចូលរួមអនុវត្តការងារជាក់ស្តែងនៅនាយកដ្ឋានរដ្ឋបាលកំពង់ផែ** ...... ៣៨

**៣.៣.១. ការងាររៀប** ........................................................................................................ ៣៩

**៣.៣.២. ការងារប្រជុំ និងធ្វើរបាយការណ៍** ........................................................................ ៣៩

**៣.៣.៣. ការងារផ្សេងៗ** .................................................................................................. ៤០

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

**សេចក្តីសន្និដ្ឋាន** ............................................................................................................... ៤១

**អនុសាសន៍** ........................................................................................................................ ៤៣

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# សន្ទានុក្រម

វាក្យស័ព្ទបច្ចេកទេសដែលប្រើនៅក្នុងរបាយការណ៍នេះ មាននិយមន័យដូចខាងក្រោម៖

- **កំពង់ផែ** ៖ សំដៅតំបន់ដែលមានដែនទឹក និងដែនគោក ដែលមានឋបនីយភណ្ឌ សម្រាប់បម្រើឱ្យនាវាចេញចូល បោះយុថ្កា សម្រាល ចងពួរ បត់ ចត លើកដាក់ ផ្ទេរ-ផ្ទុក និងរក្សាទុកទំនិញ និងផ្ទេរ-ផ្ទុកអ្នកដំណើរសម្រាប់ធ្វើពាណិជ្ជកម្ម ឬសហគ្រាសផ្ទាល់។(សេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការឋបនីយភណ្ឌផែ, ២០២០)
- **ឋបនីយភណ្ឌផែ** ៖ សំដៅទីតាំង ឧបករណ៍ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ បម្រើដល់ការធ្វើប្រតិបត្តិការរវាងនាវានិងកំពង់ផែ ដូចជា៖ទំនប់ការពាររលក ប្រឡាយនាវាចរណ៍ អាងបត់នាវា ទីតាំងបោះយុថ្កា តំបន់រង់ចាំ ចំណតនាវា សំណង់និងឧបករណ៍សម្ភារៈនានា។(សេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការឋបនីយភណ្ឌផែ, ២០២០)
- **ផែនការសន្តិសុខឋបនីយភណ្ឌផែ** ៖ សំដៅដល់ផែនការដែលបានកសាងឡើង ដើម្បីធានាអនុវត្តវិធានការនានា ក្នុងទិសដៅការពារអាយុជីវិតមនុស្ស ទំនិញ នាវាភ័ណ្ឌ នាវា និងឋបនីយភណ្ឌផែ ទប់ទល់នឹងហានិភ័យនៃឧប្បត្តិហេតុសន្តិសុខ។ (សេចក្តីព្រាងច្បាប់ស្តីពីកំពង់ផែ, ២០១៣)
- **សន្តិសុខឋបនីយភណ្ឌផែ** ៖ សំដៅដល់មនុស្ស តែងតាំងឡើងដោយស្ថាប័នមានសមត្ថកិច្ចកំពង់ផែ ដើម្បីទទួលខុសត្រូវចំពោះការកសាង ការអនុវត្ត ការពិនិត្យឡើងវិញ និងការរក្សាផែនការសន្តិសុខឋបនីយភណ្ឌផែ និងសហការជាមួយនឹងសន្តិសុខនាវា និងសន្តិសុខក្រុមហ៊ុន។ (សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការឋបនីយភណ្ឌផែ, ២០២០)
- **ប្រតិបត្តិការកំពង់ផែ** ៖ សំដៅដល់ទីតាំងផ្តល់សេវាកម្មកំពង់ផែដល់អ្នកប្រើប្រាស់សេវាកម្មកំពង់ផែ មានជាអាទិ៍៖ សេវាចូលចតនាវា ផ្ទេរ-ផ្ទុកទំនិញពីនាវានិងអ្នកដំណើរ រក្សាទំនិញនិងសេវាដទៃទៀត ដែលពាក់ព័ន្ធនឹងទំនិញ និងអ្នកដំណើរ។ (គោលនយោបាយជាតិស្តីពីកំពង់ផែ, ២០១៣)
- **ប្រតិបត្តិករកំពង់ផែ** ៖ សំដៅដល់បុគ្គលដែលផ្តល់សេវាកម្មកំពង់ផែដល់អ្នកប្រើប្រាស់សេវាកម្មកំពង់ផែ មានជាអាទិ៍៖ សេវាចូលចតនាវា ផ្ទេរ-ផ្ទុកទំនិញពីនាវានិងអ្នក

ដំណើរ រក្សាទំនិញនិងសេវាដទៃទៀត ដែលពាក់ព័ន្ធនឹងទំនិញ និងអ្នកដំណើរ។ (គោនយោបាយជាតិស្ដីពីកំពង់ផែ, ២០១៣)

- **កណ្ណជារ** ៖ សំដៅដល់អ្នកនាំផ្លូវនាវា ដែលមានភារកិច្ចផ្ដល់យោបល់ដល់មេបញ្ជាការនាវា ដើម្បីធ្វើនាវាចរប្រកបដោយសុវត្ថិភាពនៅក្នុងមណ្ឌលកណ្ណជារកិច្ច។
- **លិខិតអនុញ្ញាតឲ្យនាវាចូលកំពង់ផែ** ៖ សំដៅដល់ឯកសារដែលផ្ដល់សិទ្ធិឱ្យនាវាចូលកំពង់ផែ នៃព្រះរាជាណាចក្រកម្ពុជា។(សេចក្ដីព្រាងច្បាប់ស្ដីពីកំពង់ផែ, ២០២០)

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំដើម

ប្រទេសកម្ពុជា ជាប្រទេសតូច ប៉ុន្តែមានអំណោយផលខ្ពស់ពីធម្មជាតិ។ ប្រសិនបើយើងនិយាយពីផ្លូវទឹកនៅកម្ពុជា គឺត្រូវបានបែងចែកជាពីរក្រុមធំៗគឺៈ ក្រុមផ្លូវទឹកសាប(ប្រព័ន្ធទន្លេមេគង្គ និងប្រព័ន្ធទន្លេសាប) និងក្រុមផ្លូវទឹកសមុទ្រ ឬទឹកប្រៃ។ ការរៀបចំបង្កើតឱ្យមាននូវកំពង់ផែនានា នៅតាមតំបន់ផ្លូវទឹកនៃព្រះរាជាណាចក្រកម្ពុជា គឺមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការជំរុញសកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ និងក្នុងដំណើរអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ កំពង់ផែ មានតួនាទីសំខាន់ណាស់សំរាប់ជំរុញវិស័យពាណិជ្ជកម្មគ្រប់ប្រភេទ និងដំណើរអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងតំបន់ និងអន្តរជាតិ។ ស្របពេលដែលព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់ មានការអភិវឌ្ឍប្រកបដោយចីរភាព វិស័យកំពង់ផែក៏ទាមទារឱ្យមានការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពឆ្លើយតបទៅអ្នកប្រើប្រាស់សេវាប្រកបដោយទំនុកចិត្ត ផ្តល់ភាពងាយស្រួល ឆាប់រហ័ស តម្លៃថោក មានសន្តិសុខ និងសុវត្ថិភាពដល់នាវានិងទំនិញ ព្រមទាំងរួមចំណែកការពារបរិស្ថាន ដើម្បីមានលទ្ធភាពប្រកួតប្រជែងជាមួយកំពង់ផែនៅក្នុងតំបន់។ ក្នុងបរិបទនៃដំណើរសកលភាវូបនីយកម្មនាពេលបច្ចុប្បន្ននេះ វិស័យកំពង់ផែនៅលើពិភពលោកមានការវិវត្តិគួរឱ្យកត់សម្គាល់។ កំពង់ផែនៃបណ្តាប្រទេសជាច្រើន បានធ្វើការកែទម្រង់តាមបែបផែនផ្សេងៗគ្នា និងទទួលបានជោគជ័យជាបន្តបន្ទាប់ ដោយផ្លាស់ប្តូរពីការគ្រប់គ្រងបែបផ្តល់សេវាកម្ម ទៅជាការគ្រប់គ្រងបែបម្ចាស់ដី ឬធ្វើសម្បទានកម្មទៅឱ្យឯកជនធ្វើប្រតិបត្តិការ។ ក្នុងនោះ រាជរដ្ឋាភិបាលតែងបានលើកទឹកចិត្តឱ្យផ្នែកឯកជន ចូលរួមក្នុងការអភិវឌ្ឍកំពង់ផែដូចជាការសាងសង់ហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ និងធ្វើប្រតិបត្តិការកំពង់ផែផងដែរ។ ការសហការជាដៃគូរវាងផ្នែកឯកជនជាមួយវិស័យសាធារណៈបែបនេះអាចជួយសម្រួលដល់ការអភិវឌ្ឍកំពង់ផែ កែលម្អហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ និងបង្កើនប្រសិទ្ធិភាព ប្រតិបត្តិការកំពង់ផែ។ កន្លងមក ដោយសារមានគោលនយោបាយបើកចំហជើងសមុទ្ររបស់រាជរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជាបានទទួលការវិនិយោគជាបន្តបន្ទាប់ពីដៃគូអភិវឌ្ឍន៍នានាក្នុងវិស័យកំពង់ផែ ធ្វើឱ្យវិស័យនេះទទួលបាននូវការអភិវឌ្ឍគួរជាទីមោទកភាព។ កំពង់ផែដែលមានស្រាប់ បាននិងកំពុងពង្រីកខ្លួន និងទទួលបាននូវកំណើនបរិមាណទំនិញឆ្លងកាត់គួរឱ្យកត់សំគាល់ ស្របពេលដែលចរន្តនៃការវិនិយោគកំពង់ផែរបស់ផ្នែកឯកជន កំពុងតែផុសផុលឡើងជាបន្តបន្ទាប់។

ទន្ទឹមនឹងនេះ វិស័យកំពង់ផែ បាននិងកំពុងជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន មានជាអាទិ៍ សណ្តាប់ធ្នាប់នៃការកសាងកំពង់ផែថ្មីៗ រចនាសម្ព័ន្ធគ្រប់គ្រង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត លិខិតបទដ្ឋានគតិយុត្ត ធនធានមនុស្ស ព័ត៌មាននិងស្ថិតិសកម្មភាពទំនិញឆ្លងកាត់កំពង់ផែ និងការចូលរួមពីអ្នកប្រើប្រាស់កំពង់ផែ ហើយទម្លាប់នៃការគ្រប់គ្រងកំពង់ផែមួយចំនួន ពុំទាន់មានលក្ខណៈសមស្របតាមរបត់សេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។ បច្ចុប្បន្ន កម្ពុជាហាក់បី ដូចជាស្ថិតនៅក្នុងសម័យអន្តរកាល ក្នុងការគ្រប់គ្រងវិស័យកំពង់ផែ ដែលកំពុងរង់ចាំច្បាប់ និងលិខិត

បទដ្ឋាន ដើម្បីជំនួសឱ្យសារាចរណែនាំលេខ ០៧០ សរណន.សក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន ហើយ ដែលពុំទាន់មានអានុភាព គតិយុត្តគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងវិស័យកំពង់ផែនៅឡើយ។

ដោយមើលឃើញពីការលំបាកខាងលើ នាយកដ្ឋានរដ្ឋបាលកំពង់ផែ ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាល បានខិតខំក្នុងការរៀបចំ សិក្សាស្រាវជ្រាវពីឯកសារពាក់ព័ន្ធ រួមទាំងបែបបទនីតិវិធីនៃការគ្រប់គ្រងនានា ពីបណ្តា ប្រទេសមួយចំនួន ទាំងក្នុងតំបន់ និងអន្តរជាតិ ដើម្បីចងក្រងច្បាប់ស្តីពីកំពង់ផែ និងប្រកាសស្តីពីនីតិវិធីនានា សម្រាប់គ្រប់គ្រងអាជីវកម្មកំពង់ផែនៅកម្ពុជា ឱ្យស្របនឹងគោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រង កំពង់ផែ។ ការខិតខំរៀបចំអត្ថបទច្បាប់នេះឡើង គឺដើម្បីធ្វើការកែទម្រង់លើការគ្រប់គ្រង និងប្រតិបត្តិការកំពង់ផែ ដោយធ្វើសនិទានកម្មគ្រប់ទិដ្ឋភាពនៃរបត់សេដ្ឋកិច្ច និងនយោបាយរបស់ព្រះរាជាណាចក្រកម្ពុជា ជាពិសេស យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលគ្រប់ដំណាក់កាល ក៏ដូចជាចរន្តភាវូបនីយកម្ម សកលភាវូបនីយកម្ម និងទំនើបភាវូបនីយកម្ម ដើម្បីធានាការអភិវឌ្ឍវិស័យកំពង់ផែប្រកបដោយចីរភាព មានទំនុកចិត្តពីអ្នកប្រើប្រាស់ មានសន្តិសុខ សុវត្ថិភាព និងរួមចំណែកការពារបរិស្ថាន។

## ២. ចំណោទបញ្ហា

ដើម្បីធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹង **“ការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ”** ឱ្យកាន់តែមានភាពស៊ីជម្រៅ និងមានភាពច្បាស់លាស់ថែមទៀតនោះ ចំណោទបញ្ហាត្រូវបានលើកឡើងជាបន្តបន្ទាប់ថា៖ (១).តើការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ មាន នីតិវិធីដូចម្តេចខ្លះ? (២). តើមន្ត្រីរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវធ្វើការអនុវត្តគោលការណ៍ណែនាំ បែបណាខ្លះ ក្នុងការផ្តល់សេវានេះជូនដល់ប្រជាពលរដ្ឋ? (៣).តើអង្គភាពមានបញ្ហាប្រឈមអ្វីខ្លះ ពាក់ព័ន្ធនឹង ការផ្តល់សេវានេះទៅកាន់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់កំពង់ផែ?

## ៣. គោលបំណងនៃកម្មសិក្សា

គោលបំណងសំខាន់ៗនៃរបាយការណ៍កម្មសិក្សានេះ គឺដើម្បីឈ្វេងយល់លើចំណុចដូចខាងក្រោម៖

- សាវតា រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- គោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ
- នីតិវិធីជាក់ស្តែងនៃការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ
- ការអនុវត្តកិច្ចការរដ្ឋបាលខ្លះៗ តាមរយៈការចុះកម្មសិក្សាដោយផ្ទាល់
- ដកស្រង់បទពិសោធន៍ការងារក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលអង្គភាពសាធារណៈជួបប្រទះ
- ចូលរួមអភិវឌ្ឍការផ្តល់សេវាសាធារណៈនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងអត្ថបទរបាយការណ៍នេះ យើងនឹងធ្វើការសិក្សាវែកញែកលំអិតតែទៅលើដំណើរការ ព្រមទាំងនីតិវិធីក្នុងការផ្តល់សេវាចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ ជូនដល់ក្រុមហ៊ុនឯកជនដោយនាយកដ្ឋានរដ្ឋបាលតែប៉ុណ្ណោះ។ ពោលគឺ ចាប់ពីពេលដែលរាល់សំណុំឯកសារនៃការស្នើសុំបានទៅដល់នាយកដ្ឋានរដ្ឋបាលកំពង់ផែ រហូតដល់ការសម្រេចលទ្ធផលចេញជាលិខិតអនុញ្ញាតមួយឡើងសម្រាប់ប្រគល់ជូនដល់អ្នកស្នើសុំ។ ជាមួយគ្នានេះ ការសិក្សារបស់យើងខ្ញុំផ្តោតទៅលើតែកំពង់ផែណាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ចំណែកឯកំពង់ផែដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័នផ្សេងគឺយើងមិនបានយកមកធ្វើការសិក្សាឡើយ។

ចំពោះប្រភេទទិន្នន័យដែលយើងខ្ញុំនឹងលើកយកមកធ្វើការសិក្សា ក្នុងអត្ថបទរបាយការណ៍នេះ គឺផ្តោតសំខាន់លើឯកសារជាតិរួមមាន៖ (១).គោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ ដែលទទួលបានការឯកភាពពីទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣, (២). សេចក្តីព្រាងច្បាប់ស្តីពីកំពង់ផែ (៣).សារាចរណែនាំលេខ ០៧០ សរណន.សក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពី ផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលិខិតបទដ្ឋាននានាដែលបានបង្កើតឡើងដើម្បីសម្រួលដល់ការអនុវត្តការងាររបស់នាយកដ្ឋាន។ ហើយយើងក៏នឹងលើកយកនូវសមិទ្ធផលដែលនាយកដ្ឋានសម្រេចបានលើការងារចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែចាប់ពីឆ្នាំ២០១៩ ដល់ដើមឆ្នាំ២០២០ និងទិសដៅការងារបន្ទាប់ដែលបានដាក់ចេញសម្រាប់អនុវត្តក្នុងឆ្នាំ២០២០ នេះប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះថាវាមិនត្រឹមតែផ្តល់ជាប្រយោជន៍ដល់ពួកខ្ញុំទាំងពីរតែប៉ុណ្ណោះទេ តែការសិក្សាស្រាវជ្រាវមួយនេះ ក៏បានផ្តល់ជាឧត្តមប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ជាពិសេសដល់សង្គមជាតិទាំងមូលដូចខាងក្រោម៖

ទីមួយ ការស្រាវជ្រាវមួយនេះ បានជួយអោយយើងខ្ញុំទទួលបានចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអនុញ្ញាតឱ្យយើងខ្ញុំអាចធ្វើការផ្សារភ្ជាប់ពីការសិក្សាទ្រឹស្តី ទៅនឹងការអនុវត្តន៍ការងារជាក់ស្តែង ពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ ការគ្រប់គ្រងអង្គភាពសាធារណៈ ដំណើរការងាររដ្ឋបាលមួយចំនួន និងការផ្តល់សេវាសាធារណៈនានា របស់ស្ថាប័នរដ្ឋ ដែលជាចំណែកមួយក្នុងការចូលរួមលើកកម្ពស់ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈផ្សេងៗ ជាពិសេសសេវាចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែនៅកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើង។ ជាងនេះទៅទៀត យើងខ្ញុំនឹងអាចបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានយ៉ាងជោគជ័យនាពេលខាងមុខផងដែរ។

ទីពីរ ការសិក្សាស្រាវជ្រាវមួយនេះ ក៏នឹងក្លាយជាឯកសារជំនួយ ដែលនឹងអាចក្លាយជាមូលដ្ឋានមួយដែលជួយសម្រួលដល់ការសិក្សា និងស្រាវជ្រាវជាបន្តបន្ទាប់របស់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀត ដែលមានបំណង់ចង់ធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ ពីចំណេះដឹងពាក់ព័ន្ធលើប្រធានបទដែលទាក់នឹងវិស័យកំពង់ផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជាថែមទៀតផង។

ចុងក្រោយ ការសិក្សាស្រាវជ្រាវនេះ ក៏នឹងបានផ្តល់ជាឧត្តមប្រយោជន៍យ៉ាងសំខាន់សម្រាប់សង្គមផងដែរ ជាពិសេស ការចូលរួមចំណែកក្នុងការផ្សព្វផ្សាយសេវាសាធារណៈរបស់រដ្ឋពាក់ព័ន្ធនិងវិស័យកំពង់ផែនៅកម្ពុជាឱ្យកាន់តែមានភាពទូលំទូលាយ ប្រកបដោយតម្លាភាព ដើម្បីជម្រុញឱ្យសេវាមួយនេះកាន់តែមានភាពល្អប្រសើរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៦.១. ការប្រមូលទិន្នន័យ

ដើម្បីជួយឱ្យការចងក្រងឯកសារនេះបានល្អប្រសើរឡើង យើងខ្ញុំបានរៀបចំបែងចែកជា៣ជំហានសំខាន់ៗ សម្រាប់ធ្វើការប្រមូលទិន្នន័យឱ្យបានគ្រប់គ្រាន់ ដើម្បីជាមូលដ្ឋានក្នុងការវិភាគឱ្យបានល្អ និងគ្រប់ជ្រុងជ្រោយ។ ជំហានសំខាន់ៗទាំងនោះរួមមាន៖

ជំហានទី១ ស្វែងរក និងឈ្វេងយល់លើលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានា(ច្បាប់, ព្រះរាជក្រឹត្យ, អនុក្រឹត្យ, សារាចរ), យុត្តិសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ឯកសារជំនួយស្មារតីដែលបានសិក្សាកន្លងមកពីសាស្ត្រាចារ្យនៅសាលា ឯកសារដែលទទួលបានតាមរយៈប្រព័ន្ធអេឡិចត្រូនិច(Internet) និងឯកសារមួយចំនួនផ្សេងទៀតដែលពាក់ព័ន្ធ។

ជំហានទី២ គឺការចុះធ្វើកម្មសិក្សាដោយផ្ទាល់នៅនាយកដ្ឋានរដ្ឋបាលកំពង់ផែ របស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ នៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីធ្វើការអង្កេត និងស្ទាបស្ទង់លើការអនុវត្តការងារជាក់ស្តែងរបស់អង្គភាព ដែលទទួលបន្ទុកអនុវត្តរាល់លិខិតបទដ្ឋានគតិយុត្តិ និងសារាចរណែនាំនានា ដើម្បីផ្តល់សេវាលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែជូនដល់ក្រុមហ៊ុនឯកជនដែលបានស្នើសុំ។ ក្នុងកំឡុងពេលនៃកម្មសិក្សានេះដែរ យើងខ្ញុំក៏បានប្រមូលទិន្នន័យបន្ថែម តាមរយៈការសម្ភាសន៍សួរនាំផ្ទាល់ និងសុំឯកសារបន្ថែមពីសំណាក់មន្ត្រីកំពុងបម្រើការងារផ្ទាល់នៅក្នុងនាយកដ្ឋានរដ្ឋបាលកំពង់ផែផងដែរ។ ឯកសារទាំងអស់នោះរួមមាន៖ សេចក្តីព្រាងច្បាប់ស្តីពីកំពង់ផែ ដែលមិនទាន់បានចេញផ្សាយជាសាធារណៈនៅឡើយ, របាយការណ៍ស្តីពីសមិទ្ធផលដែលនាយកដ្ឋានសម្រេចបាន, និងទិន្នន័យស្ថិតិកំពង់ផែនៅព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្នជាដើម ដើម្បីបំពេញភាពខ្វះខាតលើផ្នែកខ្លឹមសាររបស់របាយការណ៍បញ្ចប់ការសិក្សាមួយនេះ ឱ្យកាន់តែមានលក្ខណៈពេញលេញ និងមានភាពស៊ីជម្រៅបន្ថែមទៀត។

ជំហានទី៣ គឺជាការបូកសរុបលទ្ធផល នៃការចុះកម្មសិក្សារបស់យើងខ្ញុំ ពីសំណាក់លោកប្រធាននាយកដ្ឋានរដ្ឋបាលកំពង់ផែផ្ទាល់។ តាមរយៈនេះ យើងខ្ញុំទទួលបាននូវឱកាសក្នុងការសាកសួរ និងការណែនាំលម្អិតបន្ថែមលើចំណុចមួយចំនួនទៀតដែលមិនទាន់បានយល់ច្បាស់ ដើម្បីឱ្យខ្លឹមសារនៃអត្ថបទនេះ កាន់តែមានទម្ងន់ និងភាពច្បាស់លាស់អាចយកមកប្រើជាឧត្តមប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត។

### ៦.២. វិធីសាស្ត្រក្នុងការវិភាគទិន្នន័យ

បន្ទាប់ពីទទួលបានទិន្នន័យគ្រប់គ្រាន់តាមរយៈការធ្វើកម្មសិក្សារួចមក យើងបានយកទិន្នន័យដែលទទួលបានទាំងនោះមកធ្វើការប្រៀបធៀបរវាងទ្រឹស្តី ជាមួយនឹងការអនុវត្តជាក់ស្តែង ដើម្បីវិភាគរកភាពខ្លាំង ភាពខ្សោយ កត្តាគម្រាមកំហែង និងកាលានុវត្តភាពក្នុងការអនុវត្តការងាររបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ ពាក់ព័ន្ធនឹងការចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ ដើម្បីឈានឆ្ពោះទៅរកការសន្និដ្ឋានជារួម និងលើកជាអនុសាសន៍ដើម្បីចូលរួមចំណែកក្នុងការកែលម្អ នូវចំណុចខ្វះខាតមួយចំនួនឱ្យកាន់តែមានភាពល្អប្រសើរថែមមួយកម្រិតទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរបាយការណ៍កម្មសិក្សានេះ យើងខ្ញុំបានបែងចែកចេញជា ៥ផ្នែកធំៗដូចខាងក្រោម៖

សេចក្តីផ្តើម មានបង្ហាញពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី១ អំពីស្ថាប័ន និងអង្គភាពគ្រប់គ្រង** មានបង្ហាញពី ដំណើរការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន(ប្រវត្តិ និងរចនាសម្ព័ន្ធរបស់ក្រសួង, មុខងារ និងភារកិច្ចរបស់ក្រសួង) មុខងារភារកិច្ចរបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ព្រមទាំងនាយកដ្ឋានរដ្ឋបាលកំពង់ផែ(អំពីតួនាទីនិងភារកិច្ចរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ, អំពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ)ផងដែរ។

**ជំពូកទី២ អំពីក្របខណ្ឌក្នុងការចេញសេវាលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ** មានបង្ហាញពីទិដ្ឋភាពទូទៅនៃកំពង់ផែ(សញ្ញាណទូទៅរបស់កំពង់ផែ, អំពីទិន្នន័យកំពង់ផែ និងប្រភេទកំពង់ផែនៅកម្ពុជា) លក្ខខណ្ឌដើម្បីប្រកបអាជីវកម្មក្នុងវិស័យកំពង់ផែ(លិខិតវាយតម្លៃផែនការកម្មកំពង់ផែ ឬលិខិតអនុញ្ញាតបង្កើតកំពង់ផែ, លិខិតអនុញ្ញាតសាងសង់កំពង់ផែ) និងអំពីការផ្តល់សេវាលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ(នីតិវិធីនៃការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ, គោលការណ៍ដែលអនុវត្តចំពោះមន្ត្រីដែលផ្តល់សេវា)។

**ជំពូកទី៣ លទ្ធផល និងការវិភាគអំពីការផ្តល់សេវាលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ** មានបង្ហាញពីលទ្ធផលការងារ និងទិសដៅអនុវត្តបន្ទាប់របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ(លទ្ធផលការងាររបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែក្នុងការចេញលិខិតប្រតិបត្តិការផែ, ការងារដែលបានគ្រោងដើម្បីអនុវត្តបន្ទាប់) ការវិភាគទៅលើ

ការអនុវត្ត(ការវិភាគ SWOT, ការបកស្រាយលើលទ្ធផលនៃការវិភាគ) សកម្មភាពចូលរួមអនុវត្តការងារជាក់ស្តែងនៅនាយកដ្ឋានរដ្ឋបាលកំពង់ផែ(ការងាររបៀប ការងារប្រជុំ និងធ្វើរបាយការណ៍ និងការងារផ្សេងៗ)។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** មានបង្ហាញពី ចំណុចសន្និដ្ឋានចុងក្រោយលើប្រធានបទ និងផ្តល់ជាអនុសាសន៍ដែលកើតចេញពីចំណេះដឹងនៃការស្រាវជ្រាវរបស់យើងខ្ញុំ ដើម្បីរួមចំណែកអភិវឌ្ឍការផ្តល់សេវា និងការគ្រប់គ្រងអង្គភាពឱ្យកាន់តែប្រសើរឡើង។

# ជំពូកទី១
# អំពីស្ថាប័ន និងអង្គភាពគ្រប់គ្រង

# ជំពូកទី១
# អំពីស្ថាប័ន និងអង្គភាពគ្រប់គ្រង

ដើម្បីសិក្សាឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅ លើប្រធានបទស្តីពី "ការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ" យើងនឹងធ្វើការសិក្សាជាសារវន្តទៅលើដំណើរការប្រព្រឹត្តទៅរបស់ស្ថាប័ន និងអង្គភាពដែលធ្វើការគ្រប់គ្រង និងទទួលបន្ទុកលើការងារផ្តល់សេវានេះ ពោលគឺក្រសួងសាធារណការ និងដឹកជញ្ជូនដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ទទួលបន្ទុកគ្រប់គ្រងរាល់វិស័យដឹកជញ្ជូនទាំងអស់របស់កម្ពុជា(ចំណុច ១.១)។ ក្នុងនោះ យើងក៏នឹងសិក្សាផងដែរទៅលើរចនាសម្ព័ន្ធ និងស្ថានភាពរបស់ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ដែលជាអង្គភាពចំណុះឱ្យក្រសួងសាធារណការនិងដឹកជញ្ជូន ទទួលភារកិច្ចគ្រប់គ្រងលើវិស័យដឹកជញ្ជូនផ្លូវទឹករបស់កម្ពុជា(ចំណុច១.២) និងនាយកដ្ឋានរដ្ឋបាលកំពង់ផែ ដែលជាអ្នកអនុវត្តផ្ទាល់លើការផ្តល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ ជូនដល់ក្រុមហ៊ុនផែដែលស្នើសុំ(ចំណុច ១.៣)។

## ១.១. ដំណើរការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន

ក្នុងរយៈពេល២២ឆ្នាំ ក្រោយពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន កម្ពុជាបានប្រែមុខមាត់វិស័យនេះគួរឱ្យកត់សម្គាល់ ពោលគឺបានប្រែក្លាយពីប្រទេសដែលមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនអន់ថយ ទៅជាប្រទេសដែលមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនទំនើប ងាយស្រួល និងជាប់ធន់បានយូរ។ នៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាជាសង្ខេបទៅលើប្រវត្តិ-រចនាសម្ព័ន្ធ ព្រមទាំងតួនាទី-ភារកិច្ច របស់ក្រសួងនេះផងដែរ។

### ១.១.១. ប្រវត្តិ និងរចនាសម្ព័ន្ធរបស់ក្រសួង

#### ១.១.១.១. ប្រវត្តិរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន

ក្រសួងសាធារណការនិងដឹកជញ្ជូន ជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងការដឹកនាំនិងគ្រប់គ្រងវិស័យសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងនេះ ត្រូវបានបង្កើតឡើងជាដំបូងនៅក្នុងឆ្នាំ១៩៤៥ ដោយបានដាក់ឈ្មោះថា ក្រសួងការពារជាតិ សាធារណការ និងសុខាភិបាល។ ក្រោយមក ដោយសារការផ្លាស់ប្តូរនៃបរិបទនយោបាយ ក្រសួងក៏បានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនជាបន្តបន្ទាប់ រហូតទៅដល់ ៤៩ លើក មុននឹងដាក់ឈ្មោះជាផ្លូវការថា ក្រសួងសាធារណការនិងដឹកជញ្ជូន ដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦។[១] ក្រសួងសាធារណការនិងដឹកជញ្ជូន ដែលត្រូវបានឡាយព្រះហស្ថលេខាឱ្យដំណើរការជាផ្លូវការនេះ គឺមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរាល់សកម្មភាពពាក់ព័ន្ធលើវិស័យសាធារណការនិងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។

---

[១] សូមមើលតារាងស្តីពីលំដាប់លំដោយនៃការវិវត្តន៍ស្ថាប័នសាធារណការនិងដឹកជញ្ជូន នៃឧបសម្ព័ន្ធ "ខ.៥".

ក្រោយពីបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន អស់រយៈពេល២២ឆ្នាំកន្លងមក វិស័យសាធារណការនិងដឹកជញ្ជូន បានប្រែមុខមាត់គួរឱ្យកត់សម្គាល់ ពោលគឺបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅកម្ពុជាឱ្យមានលក្ខណៈទំនើបកម្មដើម្បីធ្វើការប្រកួតប្រជែងនឹងបណ្តាប្រទេសនានា។ កត្តានេះជំរុញឱ្យមានការបង្កើន និងពន្លឿនការដឹកជញ្ជូនផលិតផលរបស់ប្រជាពលរដ្ឋសម្រាប់ការផ្គត់ផ្គង់ក្នុងស្រុក ក៏ដូចជាទំនាក់ទំនងពាណិជ្ជកម្មជាមួយបរទេសបានដោយសុវត្ថិភាព ទាន់ពេលវេលា និងចំណាយតិច។ បើយើងនិយាយពីទំហំនៃការដឹកទំនិញ យើងឃើញថាប្រព័ន្ធដឹកជញ្ជូនផ្លូវទឹកនៅកម្ពុជាមានវិសាលភាពដឹកទំនិញបានច្រើនគួរឱ្យកត់សម្គាល់ ពីមួយឆ្នាំទៅមួយឆ្នាំ។ ជាក់ស្តែង ចំពោះស្ថានភាពប្រព័ន្ធផ្លូវទឹកសាបនៅកម្ពុជា គឺមានជម្រៅទឹកពី ២.៥ ទៅ ៤.៥ម៉ែត្រ ដែលអាចអនុញ្ញាតឱ្យនាវាផ្ទុកកុងតឺន័របានទម្ងន់ប្រមាណជាង ២០០០តោន ឬស្មើនឹង ១២០TEUs និងនាវាដែលផ្ទុកអ្នកដំណើរប្រមាណពី ៥០-១២០នាក់ ក្នុងមួយគ្រឿងអាចធ្វើការឆ្លងកាត់បាន។[២] ដោយឡែកចំពោះស្ថានភាពផ្លូវសមុទ្រវិញ យើងឃើញថាវាមានជម្រៅពី៤ម៉ែត្រ ទៅ ១១ម៉ែត្រ ហើយអាចអនុញ្ញាតឱ្យនាវាដែលមានចំណុះផ្ទុកពី ៣ ០០០TEUs ទៅ ៧ ០០០TEUs ចេញចូលចតបាន។[៣] ការនេះ កំពង់ផែបានក្លាយជាមជ្ឈមណ្ឌលនៃច្រកចេញចូលដ៏សំខាន់សម្រាប់សេដ្ឋកិច្ចជាតិ ជំរុញសកម្មភាពពាណិជ្ជកម្ម ទាក់ទាញអ្នកវិនិយោគទុន បង្កើតតំបន់ឧស្សាហកម្ម បង្កើតការងារ បង្កើនចំណូលដល់ប្រជាពលរដ្ឋ បង្កើនចំណូលជាតិ និងចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជាផងដែរ។ តួយ៉ាង ចំណូលរបស់កំពង់ផែអន្តរជាតិក្រុងព្រះសីហនុក្នុងឆ្នាំ២០១៩ នេះ មានការកើនឡើងយ៉ាងខ្លាំង ពោលគឺទទួលចំណូលសរុបចំនួន ៣៣៣ ៩១៣ ៣៧៧ ០០០រៀល កើនឡើងចំនួន ៣៣៧ ៧៣២ ០០០ រៀល ស្មើនឹង២១.១៧% បើធៀបនឹងឆ្នាំ២០១៨ និងចំណេញសុទ្ធក្នុងការិយបរិច្ឆេទចំនួន ៤៣ ៤៦៣ ៥០០ ០០០ រៀល។[៤] នេះយើងមិនទាន់និយាយពីចំណូលរបស់កំពង់ផែស្វយ័តក្រុងភ្នំពេញ និងកំពង់ផែផ្សេងៗទៀត ដែលបានបំពេញការងាររបស់ខ្លួនយ៉ាងសកម្មលើការបម្រើសេវាកម្មសំខាន់ៗដូចជា៖ សេវាកម្មនាវាចរ សេវាលើកដាក់ទំនិញ សេវាស្តុកទំនិញ សេវាដឹកជញ្ជូន សេវាភស្តុភារ និងសេវាកម្មមូលដ្ឋានផ្គត់ផ្គង់ការរុករកប្រេងជាដើម។

### ១.១.១.២. រចនាសម្ព័ន្ធរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន

យោងតាមមាត្រា៦ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន បានកំណត់អំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រង ដោយបានបែងចែកឱ្យមានជាអង្គភាពថ្នាក់កណ្តាល អង្គភាពថ្នាក់មូលដ្ឋាន និងសហគ្រាសសាធារណៈ។

---

[២] នាយកដ្ឋាននាវាជំនួញសមុទ្រ.(២០១៩). “The Waterways Infrastructure Development in Cambodia”.

[៣] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា.(២០១៧).SEA PORT. ដកស្រង់ពី http://www.cambodiainvestment.gov.kh/investors-information/infrastructure/sea-port.html, បកប្រែដោយ កញ្ញា តាន់ សម្បត្តិសុភ័កត្រា.

[៤] កំពង់ផែស្វយ័តក្រុងព្រះសីហនុ,(២០១៩).របាយការណ៍ហិរញ្ញវត្ថុសម្រាប់បំណាច់ឆ្នាំ២០១៩.

នៅអង្គភាពថ្នាក់កណ្តាលរបស់ក្រសួងរួមមាន៖ ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានសាធារណការ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ អគ្គនាយកដ្ឋានភស្តុភារកម្ម អគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផ្លូវដែក នាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ និងអង្គភាពលទ្ធកម្ម។[៥] ក្នុងអគ្គនាយកដ្ឋាននីមួយៗ ដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងមួយចំនួនទៀតជាជំនួយការ ដើម្បីសហការគ្នាបម្រើការងារលើជំនាញរៀងៗខ្លួន។ ចំនួនជាក់លាក់នៃអគ្គនាយករងនៅតាមអគ្គនាយកដ្ឋាននីមួយៗ គឺមានការប្រែប្រួលទៅតាមតម្រូវការចាំបាច់នៃទំហំការងារ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។ ចំណែកឯអង្គភាពថ្នាក់មូលដ្ឋានវិញ រួមមាន៖ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត និងការិយាល័យសាធារណការនិងដឹកជញ្ជូនក្រុង ស្រុក ខណ្ឌ។ ហើយសហគ្រាសសាធារណៈមាន៖ កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ និងមន្ទីរពិសោធន៍សំណង់និងសាធារណការ។ បច្ចុប្បន្ន ក្រសួងសាធារណការនិងដឹកជញ្ជូន បានបង្កើត និងដាក់ឱ្យដំណើរការអង្គភាពថ្នាក់មូលដ្ឋានរបស់ខ្លួន នៅគ្រប់បណ្តាខេត្តក្រុងទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ហើយអង្គភាពនីមួយៗមានភារកិច្ចធ្វើរបាយការណ៍ការងាររបស់ខ្លួនជាប្រចាំ មកកាន់អង្គភាពថ្នាក់កណ្តាល។

### ១.១.២. តួនាទី និងភារកិច្ចរបស់ក្រសួង

ផ្អែកលើ អនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន បានកំណត់អំពីមុខងារ ភារកិច្ចក្នុងការរៀបចំ និងតាមដានការអនុវត្តន៍គោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់អភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន និងរៀបចំផែនការមេបណ្តាញដឹកជញ្ជូនតាមផ្លូវគោក ផ្លូវដែក ផ្លូវទឹក ផ្លូវសមុទ្រ កំពង់ផែ ឬតាមបណ្តាញផ្សេងៗទៀត ដែលអនុញ្ញាតដោយរាជរដ្ឋាភិបាល។ ពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូនទាំងអស់នេះ ក្រសួងសាធារណការនិងដឹកជញ្ជូន ជាអ្នកគ្រប់គ្រង ត្រួតពិនិត្យ តាមដាន សិក្សាស្រាវជ្រាវគម្រោងប្លង់ និងវាយតម្លៃលើការងារសាងសង់ អភិវឌ្ឍជួសជុល និងថែទាំ ផ្លូវ ថ្នល់ ស្ពាន កំពង់ចម្លង ផ្លូវដែក ផ្លូវទន្លេ ផ្លូវសមុទ្រ កំពង់ផែ ភស្តុភារកម្ម និងការងារផ្សេងទៀត ដែលពាក់ព័ន្ធនិងវិស័យសាធារណការ និងដឹកជញ្ជូន។ ក្នុងករណីនេះ ក្រសួងត្រូវរៀបចំ គ្រប់គ្រង តាមដាន និងត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ រួមទាំងចាត់វិធានការអនុវត្តយ៉ាងម៉ឺងម៉ាត់ ដើម្បីថែរក្សាការពារផ្លូវថ្នល់ ស្ពាន ឬហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្សេងទៀត។

---

[៥] មាត្រា៦ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន.

ផ្តោតលើការងារផ្នែកច្បាប់ និងលិខិតបទដ្ឋានគតិយុត្តវិញ ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំកសាងសេចក្តីព្រាងច្បាប់ គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងវិស័យសាធារណការនិងដឹកជញ្ជូន ព្រមទាំងតាមដានត្រួតពិនិត្យការអនុវត្តន៍លិខិតគតិយុត្តទាំងអស់នោះ សម្រាប់វិស័យសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនេះ ក្រសួងត្រូវរៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយបទប្បញ្ញត្តិបច្ចេកទេស ឬស្តង់ដារបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗ ដើម្បីធានាគុណភាពសំណង់ហេដ្ឋារចនាសម្ព័ន្ធសាធារណការ សំណង់ផ្លូវដែក និងសំណង់កំពង់ផែ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ចំពោះការផ្តល់សេវាសាធារណៈជូនដល់សាធារណជន ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវគ្រប់គ្រង វាយតម្លៃ ទទួលស្គាល់ និងផ្តល់វិញ្ញាបនបត្រអនុញ្ញាតការធ្វើអាជីវកម្ម និងសាងសង់សំណង់ទាំងឡាយ ដែលបម្រើដល់វិស័យសាធារណការ និងដឹកជញ្ជូន។ ក្នុងការផ្តល់សេវានេះផងដែរ ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអប់រំនិងណែនាំមន្ត្រីគ្រប់លំដាប់ថ្នាក់ ឱ្យអនុវត្តតាមគោលការណ៍នានាដែលបានកំណត់ដោយរាជរដ្ឋាភិបាល ដើម្បីធានាជម្រុញការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលល្អប្រសើរឡើង។

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដឹកនាំ និងចូលរួមរៀបចំអនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ លើវិស័យសាធារណការ និងដឹកជញ្ជូន និងមានភារកិច្ចជំរុញលើកទឹកចិត្តដល់ផ្នែកឯកជនចូលរួមក្នុងការអភិវឌ្ឍវិស័យនេះ ដើម្បីឱ្យវិស័យសាធារណការ និងដឹកជញ្ជូននៅកម្ពុជា កាន់តែមានភាពរីកចម្រើន ដែលសម្រួលដល់ការធ្វើសមាហរណកម្ម ព្រះរាជាណាចក្រកម្ពុជាចូលក្នុងក្របខណ្ឌអនុតំបន់ តំបន់ និងសកលលោក ប្រកបដោយប្រសិទ្ធភាព និងការប្រកួតប្រជែងខ្ពស់។ លើសពីនេះ ក្រសួងសាធារណការនិងដឹកជញ្ជូន ក៏ត្រូវបន្តអភិវឌ្ឍធនធានមនុស្ស ដោយការលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យាថ្មីៗ ដល់ការអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន ដើម្បីឱ្យកាន់តែមានភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

ក្រសួងសាធារណការនិងដឹកជញ្ជូន ជាអាណាព្យាបាលបច្ចេកទេសលើសហគ្រាសសាធារណៈដូចជា កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ មន្ទីរពិសោធន៍សំណង់ និងអង្គភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យសាធារណការ និងដឹកជញ្ជូន។ ក្រសួង ត្រូវចុះធ្វើអធិការកិច្ច និងសវនកម្មបច្ចេកទេស ព្រមទាំងសវនកម្មផ្ទៃក្នុងលើវិស័យសាធារណការ និងដឹកជញ្ជូន ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានទៀងទាត់។

## ១.២. អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ជាស្ថាប័នចំណុះឱ្យក្រសួងសាធារណការនិងដឹកជញ្ជូន ដែលគ្រប់គ្រងលើការផ្តល់សេវាសាធារណៈលើវិស័យដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ។

ក្នុងឆ្នាំ២០១៩ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ មានមន្ត្រីក្របខណ្ឌសរុបចំនួន១៥២រូប ដែលបុរស ១២៥រូប ស្ត្រី ២៧រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១៤រូប ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានមានចំនួន ០៦រូប(អគ្គនាយក០១រូប និងអគ្គនាយករងចំនួន០៥រូប) ថ្នាក់ដឹកនាំនាយកដ្ឋានចំនួន ២០រូប ថ្នាក់ការិយាល័យ ចំនួន ៤៨រូប និងមន្ត្រីក្របខណ្ឌឯទៀតមានចំនួន ៧៨រូប។ ក្រៅពីនេះមានមន្ត្រីស្ថិតនៅក្រៅក្របខណ្ឌដើមចំនួន ០៦រូប និងមន្ត្រីបម្រើការងារគម្រោងក្រៅនាយកដ្ឋានចំនួន ០១រូប។ ក្នុងចំណោមមន្ត្រីក្របខណ្ឌចំនួន ១៥២រូប មាន មន្ត្រីជំនាញថ្នាក់បរិញ្ញាបត្រ អនុបណ្ឌិត វិស្វករចំនួន១២៧រូប មន្ត្រីមធ្យមបច្ចេកទេស ០៩រូប និងមន្ត្រីរាជការ ធម្មតា ១៦រូប។[៦] អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ មាននាយកដ្ឋានចំនួន ៤គឺ៖ នាយកដ្ឋាន រដ្ឋបាលកំពង់ផែ, នាយកដ្ឋាននាវាជំនួញសមុទ្រ, នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក, និងនាយកដ្ឋានហេដ្ឋារចនា សម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ។[៧] នាយកដ្ឋាននីមួយៗ ត្រូវបំពេញមុខងាររៀងៗខ្លួន អនុលោមតាមលិខិត បទដ្ឋានគតិយុត្តទាំងឡាយដែលបានកំណត់ ក្នុងនាមជាសេនាធិការផ្ទាល់របស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ។

ក្នុងចំណោមនោះ ការផ្តល់សេវាលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ គឺត្រូវបានទទួលបន្ទុកផ្ទាល់ដោយ នាយកដ្ឋានរដ្ឋបាលកំពង់ផែ។ នៅចំណុចបន្តទៅនេះ យើងនឹងសិក្សាឱ្យបានកាន់តែស៊ីជម្រៅថែមទៀត ទៅលើ នាយកដ្ឋានរដ្ឋបាលកំពង់ផែ នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ដោយជាផ្តោតជាសំខាន់ ទៅលើតួនាទីភារកិច្ចរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ និងការិយាល័យនីមួយៗជាចំណុះ។

## ១.៣. នាយកដ្ឋានរដ្ឋបាលកំពង់ផែ

### ១.៣.១. អំពីតួនាទី និងភារកិច្ចរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ

នាយកដ្ឋានរដ្ឋបាលកំពង់ផែ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់ដោយអគ្គនាយកដ្ឋានដឹកជញ្ជូន ផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ហើយមានភារកិច្ច រៀបចំផែនការគោលនយោបាយ ច្បាប់ បទបញ្ញាសម្រាប់ គ្រប់គ្រងកំពង់ផែ និងការបណ្តុះបណ្តាលស្រាវជ្រាវលើការគ្រប់គ្រងកំពង់ផែ ដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងសន្តិសុខសម្រាប់កំពង់ផែ ស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ។[៨] ផ្អែកលើភារកិច្ចនេះ នាយកដ្ឋានមាន សមត្ថកិច្ចក្នុងការគ្រប់គ្រងកំពង់ផែដូចជា៖ ការរៀបចំប្លង់ ការសាងសង់ ការធ្វើប្រតិបត្តិការកំពង់ផែ និងចាត់

---

៦ របាយការណ៍ស្តីពីលទ្ធផលការងាររបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ប្រចាំខែកុម្ភៈ ឆ្នាំ២០២០.

៧ សូមមើលអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ឧបសម្ព័ន្ធ "ខ.២".

៨ មាត្រា៣៦ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង សាធារណការ និងដឹកជញ្ជូន.

ចែងចលនានាវានៅកំពង់ផែ និងការងារពាក់ព័ន្ធផ្សេងៗទៀត ដើម្បីធានាសន្តិសុខក្នុងតំបន់កំពង់ផែនានា។ បន្ថែមពីនេះ នាយកដ្ឋានមានតួនាទីក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក សម្រាប់នាវាចរណ៍ដូចជាៈ ការបំពាក់ និងការងារថែទាំសញ្ញាជំនួយ នាវាចរណ៍ និងគ្រប់គ្រងក្រុមចំណាត់ថ្នាក់នាវា ឬអង្គការសន្តិសុខទទួលស្គាល់ ដើម្បីបំពេញការងារបច្ចេកទេស ដែលពាក់ព័ន្ធសុវត្ថិភាព សន្តិសុខ បរិស្ថាន ស្របតាមច្បាប់ជាតិ និងអន្តរជាតិផងដែរ។ សម្រាប់កិច្ចទំនាក់ទំនងអន្តរជាតិលើវិស័យកំពង់ផែ នាយកដ្ឋានមានតួនាទីក្នុងការសម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ និងបណ្តាប្រទេសពាក់ព័ន្ធនានា ដើម្បីអភិវឌ្ឍកំពង់ផែនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបនឹងការប្រកួតប្រជែងទាំងនៅក្នុងតំបន់ និងសកលលោក។ នាយកដ្ឋាន ក៏ត្រូវសហការជាមួយវិទ្យាស្ថានជាតិសាធារណការ និងដឹកជញ្ជូន ដើម្បីរៀបចំសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល វិទ្យាសាស្ត្របច្ចេកទេស បច្ចេកវិទ្យាថ្មីទំនើបពាក់ព័ន្ធនឹងទស្សនទាន និងចក្ខុវិស័យក្នុងកិច្ចអភិវឌ្ឍកំពង់ផែ ដើម្បីឱ្យវិស័យនេះកាន់តែមានភាពឆ្លើយតបនឹងតម្រូវការសង្គមជាក់ស្តែង។

បន្ថែមពីលើនេះផងដែរ នាយកដ្ឋាន ក៏ត្រូវរៀបចំធ្វើបច្ចុប្បន្នភាពកំពង់ផែឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដោយធ្វើការប្រមូលចងក្រងស្ថិតិ និងទិន្នន័យ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកំពង់ផែ។ ជាមួយគ្នានោះ នាយកដ្ឋានរដ្ឋបាលកំពង់ផែ ត្រូវតាមដានត្រួតពិនិត្យ ណែនាំ ដឹកនាំការអនុវត្ត និងសម្របសម្រួលការអនុវត្តន៍ច្បាប់ ព្រមទាំងបទបញ្ញាផ្សេងៗ ទៅដល់ប្រតិបត្តិករផែ និងម្ចាស់ផែ ឬម្ចាស់នាវាទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការរុករក និងសង្គ្រោះនាវា សម្រាប់ត្រៀមទប់ទល់ ឆ្លើយតបនឹងករណីកំពប់ប្រេងចេញពីនាវានៅតាមផ្លូវទឹក ដើម្បីរួមចំណែកការពារបរិស្ថាន។ ក្រោយមក នាយកដ្ឋានត្រូវរៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួន តាមកាលកំណត់ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងឱ្យបានជាប្រចាំ និងត្រូវបំពេញភារកិច្ចមួយចំនួនទៀត ដែលប្រគល់ឱ្យដោយនាយឋានានុក្រមតាមការចាំបាច់។

### **១.៣.២. អំពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ**

នាយកដ្ឋានរដ្ឋបាលកំពង់ផែ ដឹកនាំដោយ ប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ជាជំនួយការ។[៩] ចំនួនជាក់លាក់នៃអនុប្រធាននាយកដ្ឋាន គឺប្រែប្រួលតាមរយៈទំហំការងារ និងតម្រូវការជាក់ស្តែងរបស់អង្គភាព ហើយអនុប្រធាននាយកដ្ឋាននីមួយៗ ត្រូវតែងតាំងឡើងដោយប្រកាសរបស់ក្រសួងផ្ទាល់។[១០] បច្ចុប្បន្នក្នុងការបំពេញការងារជាក់ស្តែង នាយកដ្ឋានរដ្ឋបាលកំពង់ផែ ត្រូវបានដឹកនាំដោយប្រធាននាយកដ្ឋាន មួយរូប និងមានអនុប្រធាននាយកដ្ឋានចំនួន ០៥រូប។ ដើម្បីសម្រួលកិច្ចការងាររបស់ខ្លួន នាយកដ្ឋានរដ្ឋបាលកំពង់ផែ

---

[៩] ប្រកាសលេខ ២៤៤ សក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ.

[១០] សាស្ត្រាចារ្យ ហៀង សាង.(២០១៨). នីតិរដ្ឋបាលសាធារណៈ. ភ្នំពេញ. បោះពុម្ពលើកទី១.

បានរៀបចំឱ្យមានការិយាល័យចំនួនប្រាំគឺ៖[១១] ការិយាល័យកិច្ចការទូទៅ, ការិយាល័យផែនការ និងនីតិកម្ម, ការិយាល័យអភិវឌ្ឍកំពង់ផែ, ការិយាល័យបច្ចេកទេស, និងការិយាល័យប្រតិបត្តិការកំពង់ផែ ដែលការិយាល័យមួយត្រូវបានទទួលបន្ទុកគ្រប់គ្រងការងារដោយអនុប្រធាននាយកដ្ឋានម្នាក់ ហើយការិយាល័យនីមួយៗ របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ ដែលអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

**១.៣.២.១. ការិយាល័យកិច្ចការទូទៅ**

ការិយាល័យកិច្ចការទូទៅ មានភារកិច្ច បំពេញការងាររដ្ឋបាលទូទៅរបស់នាយកដ្ឋានរដ្ឋបាលផ្ទាល់។ ការិយាល័យនេះ ទទួលបន្ទុកក្នុងការគ្រប់គ្រងបុគ្គលិក និងធនធានមនុស្ស គណនេយ្យ ហិរញ្ញវត្ថុ បញ្ជីសារពើភណ្ឌរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ ព្រមទាំងរៀបចំផែនការ និងព័ត៌មានវិទ្យាសម្រាប់សម្រួលដល់ការងាររបស់នាយកដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព។ ក្រៅពីនេះ ការិយាល័យក៏មានភារកិច្ច រៀបចំការងារបណ្តុះបណ្តាលមន្ត្រីផ្ទៃក្នុងនាយកដ្ឋានផងដែរ។[១២]

ការិយាល័យកិច្ចការទូទៅ ធ្វើការគ្រប់គ្រង និងរៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ច ឬបេសកកម្មជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់នាយកដ្ឋានសម្រាប់ការចុះបំពេញការងារនៅក្រៅអង្គភាព។ បន្ទាប់មក ការិយាល័យកិច្ចការទូទៅ ត្រូវចាត់ចែងចម្លងរាល់លិខិតបញ្ជាបេសកកម្មទាំងក្នុង និងក្រៅប្រទេសរបស់មន្ត្រី នៅក្នុងនាយកដ្ឋានដែលបានចាត់ឱ្យទៅបំពេញបេសកកម្មនានាជូនទៅនាយកដ្ឋានបុគ្គលិកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។

ក្នុងការគ្រប់គ្រងកំពង់ផែ ការិយាល័យកិច្ចការទូទៅ មានភារកិច្ចសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលអំពីការគ្រប់គ្រងកំពង់ផែ ជូនដល់ប្រតិបត្តិករផែ ព្រមទាំងសហការជាមួយនឹងការិយាល័យផ្សេងទៀត ក្នុងការរៀបចំចងក្រងស្ថិតិ និងទិន្នន័យដែលពាក់ព័ន្ធ សម្រាប់ធ្វើបច្ចុប្បន្នភាពអំពីកំពង់ផែនៅកម្ពុជា។ ការិយាល័យកិច្ចការទូទៅ ជាអ្នកប្រមូលចំណូលពីការផ្តល់សេវាផ្សេងៗ បង់ចូលថវិកាជាតិ ព្រមទាំងទំនាក់ទំនង និងសម្របសម្រួលការងារជាមួយស្ថាប័នជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនឹងវិស័យកំពង់ផែនៅកម្ពុជា។

ការិយាល័យត្រូវរាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំនាយកដ្ឋានអំពី សកម្មភាពការងាររបស់ការិយាល័យ និងបូកសរុបរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនថ្នាក់អគ្គនាយកដ្ឋានរបស់ខ្លួន ដើម្បីធ្វើការពិនិត្យនិងវាយតម្លៃ ព្រមទាំងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

---

[១១] ប្រការ២ នៃ ប្រកាសលេខ ២៤៤ សក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ.

[១២] ប្រការ៤ នៃ ប្រកាសលេខ ២៤៤ សក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ.

### ១.៣.២.២. ការិយាល័យផែនការ និងនីតិកម្ម

ការិយាល័យផែនការ និងនីតិកម្ម មានភារកិច្ចរៀបចំផែនការ គោលនយោបាយ ច្បាប់និងបទបញ្ញាគ្រប់គ្រងកំពង់ផែ សម្រាប់នាយកដ្ឋានរដ្ឋបាលកំពង់ផែ និងធ្វើការសិក្សាស្រាវជ្រាវ រៀបចំកម្មវិធីតាមដានការអនុវត្តគោលនយោបាយ ដើម្បីបង្កើនសមត្ថភាពកំពង់ផែ និងបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុននាវាចរណ៍ ម្ចាស់ទំនិញ និងអ្នកប្រើប្រាស់កំពង់ផែទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រៅពីនេះ ការិយាល័យនេះក៏រួមចំណែកជាមួយនឹងការិយាល័យផ្សេងទៀតនៃនាយកដ្ឋានរដ្ឋបាលកំពង់ផែ ដើម្បីប្រមូល ចងក្រង គ្រប់គ្រងស្ថិតិ និងទិន្នន័យដែលពាក់ព័ន្ធសម្រាប់ធ្វើបច្ចុប្បន្នភាពកំពង់ផែ។ ការិយាល័យនេះ មានភារកិច្ចជាអ្នកកសាផែនការមេស្តីពីការអភិវឌ្ឍកំពង់ផែ ដើម្បីសម្រួលដល់គម្រោងការអភិវឌ្ឍកំពង់ផែនៅតាមផ្លូវទន្លេ ផ្លូវសមុទ្រ និងផែស្ងួត ដោយជម្រុញឱ្យប្រតិបត្តិករផែ និងម្ចាស់ផែទាំងអស់ឱ្យបំពាក់ឧបករណ៍ សម្ភារៈ និងបរិក្ខារ ដែលមានលក្ខណៈបច្ចេកទេសទំនើប សំដៅជួយឱ្យមានប្រតិបត្តិការដោយរលូន មានប្រសិទ្ធិភាពខ្ពស់ មិនប៉ះពាល់ដល់បរិស្ថាន និងជំរុញលើកទឹកចិត្តការធ្វើទំនើបកម្មវិស័យព័ត៌មានវិទ្យា និងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ សម្រាប់គ្រប់គ្រងប្រតិបត្តិការផ្សេងៗនៅតាមកំពង់ផែរបស់ខ្លួនផងដែរ។[១៣] ព្រមជាមួយគ្នានោះ ការិយាល័យផែនការ និងនីតិកម្មរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ ក៏មានភារកិច្ចជំរុញឱ្យមានការប្រកួតប្រជែងដោយឈរលើគោលការណ៍សមធម៌ ស្មោះត្រង់ និងមានតម្លាភាព តាមរយៈការផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យមានការវិនិយោគពីផ្នែកឯកជនលើការអភិវឌ្ឍកំពង់ផែ និងសេវាកម្មកំពង់ផែយ៉ាងទូលំទូលាយ ទៅកាន់សាធារណៈជន។ ការិយាល័យនេះ ត្រូវរាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំនាយកដ្ឋាន អំពីសកម្មភាពការងាររបស់ការិយាល័យខ្លួន និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

### ១.៣.២.៣. ការិយាល័យអភិវឌ្ឍកំពង់ផែ

ការិយាល័យអភិវឌ្ឍកំពង់ផែ មានភារកិច្ចផ្សព្វផ្សាយគោលនយោបាយ យុទ្ធសាស្ត្រ ផែនកាសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តដល់ប្រតិបត្តិករកំពង់ផែ និងអ្នកប្រើប្រាស់កំពង់ផែ ព្រមទាំងរៀបចំសំណុំឯកសារសម្រាប់ផ្តល់ការអនុញ្ញាតផែនការកម្មកំពង់ផែ ការសាងសង់ និងសំណើសុំអភិវឌ្ឍឋបនីយកណ្ឌផ្សេងទៀត ព្រមទាំងសេវាពាក់ព័ន្ធនានា។[១៤] ការិយាល័យអភិវឌ្ឍកំពង់ផែ ក៏មានភារកិច្ចក្នុងការគ្រប់គ្រង និងចងក្រងលើថ្លៃសេវាកម្មប្រតិបត្តិការកំពង់ផែ កម្រៃប្រើប្រាស់សេវាផ្សេងៗ និងស្ថិតិសកម្មភាពទំនិញឆ្លងកាត់នៅគ្រប់កំពង់ផែទាំងអស់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យនាយកដ្ឋានមានភាពងាយស្រួល និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការតាមដានពីសកម្មភាពប្រកបអាជីវកម្មផែរបស់កំពង់ផែទាំងនោះ ឱ្យត្រឹមត្រូវតាមកម្មវត្ថុដែលខ្លួន

---

[១៣] ប្រការ៥ នៃ ប្រកាសលេខ ២៤៤ សក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ.

[១៤] ប្រការ៧ នៃ ប្រកាសលេខ ២៤៤ សក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ.

បានស្នើសុំ។ ក្រៅពីនេះ ការិយាល័យអភិវឌ្ឍកំពង់ផែ ក៏មានតួនាទីក្នុងការប្រមូល ចងក្រង គ្រប់គ្រងស្ថិតិ និងទិន្នន័យដែលពាក់ព័ន្ធនឹងកំពង់ផែនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន រួចត្រូវធ្វើការរាយការណ៍ជាប្រចាំ ជូនដល់ថ្នាក់ដឹកនាំនាយកដ្ឋានត្រួតពិនិត្យ។

**១.៣.២.៤. ការិយាល័យបច្ចេកទេស**

ការិយាល័យបច្ចេកទេស មានភារកិច្ចរៀបចំគោលការណ៍ណែនាំ ដើម្បីធានាសុវត្ថិភាពក្នុងការសាងសង់ និងប្រតិបត្តិកំពង់ផែ ដូចជា៖ ការរៀបចំប្លង់ ការសាងសង់ ការធ្វើប្រតិបត្តិការកំពង់ផែ ការគ្រប់គ្រង និងចាត់ចែងចលនានាវានៅកំពង់ផែ សន្តិសុខកំពង់ផែ និងការងារពាក់ព័ន្ធផ្សេងៗទៀត។[១៥] ការិយាល័យមានតួនាទីជាចាំបាច់ក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក សម្រាប់នាវាចរណ៍ដូចជា ការបំពាក់ និងការងារថែទាំសញ្ញាជំនួយនាវាចរណ៍នៅក្នុងតំបន់កំពង់ផែ ដើម្បីធានាសុវត្ថិភាពជូនដល់នាវាដែលចូលចត។ ការិយាល័យនេះ ត្រូវគ្រប់គ្រងរាល់ក្រុមចំណាត់ថ្នាក់កំពង់ផែ ឬអង្គការសន្តិសុខទទួលស្គាល់ដើម្បីបំពេញការងារបច្ចេកទេសដែលពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ បរិស្ថាននៃកំពង់ផែឱ្យស្របតាមច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងតាមដាន វាយតម្លៃ និងផ្តល់យោបល់លើការធ្វើទំនើបកម្មឋបនីយកណ្ឌផែ ធានាដល់ការរក្សាសុវត្ថិភាពប្រតិបត្តិការកំពង់ផែ។

ចំពោះការចូលរួមអភិវឌ្ឍកំពង់ផែ ការិយាល័យមានភារកិច្ចសម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ រួមទាំងបណ្តាប្រទេសដែលជាដៃគូអភិវឌ្ឍន៍នានា ដើម្បីសិក្សាពីធាតុចូលសំខាន់ៗ ដែលចាំបាច់សម្រាប់ប្រើប្រាស់លើការគ្រប់គ្រងវិស័យកំពង់ផែនៅកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព។ ការិយាល័យ ត្រូវសហការជាមួយវិទ្យាស្ថានជាតិសាធារណការ និងដឹកជញ្ជូន ដើម្បីរៀបចំសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល មន្ត្រីរបស់ខ្លួនអំពីវិទ្យាសាស្ត្របច្ចេកទេស បច្ចេកវិទ្យាថ្មីទំនើបពាក់ព័ន្ធនឹងទស្សនទាន និងចក្ខុវិស័យក្នុងកិច្ចអភិវឌ្ឍន៍កំពង់ផែនៅកម្ពុជា។ ក្រៅពីនេះ ការិយាល័យបច្ចេកទេស ក៏ត្រូវចូលរួមជាមួយនឹងការិយាល័យដទៃទៀតដើម្បីប្រមូល ចងក្រង គ្រប់គ្រងស្ថិតិ និងទិន្នន័យដែលពាក់ព័ន្ធនឹងកំពង់ផែនៅកម្ពុជា ហើយត្រូវធ្វើរបាយការណ៍ជាប្រចាំ ដាក់ជូនថ្នាក់ដឹកនាំនាយកដ្ឋានដើម្បីធ្វើការត្រួតពិនិត្យ។

**១.៣.២.៥ ការិយាល័យប្រតិបត្តិការកំពង់ផែ**

ការិយាល័យប្រតិបត្តិការកំពង់ផែ មានភារកិច្ចរៀបចំសំណុំឯកសារពាក់ព័ន្ធនានា សម្រាប់ផ្តល់ការអនុញ្ញាតប្រតិបត្តិការកំពង់ផែ និងសំណើសុំប្រតិបត្តិការផ្សេងទៀត។[១៦] ការិយាល័យនេះ ជាការិយាល័យដែលទទួលបន្ទុកផ្ទាល់លើការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ សម្រាប់គ្រប់កំពង់ផែទាំងអស់នៅកម្ពុជា

[១៥] ប្រការ៦ នៃ ប្រកាសលេខ ២៨៤ សក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ.

[១៦] ប្រការ៨ នៃ ប្រកាសលេខ ២៨៤ សក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ.

ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន លើកលែងតែកំពង់ផែស្វយ័តធំៗទាំងពីររួមមាន៖ កំពង់ផែស្វយ័តក្រុងភ្នំពេញ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ ព្រមជាមួយគ្នានេះ ការិយាល័យត្រូវអនុវត្តការត្រួតពិនិត្យ តាមដាន ណែនាំ និងសម្របសម្រួលការអនុវត្តផែនការ គោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗដែលពាក់ព័ន្ធនឹងកំពង់ផែ ទៅកាន់ម្ចាស់ផែ និងប្រតិបត្តិករផែទាំងនោះ។ អង្គភាពនេះ ជាអ្នកណែនាំ និងជំរុញការប្រើប្រាស់កណ្ដាធារ ដើម្បីធានាសុវត្ថិភាពក្នុងពេលធ្វើចលនាចរនាវាចូល-ចេញផែ ដោយជំរុញការរៀបចំផែនការ អនុវត្តវិធានការសន្តិសុខកំពង់ផែ/សន្តិសុខបរិយកណ្ឌផែ។ ការិយាល័យប្រតិបត្តិការកំពង់ផែ ត្រូវជំរុញនិងលើកកម្ពស់កំពង់ផែ ឱ្យមានសមត្ថភាពរុករក និងសង្គ្រោះនាវា ព្រមទាំងការត្រៀម និងការឆ្លើយតបនឹងករណីប្រេងកំពប់ដែលកើតឡើងនៅក្នុងដែនទឹកកំពង់ផែរបស់ខ្លួន និងអនុវត្តវិធានការបង្ការសម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ន ដូចជាអគ្គិភ័យ និងការបំពុលបរិស្ថានសមុទ្រជាដើម។ ក្នុងកិច្ចការនេះ ការិយាល័យ ត្រូវចូលរួមសហការជាមួយគ្រប់អង្គភាពពាក់ព័ន្ធនានាដើម្បីតាមដាន និងវាយតម្លៃរាល់ការអនុវត្តតាមបទបញ្ញា និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការបញ្ចេញកាកសំណល់ពីនាវា ការបំពុលទឹក និងបរិយាកាសនៅក្នុងកំពង់ផែ។

ដើម្បីធានានូវការប្រកួតប្រជែងដោយស្មើភាព ការិយាល័យប្រតិបត្តិការកំពង់ផែ ត្រូវសិក្សាចងក្រងកម្រៃសេវាកម្មផ្សេងៗក្នុងប្រតិបត្តិការកំពង់ផែ រួចរៀបចំជាតារាងតម្លៃ សម្រាប់កំណត់តម្លៃរួមមួយ ដែលគ្រប់ម្ចាស់ផែទាំងអស់អាចទទួលយកបាន ព្រមទាំងប្រមូលចងក្រងស្ថិតិនាវា ទំនិញ អ្នកដំណើរ និងទិន្នន័យដែលពាក់ព័ន្ធផ្សេងៗទៀត ដើម្បីងាយស្រួលក្នុងការវាយតម្លៃអំពីដំណើរការធ្វើអាជីវកម្មកំពង់ផែនីមួយៗ រួចរាយការណ៍ជាប្រចាំទៅកាន់ថ្នាក់ដឹកនាំនាយកដ្ឋាន។ ការិយាល័យប្រតិបត្តិការកំពង់ផែ សហការជាមួយនឹងការិយាល័យផ្សេងទៀតដើម្បីធ្វើបច្ចុប្បន្នភាពកំពង់ផែទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យបានទៀងទាត់ផងដែរ។

# ជំពូកទី២
# ក្របខណ្ឌនៃការផ្ដល់សេវា
# លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ

# ជំពូកទី២
# ក្របខណ្ឌនៃសេវាចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ

រាជរដ្ឋាភិបាលកម្ពុជាបានមើលឃើញថាការកែលម្អនៃការផ្តត់ផ្គង់សេវាកម្ម គឺជាផ្នែកមួយនៃអាទិភាពគន្លឹះរបស់កម្ពុជា។ ក្នុងនោះ ការផ្តល់សេវាលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ ជាចំណែកមួយក្នុងចំណោមសេវាដទៃទៀត ដែលចូលរួមក្នុងការអភិវឌ្ឍវិស័យសេវាសាធារណៈនៅកម្ពុជា ក្នុងន័យពង្រឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសគឺការគ្រប់គ្រងបានល្អនូវសកម្មភាពធ្វើពាណិជ្ជកម្មតាមផ្លូវទឹករបស់កម្ពុជាឱ្យកាន់តែមានភាពល្អប្រសើរឡើង។ តើអ្វីជាលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ? ហេតុអ្វីចាំបាច់ត្រូវមានលិខិតនេះ មុននឹងដំណើរការអាជីវកម្មផែបាន? ចម្លើយទាំងអស់នេះ យើងខ្ញុំនឹងធ្វើការបកស្រាយលើចំណុចដូចតទៅ៖

## ២.១. ទិដ្ឋភាពទូទៅនៃកំពង់ផែ

នៅកម្ពុជាមានកំពង់ផែជាច្រើនកំពុងដំណើរការអាជីវកម្មរបស់ខ្លួន។ កំពង់ផែនីមួយៗ ផ្តល់សេវាខុសៗគ្នាអាស្រ័យលើសមត្ថភាព និងគោលបំណងរបស់កំពង់ផែ។ ដើម្បីធ្វើការសិក្សាឱ្យកាន់តែស៊ីជម្រៅថែមទៀត នៅក្នុងផ្នែកនេះយើងនឹងធ្វើការបង្ហាញពីសញ្ញាណទូទៅរបស់កំពង់ផែ(២.១.១) ទិន្នន័យ និងប្រភេទកំពង់ផែនៅកម្ពុជា(២.១.២) និងលក្ខខណ្ឌចាំបាច់ដើម្បីអាចប្រកបអាជីវកម្មផែនៅកម្ពុជាបាន(២.១.៣)។

### ២.១.១. សញ្ញាណទូទៅរបស់កំពង់ផែ

កំពង់ផែ សំដៅដល់តំបន់ដែលមានដែនទឹក និងដែនគោកជាក់លាក់ ព្រមទាំងមានឋបនីយភណ្ឌផែ សម្រាប់បម្រើឱ្យនាវាចេញ-ចូល បោះយុថ្កា និងចតដើម្បីផ្ទេរផ្ទុក រក្សាទុកទំនិញ និងផ្ទេរផ្ទុកអ្នកដំណើរបាន។[១៧] តួនាទីរបស់កំពង់ផែ គឺសម្រាប់ផ្តល់សេវាដល់អ្នកប្រើប្រាស់ដូចជា សេវាកណ្តូធារកិច្ចនាំនាវាចេញ-ចូល ចំណតនាវា ឬទីតាំងសម្រាប់នាវាធ្វើការជួសជុល និងចាក់ប្រេង។ កំពង់ផែ ក៏ជាចំណតសម្រាប់លើកដាក់ ផ្ទេរផ្ទុក រក្សាទុកទំនិញ សេវាអូស-ទាញនាវាពាក់និងដោះពួរ សេវាផ៍-ច្រកទំនិញដាក់កុងតឺន័រ និងសេវាជួសជុល ថែទាំសំបកកុងតឺន័រ ដើម្បីឱ្យអ្នកប្រើប្រាស់មានទំនុកចិត្ត លក្ខណៈងាយស្រួល ទទួលសេវាបានឆាប់រហ័ស តម្លៃសមរម្យ។ ជាមួយគ្នានេះ កំពង់ផែជាកន្លែងដែលមានសន្តិសុខ និងសុវត្ថិភាពដល់នាវា ទំនិញ និងអ្នកដំណើរផងដែរ។ ចំពោះតម្លៃក្នុងការដឹកជញ្ជូនតាមនាវា គឺចំណាយថ្លៃដើមតិច បើធៀបនឹងការដឹកជញ្ជូនតាមផ្លូវគោកដែលប្រើប្រាស់ដោយរថយន្ត។ ក្នុងនោះយើងសង្កេតឃើញថា ប្រេង១លីត្រ ដឹកដោយរថយន្តបានចំនួន២៤តោនក្នុង១គីឡូម៉ែត្រប៉ុណ្ណោះ ប៉ុន្តែប្រសិនបើដឹកតាមនាវាវិញគឺបានរហូតដល់ ១០៥តោន ក្នុង ១គីឡូម៉ែត្រ ដូចគ្នា។[១៨] ជំនួសឱ្យការដឹកជញ្ជូនតាមរយៈផ្លូវថ្នល់ ការដឹក

[១៧] មាត្រា៤ នៃសេចក្តីព្រាងច្បាប់ស្តីពីកំពង់ផែ ឆ្នាំ២០២០.

[១៨] លោក ញាណ សុកុល, (២០១៦).កិច្ចពិភាក្សា ក្រោមប្រធានបទ "ការអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវទឹក". កម្មវិធីទំនើបភាវូបនីយកម្មខ្មែរ នៃប៉ុស្តិ៍ទូរទស្សន៍ទស្សន៍ជាតិកម្ពុជា. ដកស្រង់ពី: https://www.youtube.com/watch?v=fjVwjoD6GHI.

ដឹកជញ្ជូនតាមផ្លូវទឹក គឺជាមធ្យោបាយមួយ ដែលរាជរដ្ឋាភិបាលបាននឹងកំពុងលើកទឹកចិត្តឱ្យមានការប្រើប្រាស់កាន់តែទូលំទូលាយ ដើម្បីរួមចំណែកកាត់បន្ថយការកកស្ទះចរាចរណ៍ និងការខូចខាតផ្លូវថ្នល់ ដោយសារការផ្ទុកទំនិញលើសទម្ងន់កំណត់។ ក្នុងនោះដែរ កំពង់ផែជាផ្នែកមួយមានសារៈសំខាន់ បានរួមចំណែកក្នុងការលើកស្ទួយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងសម្រួលដល់ការដឹកជញ្ជូននិងចរាចរទំនិញ អ្នកដំណើរ សម្រាប់បម្រើឱ្យវិស័យពាណិជ្ជកម្ម កសិកម្ម ឧស្សាហកម្ម និងទេសចរណ៍ ព្រមទាំងផ្តល់ឱកាសដល់អ្នកវិនិយោគទុនជាតិនិងអន្តរជាតិ។ ប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវទឹក បានផ្តល់ការងារជាច្រើន និងជួយសម្រួលដល់ការរស់នៅរបស់ប្រជាជនតាមផ្លូវទឹកជាអាទិ៍ ទន្លេ ស្ទឹង បឹង ព្រែក ប្រឡាយ និងឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា។

អនុលោមតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ គោលនយោបាយជាតិស្តីពីកំពង់ផែនិងប្រព័ន្ធគ្រប់គ្រងកំពង់ផែ ព្រមទាំងឯកសារអន្តរជាតិពាក់ព័ន្ធនានា និងដើម្បីឆ្លើយតបទៅនឹងបញ្ហានានា រាជរដ្ឋាភិបាលបានរៀបចំច្បាប់ស្តីពីកំពង់ផែ ដើម្បីចូលរួមចំណែកជំរុញអភិវឌ្ឍន៍កំពង់ផែ និងការគ្រប់គ្រងប្រកបដោយចីរភាព មានទំនុកចិត្តពីអ្នកប្រើប្រាស់ និងអាចចូលរួមប្រកួតប្រជែងជាមួយកំពង់ផែនានានៅក្នុងតំបន់ រួមចំណែកដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិ និងពាណិជ្ជកម្មអន្តរជាតិ។

## ២.១.២.អំពីនិន្នន័យ និងប្រភេទកំពង់ផែនៅកម្ពុជា

### ២.១.២.១. អំពីនិន្នន័យកំពង់ផែនៅកម្ពុជា

ក្នុងបរិការណ៍នៃដំណើរសកលភាវូបនីយកម្មនាពេលបច្ចុប្បន្ននេះ កំពង់ផែបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកជញ្ជូនតាមផ្លូវទឹក ដើម្បីធានាជម្រុញឱ្យកម្ពុជារក្សាបាននូវភាពធននៃកំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី កំពង់ផែទាំងអស់មិនមែនសុទ្ធតែស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូននោះឡើយ ពោលគឺមានកំពង់ផែមួយចំនួនត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័នផ្សេងទៀត។ ជាក់ស្តែង ចំណតផែស្វយ័តឫស្សីកែវ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ចំណតផែអ្នកដំណើរទៅកាន់ក្រុងតាខ្មៅ ស្ថិតក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញ កំពង់ផែទេសចរណ៍អន្តរជាតិកំពត ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ជាដើម។[១៩] យើងសង្កេតឃើញថា បច្ចុប្បន្នកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រងដោយតួអង្គចំនួន៥ រួមមាន៖ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងទេសចរណ៍ ក្រសួងពាណិជ្ជកម្ម សាលារាជធានីភ្នំពេញ និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត និងសាលាខេត្ត។ ក្នុងនោះ កំពង់ផែ ចំណតផែ ដែលនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូនក្នុងឆ្នាំ២០១៩នេះ មានចំនួន៦៧ ដែលមានទីតាំងស្ថិតតាមទន្លេមានចំនួន៥២ និងតាមសមុទ្រមានចំនួន១៥។

[១៩] នាយកដ្ឋានរដ្ឋបាលកំពង់ផែ.(២០២០). តារាងស្ថិតិកំពង់ផែ ចំណតផែនៅតាមផ្លូវទឹក និងឆ្នេរសមុទ្រក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០.ភ្នំពេញ.

កំពង់ផែនៅក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញ មានចំនួន០១ ស្ថិតនៅតាមដងទន្លេមេគង្គ។ ក្រៅពីនេះ កំពង់ផែដែលនៅក្រោមការគ្រប់គ្រងរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត និងសាលាខេត្ត មានចំនួន ៣២ ដែលស្ថិតនៅតាមទន្លេមានចំនួន២២ និងនៅតាមសមុទ្រមានចំនួន១០។ ចំណែកឯកំពង់ផែ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ មានចំនួន០១ គឺមានទីតាំងនៅតាមដងទន្លេមេគង្គ និងចំណតផែនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម មានចំនួន០២ ដែលស្ថិតនៅតាមដងទន្លេមេគង្គផងដែរ។[២០]

**២.១.២.២. អំពីប្រភេទកំពង់ផែនៅកម្ពុជា**

ផ្អែកតាមមុខងារ កំពង់ផែត្រូវបានបែងចែកជាកំពង់ផែពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ និងផែប្រេងដោយឡែក ប្រសិនបើផ្អែកលើភាពជាម្ចាស់ កំពង់ផែត្រូវបានបែងចែកជាកំពង់ផែរដ្ឋ និងកំពង់ផែឯកជន។ ទោះជាយ៉ាងនេះក្តី កំពង់ផែត្រូវបានរៀបចំជាប្រភេទថ្នាក់គឺទី១ ទី២ ទី៣ និងថ្នាក់ពិសេស។[២១]

**ក. កំពង់ផែប្រភេទថ្នាក់ទី១**

សំដៅដល់កំពង់ផែដែលបម្រើសេវា ឱ្យនាវាអាចធ្វើនាវាចរណ៍បានជាលក្ខណៈអន្តរជាតិ។ កំពង់ផែដែលស្ថិតនៅក្នុងចំណាត់ថ្នាក់នេះ ជាកំពង់ផែដែលសំខាន់ជាពិសេសសម្រាប់ពាណិជ្ជកម្ម និងទំនាក់ទំនងអន្តរជាតិមានវិសាលភាពគ្របដណ្តប់ទូលំទូលាយ សម្រាប់បម្រើដល់កិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចរបស់ជាតិទាំងមូល។ បច្ចុប្បន្នកំពង់ផែប្រភេទទី១នេះ បាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ គឺមិនត្រឹមតែសម្រាប់ពង្រឹងវិស័យសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានផ្សារភ្ជាប់កម្ពុជាទៅកាន់ពិភពលោកផងដែរ។ ជាក់ស្តែង កំពង់ផែស្វយ័តក្រុងព្រះសីហនុដែលកំពុងធ្វើប្រតិបត្តិការរបស់ខ្លួនយ៉ាងមមារញឹក ក្នុងការបំពេញនូវភារកិច្ចរបស់ខ្លួន ដែលអាចជួយគាំទ្រឱ្យកម្ពុជាទទួលបានភាពធននៃកំណើនសេដ្ឋកិច្ចរៀងរាល់ឆ្នាំ។

**ខ. កំពង់ផែប្រភេទថ្នាក់ទី២**

សំដៅដល់កំពង់ផែដែលបម្រើសេវាឱ្យនាវាអាចធ្វើនាវាចរណ៍ជាលក្ខណៈទ្វេភាគី ឬត្រីភាគីជាមួយប្រទេសជិតខាងបាន។ កំពង់ផែដែលស្ថិតនៅក្នុងថ្នាក់នេះ ជាកំពង់ផែដែលសំខាន់ ជាពិសេសសម្រាប់ពាណិជ្ជកម្មអន្តរជាតិរវាងកម្ពុជា ជាមួយនឹងប្រទេសជិតខាង ឬក្នុងតំបន់ ដើម្បីផ្សារភ្ជាប់សេវាកម្មដឹកជញ្ជូនផង និងការធ្វើទំនាក់ទំនងផង ដូចជាកំពង់ផែស្វយ័តក្រុងភ្នំពេញ ដែលបានបំពេញមុខងារគាំពារដល់វិស័យពាណិជ្ជកម្មរបស់កម្ពុជាឱ្យកាន់តែខ្លាំងក្លារឹងមាំឡើង។

---

[២០] នាយកដ្ឋានរដ្ឋបាលកំពង់ផែ.(២០២០). របាយការណ៍ស្តីពីការចុះធ្វើបច្ចុប្បន្នភាព ស្រង់ស្ថិតិ និងចុះផ្សព្វផ្សាយណែនាំដល់កំពង់ផែចំណតផែ ដែលពុំទាន់មានលិខិតអនុញ្ញាតធ្វើ ប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា.ភ្នំពេញ.

[២១] មាត្រា៧ នៃសេចក្តីព្រាងច្បាប់ស្តីពីកំពង់ផែ ឆ្នាំ២០២០.

**គ. កំពង់ផែប្រភេទថ្នាក់ទី៣**

សំដៅដល់កំពង់ផែដែលបម្រើសេវានាវាចរណ៍បានតែនៅក្នុងប្រទេសកម្ពុជា ពោលគឺជាកំពង់ផែនៅតាមមូលដ្ឋានដែលមានទំហំតូចៗ បម្រើដល់ការដឹកជញ្ជូនតាមនាវាផ្លូវសមុទ្រ ឬផ្លូវទន្លេ ឬដែលគេប្រើសម្រាប់តែសកម្មភាពសហគ្រាសណាមួយជាក់លាក់។ សព្វថ្ងៃកំពង់ផែប្រភេទនេះ ត្រូវបានរាជរដ្ឋាភិបាលលើកទឹកចិត្តដល់ក្រុមហ៊ុនវិនិយោគជាតិ និងអន្តរជាតិធ្វើការបង្កើតជាឯកជនរបស់ខ្លួន ដើម្បីគាំទ្រដល់ដំណើរសង្វាក់ផលិតកម្ម និងការធ្វើអាជីវកម្មផ្សេងទៀតព្រមទាំងជម្រុញឱ្យក្រុមហ៊ុនធំៗ ធ្វើការសាងសង់នូវកំពង់ផែឯកជនផ្ទាល់ខ្លួនដើម្បីជួយជម្រុញការវិនិយោគលើវិស័យកសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្ម ពាណិជ្ជកម្មជាដើម។

**ឃ. កំពង់ផែប្រភេទថ្នាក់ពិសេស**

សំដៅដល់កំពង់ផែក្រៅពីថ្នាក់ទី១ ថ្នាក់ទី២ និងថ្នាក់ទី៣ ដែលប្រើប្រាស់សម្រាប់តែប្រភេទទំនិញជាក់លាក់មួយគត់។ កំពង់ផែប្រភេទនេះ ត្រូវបានបង្កើតឡើងដោយមានគោលបំណងបំពេញនូវឯកទេសកម្មតែមួយគត់របស់ខ្លួន ដូចជាកំពង់ផែនេសាទ ដែលបើកបម្រើសម្រាប់តែនាវានេសាទចូលមកចងព្យួរ បោះយុថ្កា លើកដាក់ទំនិញ ផ្ទេរ ផ្ទុក សំចត ជួសជុល និងធ្វើសកម្មភាពផ្សេងៗពាក់ព័ន្ធនឹងការនេសាទប៉ុណ្ណោះ។ ក្រៅពីនេះក៏មានកំពង់ផែទេសចរណ៍ សម្រាប់តែការដឹកជញ្ជូនអ្នកដំណើរកំសាន្ត និងកំពង់ផែប្រេងដែលប្រើសម្រាប់តែការដឹកជញ្ជូនប្រេងឥន្ធនៈជាដើម។

### ២.១.៣. លក្ខខណ្ឌដើម្បីប្រកបអាជីវកម្មក្នុងវិស័យកំពង់ផែ

គ្រប់នីតិបុគ្គលទាំងឡាយដែលមានបំណងចង់ប្រកបអាជីវកម្មផែរបស់ខ្លួនបាន ចាំបាច់ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតចំនួន៣សំខាន់ៗ ពីក្រសួងសាធារណការនិងដឹកជញ្ជូនដូចជាៈ លិខិតវាយតម្លៃផែនការកម្មកំពង់ផែ ឬលិខិតអនុញ្ញាតបង្កើតកំពង់ផែ លិខិតអនុញ្ញាតសាងសង់កំពង់ផែ និងលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ។ ប៉ុន្តែដោយមើលឃើញថា មានកំពង់ផែមួយចំនួនបានធ្វើការសាងសង់ និងដំណើរការអាជីវកម្មរួចហើយ ពោលគឺបានប្រកបអាជីវកម្មកំពង់ផែរបស់ខ្លួន តាំងពីមុនពេលដែលនាយកដ្ឋានរដ្ឋបាលកំពង់ផែត្រូវបានបង្កើតឡើង ហេតុនេះកំពង់ផែទាំងនោះគ្រាន់តែមកធ្វើការស្នើសុំលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែតែប៉ុណ្ណោះ។

ដើម្បីឱ្យការបកស្រាយលើប្រធានបទស្តីពី **"ការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ"** ឱ្យកាន់តែមានភាពស៊ីជម្រៅ យើងត្រូវឈ្វេងយល់ជាបឋមអំពី លិខិតវាយតម្លៃផែនការកម្មកំពង់ផែ និងលិខិតអនុញ្ញាតសាងសង់កំពង់ផែជាមុនសិន។

#### ២.១.៣.១. លិខិតវាយតម្លៃផែនការកម្មកំពង់ផែ ឬលិខិតអនុញ្ញាតបង្កើតកំពង់ផែ

ការវាយតម្លៃផែនការកម្មកំពង់ផែ គឺសំដៅដល់ការវាយតម្លៃជាមូលដ្ឋាន ដើម្បីសម្រេចថា តើអាចអនុញ្ញាតឱ្យក្រុមហ៊ុនមួយអាចបង្កើត និងដំណើរការអាជីវកម្មរបស់ខ្លួននៅលើទីតាំងដែលខ្លួនបានស្នើសុំដែរឬទេ។ អង្គភាព

គ្រប់គ្រងកំពង់ផែនៃក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំផែនការមេស្តីពីកំពង់ផែសម្រាប់ជាមូលដ្ឋានក្នុងការកំណត់តំបន់អភិវឌ្ឍន៍កំពង់ផែ មុខងារ និងសមត្ថភាពកំពង់ផែ ដើម្បីបំពេញនូវសេចក្តីត្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ លិខិតវាយតម្លៃផែនការកម្មកំពង់ផែ ជាលិខិតមួយសម្រាប់ចេញជូនដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានរៀបចំគម្រោងការកសាងកំពង់ផែ ហើយស្នើឡើងដោយស្របតាមលក្ខណៈវិនិច្ឆ័យដូចមានកំណត់ក្នុងប្រកាសដោយឡែក របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។[២២]

ក្នុងការស្នើសុំលិខិតនេះ ចាំបាច់ត្រូវមានឯកសារដូចជា៖ ពាក្យស្នើសុំ ចំនួន មួយច្បាប់, លិខិតចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន ចំនួន មួយច្បាប់ ដើម្បីបញ្ជាក់ពីភាពស្របច្បាប់របស់ក្រុមហ៊ុន។ ក្រុមហ៊ុន ឬម្ចាស់ផែ ត្រូវភ្ជាប់មកនូវប្លង់កំពង់ផែ មួយច្បាប់ ដើម្បីបញ្ជាក់ពីភូមិសាស្ត្រ និងទីតាំងទូទៅរបស់កំពង់ផែដែលស្នើសុំផងដែរ។ បន្ថែមពីលើនោះ កំពង់ផែដែលបានស្នើសុំ ត្រូវមានគោលការណ៍បង្កើតផែច្បាស់លាស់ដែលបង្ហាញពីកម្មវត្ថុ និងតួនាទីរបស់កំពង់ផែដែលនឹងត្រូវបង្កើត(ជាកំពង់ផែពហុបំណង, កំពង់ផែសម្រាប់ដឹករូបធាតុដើមកសិកម្ម, ឬកំពង់ផែសម្រាប់ដឹកប្រេង។ល។) និងមានភ្ជាប់ជាមួយនូវ ប្លង់កម្មសិទ្ធិដីធ្លី ដើម្បីបញ្ជាក់ពីភាពជាឯកជនរបស់កំពង់ផែ សម្រាប់ងាយស្រួលក្នុងការចាត់វិធានការគ្រប់គ្រងកំពង់ផែដែលស្នើសុំទាំងនោះ។[២៣]

ក្រៅពីនេះ អ្នកស្នើសុំក៏ត្រូវភ្ជាប់ជាមួយនឹងពាក្យស្នើសុំនូវរង្វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាថាកំពង់ផែដែលបានស្នើសុំ គឺមិនប៉ះពាល់ដល់សន្តិសុខបរិស្ថានដែលនៅជុំវិញ។[២៤] ក្នុងដំណើរការផ្តល់លិខិតនេះ ក្រសួងសាធារណការនិងដឹកជញ្ជូនប្រើប្រាស់រយៈពេល ៣០ថ្ងៃ សម្រាប់នីតិវិធីនៃការចេញលិខិត គិតចាប់ពីថ្ងៃស្នើសុំ ហើយក្រុមហ៊ុនត្រូវបង់ប្រាក់ថ្លៃសេវាចំនួន ៥,០០០,០០០ រៀល ដែលលិខិតមានសុពលភាពអចិន្ត្រៃយ៍ ។[២៥] ក្រសួងសាធារណការ និងដឹកជញ្ជូន មានសិទ្ធិសម្រេចលើផែនការអភិវឌ្ឍន៍កំពង់ផែ ឬដំណាក់កាលនៃផែនការអភិវឌ្ឍន៍កំពង់ផែរបស់កំពង់ផែនីមួយៗ ស្របតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងនៅក្នុងផែនការកម្មកំពង់ផែ តាមសំណើររបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ដែលមានការិយាល័យអភិវឌ្ឍកំពង់ផែជាអ្នកទទួលខុសត្រូវលើការរៀបចំបែបបទ និងនីតិវិធីនៃការស្នើសុំទាំងនេះ។

ក្រោយទទួលបានលិខិតវាយតម្លៃផែនការកម្មកំពង់ផែ ម្ចាស់អាជីវកម្មត្រូវធ្វើការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ជាដាច់ខាត មកកាន់ក្រសួងសាធារណការនិងដឹកជញ្ជូន។

---

[២២] នាយកដ្ឋានរដ្ឋបាលកំពង់ផែ.(២០២០).ប្រការ៤ នៃសេចក្តីព្រាងប្រកាសស្តីពីផែនការកម្មកំពង់ផែ នៃព្រះរាជាណាចក្រកម្ពុជា.

[២៣] លោក រស់ សុវណ្ណរិទ្ធ ប្រធានការិយាល័យអភិវឌ្ឍកំពង់ផែ. ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០.

[២៤] សារាចរណែនាំលេខ ០៧០ សរណន.សក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពី ផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា.

[២៥] ប្រកាសអន្តរក្រសួងលេខ១៤៦០ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងសាធារណការ និងដឹកជញ្ជូន.

### ២.១.៣.២. លិខិតអនុញ្ញាតសាងសង់កំពង់ផែ

ក្នុងការសាងសង់ និងការជួសជុលឋបនីយភណ្ឌផែ ត្រូវមានលិខិតអនុញ្ញាតដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន។[២៦] ការសាងសង់ ឬការជួសជុលឋបនីយភណ្ឌផែ ត្រូវធ្វើឡើងស្របតាមបទដ្ឋានបច្ចេកទេសសាងសង់ឋបនីយភណ្ឌផែ។ ដើម្បីសាងសង់កំពង់ផែបាន រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ ត្រូវដាក់ពាក្យស្នើសុំមកកាន់ក្រសួងសាធារណការនិងដឹកជញ្ជូន ដោយតម្រូវឱ្យមានសំណុំឯកសារមួយចំនួនដូចជាៈ ប្លង់ស្ថាបត្យកម្មសំណង់កំពង់ផែ ដើម្បីឱ្យក្រុមការងារបច្ចេកទេស ធ្វើការពិនិត្យមើលពីលក្ខណៈបច្ចេកទេស និងសណ្ឋានទូទៅនៃគ្រោងឆ្អឹងរបស់កំពង់ផែ ពោលគឺពិនិត្យពីរូបរាងនៃការរចនារបស់កំពង់ផែ។[២៧] រូបវន្តបុគ្គល ឬនីតិបុគ្គល ក៏ត្រូវដាក់ភ្ជាប់មកជាមួយនូវ ប្លង់វិស្វកម្មសំណង់កំពង់ផែ ឬប្លង់បង្គុំសំណង់កំពង់ផែ សម្រាប់ឱ្យក្រុមបច្ចេកទេសពិនិត្យ និងប្រៀបធៀបរវាងគ្រឿងបង្គុំដែលត្រូវយកមកប្រើប្រាស់ ធៀបជាមួយនឹងប្លង់ស្ថាបត្យកម្មកំពង់ផែ ដើម្បីបញ្ជាក់ថា កំពង់ផែដែលនឹងត្រូវសាងសង់នេះ មានភាពរឹងមាំ និងត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស។[២៨] ជាមួយគ្នានេះ អ្នកស្នើសុំ ក៏ត្រូវមានភ្ជាប់មកនូវផែនការការងារសាងសង់កំពង់ផែ ជាមួយនឹងពាក្យស្នើសុំផងដែរ។

ក្រៅពីការត្រួតពិនិត្យលើឯកសារចាំបាច់រួចហើយ ក្រុមការងារនៃការិយាល័យបច្ចេកទេស នឹងធ្វើការចុះទៅកាន់ការដ្ឋានសាងសង់កំពង់ផែផ្ទាល់ ដើម្បីធ្វើការវាយតម្លៃមុននឹងរៀបចំនីតិវិធីបន្ទាប់។ ក្រសួងសាធារណការនិងដឹកជញ្ជូន ប្រើប្រាស់រយៈពេល ៣០ថ្ងៃ សម្រាប់នីតិវិធីនៃការចេញលិខិត ដោយគិតចាប់ពីថ្ងៃស្នើសុំ ហើយក្រុមហ៊ុនត្រូវបង់ប្រាក់ថ្លៃសេវាចំនួន ៥,000,000 រៀល ដែលលិខិតមានសុពលភាពអចិន្ត្រៃយ៍។[២៩]

ក្រោយការសាងសង់រួច រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវរៀបចំសំណុំឯកសារដើម្បីធ្វើការស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ មុននឹងដំណើរការអាជីវកម្មរបស់ខ្លួន ហើយនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ នឹងត្រូវបានបកស្រាយយ៉ាងលម្អិតនៅចំណុចបន្ទាប់។

## ២.២. អំពីការផ្តល់សេវាលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ

ការចេញលិខិតអនុញ្ញាប្រតិបត្តិការកំពង់ផែ គឺជាដំណាក់កាលដ៏សំខាន់មួយដែលម្ចាស់ផែត្រូវតែគោរព និងអនុវត្តតាម មុននឹងដាក់ឱ្យដំណើរការផែរបស់ខ្លួនដោយស្របច្បាប់។ ការចេញលិខិតនេះ គឺជាការផ្តល់ឱ្យនូវអតិថិជន(ម្ចាស់ផែ) ទទួលបាននូវភាពស្របច្បាប់របស់ខ្លួន តាមរយៈការទទួលយកការផ្តល់សេវាពីក្រសួង

[២៦] មាត្រា២៥ នៃសេចក្តីព្រាងច្បាប់ស្តីពីកំពង់ផែ.

[២៧] សារាចរណែនាំលេខ ០៧០ សរណន.សក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពី ផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា.

[២៨] លោក ម៉ក់ សំណាង ប្រធានការិយាល័យបច្ចេកទេស នៃនាយកដ្ឋានរដ្ឋបាលកំពង់ផែ. ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០.

[២៩] ប្រកាសអន្តរក្រសួងលេខ១៤៦០ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងសាធារណការ និងដឹកជញ្ជូន.

សាធារណការនិងដឹកជញ្ជូន ដែលមាននាយកដ្ឋានរដ្ឋបាលកំពង់ផែ នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ជាសេនាធិការ។

**២.២.១. នីតិវិធីនៃការចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ**

បន្ទាប់ពីការសាងសង់ចប់សព្វគ្រប់ហើយ សាមីកំពង់ផែត្រូវស្នើសុំលិខិតអនុញ្ញាតធ្វើប្រតិបត្តិការ មុននឹងអាចដំណើរការអាជីវកម្មកំពង់ផែបាន។ គោលបំណងនៃការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ គឺដើម្បីធានាសន្តិសុខ សុវត្ថិភាពរាល់កំពង់ផែ ទាំងអស់ដែលបានសាងសង់រួចមុននឹងដាក់ឱ្យដំណើរការអាជីវកកម្មរបស់ខ្លួន។[៣០] លិខិតនេះមានសុពលភាពរយៈពេល ២ឆ្នាំ និងរយៈពេលនៃដំណើរការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែមានរយៈពេល ២០ថ្ងៃគិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំ។ ករណីសាមីកំពង់ផែ ដែលមានលិខិតអនុញ្ញាតប្រតិបត្តិការហួសសុពលភាព គឺតម្រូវអោយសាមីកំពង់ផែធ្វើការដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតប្រតិបត្តិការនេះសារជាថ្មីម្តងទៀត ដោយត្រូវបង់កម្រៃសេវាចំនួន ៦ ០០០ ០០០ រៀល ហើយដំណើរការនៃការផ្តល់លិខិតបន្តសុពលភាពនេះ មានរយៈពេល ១០ថ្ងៃគិតចាប់ពីថ្ងៃស្នើសុំ។ នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការនេះ ត្រូវបានបែងចែកជា ៥ដំណាក់កាលគឺ៖ ដំណាក់កាលនៃការដាក់ពាក្យស្នើសុំ ដំណាក់កាលនៃការត្រួតពិនិត្យ ដំណាក់កាលនៃការវាយតម្លៃ ដំណាក់កាលនៃការអនុម័តនិងប្រគល់ឯកសារលិខិត និងដំណាក់កាលក្រោយប្រគល់ឯកសារលិខិត។ បន្តទៅនេះ យើងខ្ញុំនឹងធ្វើការបកស្រាយលម្អិតអំពីដំណាក់កាលនីមួយៗ។

**២.២.១.១. ដំណាក់កាលនៃការស្នើសុំ**

**ក. ការរៀបចំឯកសារដើម្បីធ្វើការស្នើសុំ**

ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងស្នើសុំលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែរបស់ខ្លួន ត្រូវដាក់ពាក្យស្នើសុំមកកាន់ ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយភ្ជាប់មកជាមួយឯកសារដូចជា៖[៣១]

- ពាក្យសុំធ្វើប្រតិបត្តិការបបនីយភណ្ឌផែ.............................................. ០១ ច្បាប់
- របាយការណ៍បញ្ចប់ការសាងសង់ ........................................................ ០១ ច្បាប់
- ផែនការប្រតិបត្តិការបបនីយភណ្ឌផែ និងឧបករណ៍................................... ០១ ច្បាប់
- ផែនការថែទាំ និងគ្រប់គ្រងបបនីយភណ្ឌផែ........................................... ០១ ច្បាប់
- ផែនការសន្តិសុខបបនីយភណ្ឌផែ (បើចាំបាច់)........................................ ០១ ច្បាប់
- វិធានការបរិស្ថានរួមទាំងកម្មវិធីត្រួតពិនិត្យតាមដានបរិស្ថាន ....................... ០១ ច្បាប់
- បញ្ជីរាយនាមនាយសន្តិសុខ និងសន្តិសុខបបនីយភណ្ឌ ផែ ....................... ០១ ច្បាប់

[៣០] លោក ឈឹម ម៉ន ប្រធានការិយាល័យប្រតិបត្តិការកំពង់ផែ. ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០.

[៣១] នាយកដ្ឋានរដ្ឋបាលកំពង់ផែ.(២០២០). សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការបបនីយភណ្ឌផែ.

- របាយការណ៍ទំនិញ អ្នកដំណើរ និងនាវាឆ្លងកាត់ .................................... ០១ ច្បាប់។

ប៉ុន្តែចាប់ពីឆ្នាំ ២០២០មក សម្រាប់កំពង់ផែដែលបានដំណើរការរួចហើយមុនការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ គឺតម្រូវឱ្យមានភ្ជាប់ជាមួយនូវឯកសារមួយចំនួនបន្ថែមទៀតដូចខាងក្រោមៈ[៣២]

- លិខិតចុះបញ្ជីពាណិជ្ជកម្ម.............................................................. ០១ ច្បាប់
- លក្ខន្តិកៈក្រុមហ៊ុន...................................................................... ០១ ច្បាប់
- ប្លង់កំពង់ផែ ............................................................................. ០១ ច្បាប់
- គោលការណ៍បង្កើតផែ ................................................................. ០១ ច្បាប់
- ប្លង់កម្មសិទ្ធិដីធ្លី ........................................................................ ០១ ច្បាប់
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...................................................... ០១ ច្បាប់
- ប្លង់ស្ថាបត្យកម្មសំណង់កំពង់ផែ.......................................................... ០១ ច្បាប់
- ប្លង់វិស្វកម្មសំណង់កំពង់ផែ ឬប្លង់បង្គុំសំណង់កំពង់ផែ............................... ០១ ច្បាប់
- ផែនការការងារសាងសង់កំពង់ផែ.......................................................... ០១ ច្បាប់។

### ខ. ការដាក់លិខិតស្នើសុំ

បន្ទាប់ពីមានឯកសារគ្រប់គ្រាន់ហើយ សាមីកំពង់ផែ ឬអ្នកតំណាងដែលទទួលបានការប្រគល់សិទ្ធិស្របច្បាប់ពីម្ចាស់ក្រុមហ៊ុន-សហគ្រាស ត្រូវយកពាក្យសុំនោះទៅកាន់នាយកដ្ឋានរដ្ឋបាល នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។[៣៣] មន្ត្រីរដ្ឋបាលរបស់ក្រសួងនឹងធ្វើការពិនិត្យ និងរៀបចំនីតិវិធីរបស់ខ្លួនដើម្បីបញ្ជូនឯកសារនោះទៅកាន់អង្គភាពទទួលបន្ទុក ពោលគឺត្រូវបញ្ជូនមកអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ។ ក្រោយទទួលបានឯកសារស្នើសុំ ផ្នែកជំនួយការរដ្ឋបាលនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ នឹងធ្វើការពិនិត្យ និងរៀបចំកំណត់បង្ហាញរឿងមួយដែលមានភ្ជាប់នូវចំណារប្រគល់ភារកិច្ចរបស់ឯកឧត្តមអគ្គនាយក រួចបញ្ជូនឯកសារទាំងនោះមកកាន់នាយកដ្ឋានរដ្ឋបាលកំពង់ផែ និងនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ(ទទួលបានច្បាប់ថតចម្លង) ដែលនៅក្រោមចំណុះរបស់ខ្លួនដើម្បីរៀបចំនីតិវិធីបន្ត។ បន្ទាប់ពីទទួលបាននូវសំណុំឯកសារស្នើសុំហើយ នាយកដ្ឋានរដ្ឋបាលកំពង់ផែនឹងរៀបចំចាត់ចែងការចេញលិខិតអនុញ្ញាតជូនដល់ក្រុមហ៊ុន ឬសហគ្រាសដែលបានស្នើសុំទៅតាមនីតិវិធីរបស់ខ្លួនដូចមានរៀបរាប់នៅចំណុចក្រោយៗនេះ។

[៣២] លោក ឈឹម ម៉ន ប្រធានការិយាល័យប្រតិបត្តិការកំពង់ផែ នៃនាយកដ្ឋានរដ្ឋបាលកំពង់ផែ. ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០.

[៣៣] លោក ស៊ុម ច័ន្ទតារា មន្ត្រីការិយាល័យកិច្ចការទូទៅ នៃនាយកដ្ឋានរដ្ឋបាលកំពង់ផែ. ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០.

### ២.២.១.២. ដំណាក់កាលនៃការត្រួតពិនិត្យ

អាជ្ញាធរដែលមានភារកិច្ចទទួលបន្ទុក ពោលគឺនាយកដ្ឋានរដ្ឋបាលកំពង់ផែ នឹងរៀបចំនីតិវិធី ដើម្បីត្រួតពិនិត្យឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌដែលអនុលោមដោយលិខិតបទដ្ឋានគតិយុត្តនានា។ នេះជានីតិវិធីមួយនៃនីតិវិធីរដ្ឋបាល ដែលមានភាពចាំបាច់បំផុតមុននឹងអាជ្ញាធរសាធារណៈអាចធ្វើការសម្រេចលើរឿងអ្វីមួយ។[៣៤] ក្នុងករណីនេះ នាយកដ្ឋានរដ្ឋបាលកំពង់ផែ មានសមត្ថកិច្ចក្នុងការពិនិត្យ និងវាយតម្លៃប្រតិបត្តិការបបនីយភណ្ឌផែ ដូចជា៖ ពិនិត្យផ្ទៀងផ្ទាត់ពាក្យសុំ រួមទាំងឯកសារពាក់ព័ន្ធទាំងអស់។ បន្ថែមលើនេះផងដែរ នាយកដ្ឋានរដ្ឋបាលកំពង់ផែ ក៏មានសមត្ថកិច្ចចុះពិនិត្យ សិក្សា និងវាយតម្លៃទីតាំងផ្ទាល់របស់កំពង់ផែ និងបបនីយភណ្ឌផែ រួមទាំងស្នើសុំឯកសារបន្ថែម ឬស្នើសុំឱ្យក្រុមហ៊ុនបំពេញចំណុចខ្វះខាតនានា។[៣៥] ក្នុងករណីចាំបាច់ នាយកដ្ឋានរដ្ឋបាលកំពង់ផែអាចស្នើឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលធ្វើការបំភ្លឺពីសំណាក់ក្រុមហ៊ុនដែលបានដាក់ពាក្យសុំទាំងនោះ លើចំណុចខ្វះខាតក្នុងការអនុវត្តលក្ខខណ្ឌដែលក្រសួងបានតម្រូវផងដែរ។

#### ក. ការត្រួតពិនិត្យលើឯកសារស្នើសុំ

ក្រោយពេលទទួលបានឯកសារស្នើសុំនេះ ការិយាល័យកិច្ចការរទូទៅ របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែត្រូវធ្វើការបោះត្រាចូល និងចុះលេខលើលិខិតភ្ជាប់ដើម្បីរក្សាទុកឯកសារជាកាលប្បវត្តិ រួចបញ្ជូនរាល់សំណុំឯកសារនោះដាក់ជូនទៅកាន់ប្រធាននាយកដ្ឋានដើម្បីពិនិត្យ និងបែងចែកតាមរយៈចំណារទៅកាន់ការិយាល័យទទួលបន្ទុក ពោលគឺការិយាល័យប្រតិបត្តិការកំពង់ផែ។ មន្ត្រីជំនាញនៃនាយកដ្ឋានរដ្ឋបាលកំពង់ផែ ដែលមានការិយាល័យប្រតិបត្តិការកំពង់ផែជាសេនាធិការ ត្រូវពិនិត្យនូវរាល់សំណុំឯកសារភ្ជាប់តាមលក្ខខណ្ឌតម្រូវ។ ក្រោយការពិនិត្យរួចរាល់ ប្រសិនបើសំណុំឯកសារទាំងនោះត្រឹមត្រូវ និងគ្រប់គ្រាន់ ក្រុមការងារទទួលបន្ទុកត្រូវចុះទៅត្រួតពិនិត្យដល់ទីតាំងកំពង់ផែផ្ទាល់។ ក្នុងករណីឯកសារមិនបានបំពេញត្រឹមត្រូវតាមការណែនាំ និងលក្ខខណ្ឌតម្រូវទេ នោះមន្ត្រីជំនាញនឹងធ្វើលិខិតឆ្លើយតបទៅសាមីកំពង់ផែ ដើម្បីឱ្យបំពេញឯកសារបន្ថែម។ ប្រភេទឯកសារដែលត្រូវបានពិនិត្យនោះ គឺដូចមានរៀបរាប់ក្នុងចំណុច ២.២.២.១ កបាខណ្ឌ “ក” ខាងលើ ។

#### ខ. ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស

បន្ទាប់ពីសាមីកំពង់ផែបានបំពេញឯកសារគ្រប់គ្រាន់ហើយ ការិយាល័យកិច្ចការទូទៅ នឹងរៀបចំលិខិតបញ្ជាបេសកកម្ម និងទិដ្ឋការធ្វើដំណើរសម្រាប់ក្រុមការងារធ្វើការចុះទៅកាន់ទីតាំងកំពង់ផែផ្ទាល់ ដើម្បីត្រួតពិនិត្យមើលពីស្ថានភាពជាក់ស្តែង។ ក្នុងដំណើរនៃបេសកកម្មនេះ ត្រូវមានការចូលរួមពីមន្ត្រីរបស់នាយកដ្ឋានរដ្ឋបាល

[៣៤] សាស្ត្រាចារ្យ ឌឿក ពិដោរ.(២០២០). នីតិវិធីរដ្ឋបាល. ភ្នំពេញ.

[៣៥] នាយកដ្ឋានរដ្ឋបាលកំពង់ផែ.(២០២០). សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការបបនីយភណ្ឌផែ.

កំពង់ផែ ជាពិសេសគឺមានការចូលរួមជាដាច់ខាតពីសំណាក់មន្ត្រីទទួលបន្ទុកការងារនៅការិយាល័យប្រតិបត្តិការកំពង់ផែ និងតំណាងមន្ត្រីនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែផងដែរ។

នៅពេលចុះទៅដល់ទីតាំងកំពង់ផែ ក្រុមមន្ត្រីជំនាញនៃនាយកដ្ឋានរដ្ឋបាលកំពង់ផែ និងនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ ចាប់ផ្ដើមធ្វើការពិនិត្យ និងវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យមួយចំនួនដូចខាងក្រោម៖[៣៦]

- **លក្ខណៈកំពង់ផែ**

កំពង់ផែ ត្រូវមានលទ្ធភាពបំពេញមុខងារពេញលេញ ដោយត្រូវមានអគាររដ្ឋបាលផ្ទាល់ខ្លួនសម្រាប់បំពេញការងាររបស់បុគ្គលិក ហើយទីតាំងនៃចំណតផែត្រូវមានច្រកចូល-ចេញ ទីធ្លាធំទូលាយ និងរបងរឹងមាំល្អ។ លើសពីនេះទៀត កំពង់ផែត្រូវរៀបចំសាងសង់សំណង់សម្រាប់ការពារច្រាំងចំណតផែ ដើម្បីបញ្ចៀសការបាក់ច្រាំងជាយថាហេតុ។ ព្រមជាមួយគ្នានេះ ក៏ត្រូវមានប្រព័ន្ធកត់ត្រានូវបរិមាណទំនិញឆ្លងកាត់ ចំនួនអ្នកដំណើរ ចំនួននាវាចូល និងព័ត៌មានចាំបាច់ផ្សេងទៀត។ល។

- **ការប្រើប្រាស់ឋបនីយភណ្ឌផែ ការថែទាំ និងការគ្រប់គ្រងឋបនីយភណ្ឌផែ**

ការប្រើប្រាស់ឋបនីយភណ្ឌផែ និងឧបករណ៍ ត្រូវសមស្របតាមគោលបំណង ឬកម្មវត្ថុនៃការកសាងកំពង់ផែ។ កំពង់ផែ ត្រូវមានការចែងលម្អិតពីវិធានការសន្តិសុខឱ្យបានត្រឹមត្រូវ ហើយការប្រើប្រាស់ឋបនីយភណ្ឌផែត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចលើការងារការពារសន្តិសុខ ការថែទាំ ជួសជុល និងសម្អាតទីលានចំណតផែជាប្រចាំ។ល។

- **បរិស្ថាន សុវត្ថិភាព សន្តិសុខ និងផែនការគ្រោះអាសន្ន**

រាល់កំពង់ផែ ត្រូវមានឋបនីយភណ្ឌសម្រាប់ទទួលសំណល់ពីនាវា និងត្រូវមានឋបនីយភណ្ឌសម្រាប់ទទួលសំណល់ពីនាវា ដូចជា៖ ប្រព័ន្ធលូបង្ហូរនិងអាងចម្រោះទឹកកខ្វក់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ដែលកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងបរិស្ថានជាដាច់ខាត។ កំពង់ផែទាំងនោះត្រូវមានឋបនីយភណ្ឌសម្រាប់ចងព្យួរ និងបង្គោលភ្លើងបំភ្លឺនៅបរិវេណចំណតផែគ្រប់គ្រាន់ ព្រមទាំងត្រូវមានប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីស្របតាមលក្ខណៈបច្ចេកទេស ដើម្បីធានាការការពារបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខុមាលភាពសន្តិសុខសង្គម។ល។ ដោយត្រូវបំពាក់នូវបំពង់ពន្លត់អគ្គិភ័យនៅទីតាំងចំណតផែ និងតំបន់ទីតាំងប្រតិបត្តិការ និងរក្សាទុកទំនិញដទៃទៀត ដើម្បីធានាបាននូវការសង្គ្រោះ និងដោះស្រាយបានគ្រប់គ្រាន់នៅពេលមានអគ្គិភ័យកើតឡើង។

[៣៦] សារាចរណែនាំលេខ ០៧០ សរណន.សក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពី ផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា.

**២.២.១.៣. ដំណាក់កាលនៃការវាយតម្លៃ**

**ក. ករណីកំពង់ផែបានគោរពតាមលក្ខខណ្ឌវិនិច្ឆ័យ**

ក្រោយត្រឡប់ពីការចុះត្រួតពិនិត្យដល់ទីតាំងកំពង់ផែផ្ទាល់ ក្រុមការងារមន្ត្រីជំនាញនឹងបើកកិច្ចប្រជុំបូកសរុបលទ្ធផលស្តីពីការត្រួតពិនិត្យរបស់ខ្លួន លើករណីដែលសាមីកំពង់ផែបានបំពេញ តាមសារាចរលេខ ០៧០ សរណន.សក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពី ផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងស្ថានភាពជាក់ស្តែងរបស់កំពង់ផែ។ ប្រសិនបើលទ្ធផលបញ្ជាក់ថា កំពង់ផែនោះ បានគោរពតាមលក្ខខណ្ឌបច្ចេកទេសកំណត់ត្រឹមត្រូវហើយ នាយកដ្ឋានរដ្ឋបាលកំពង់ផែនឹងអញ្ជើញសាមីកំពង់ផែឱ្យមកធ្វើការបង់កម្រៃសេវាសាធារណៈ ចំនួន ៧ ០០០ ០០០ រៀល មុននឹងចាប់ផ្តើមបន្តនីតិវិធីរបស់ខ្លួនក្នុងការចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែពីថ្នាក់ដឹកនាំ ជូនដល់ក្រុមហ៊ុន។

**ខ. ករណីរូបវន្តបុគ្គល ឬនីតិបុគ្គលបានល្មើស**

ក្នុងករណីកំពង់ផែមិនទាន់បានបំពេញតាមលក្ខខណ្ឌគ្រប់គ្រាន់តាមការកំណត់ មន្ត្រីជំនាញនឹងរៀបចំលិខិតឆ្លើយតបទៅសាមីកំពង់ផែ ដើម្បីឱ្យបំពេញលក្ខខណ្ឌបានត្រឹមត្រូវស្របតាមលក្ខណៈវិនិច្ឆ័យដែលអាចចេញលិខិតអនុញ្ញាតជូនបាន។ ក្នុងករណីនេះដែរ សាមីកំពង់ផែត្រូវធ្វើកិច្ចសន្យាមួយថានឹងបំពេញរាល់ចំណុចខ្វះខាត ដែលក្រុមការងារមន្ត្រីជំនាញបានទាមទារ។ ដូចនេះ ក្នុងរយៈពេលនៃដំណើរការប្រតិបត្តិការអាជីវកម្មផែរយៈពេល ២ឆ្នាំ របស់ខ្លួន ប្រសិនបើក្រុមហ៊ុនមិនបានគោរពតាមកិច្ចសន្យា នោះក្រសួងនឹងមិនបន្តសុពលភាពលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែរបស់ខ្លួនជាបន្តទៀតបានឡើយ រហូតទាល់តែកំពង់ផែបានបំពេញតាមការទាមទារនោះ។ លើសពីនេះ នាយកដ្ឋានរដ្ឋបាលកំពង់ផែដែលជាសេនាធិការ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិបដិសេធន៍មិនចេញលិខិតអនុញ្ញាតជូនដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងករណីពួកគេមិនមានឯកសារសំខាន់ៗដូចជា៖ ប្លង់ស្ថាបត្យកម្ម និងប្លង់បង្គុំស្ថាបត្យកម្ម គ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវ ព្រមទាំងការមិនអនុញ្ញាតឱ្យមន្ត្រីមានសមត្ថកិច្ចនៃក្រសួងសាធារណការនិងដឹកជញ្ជូន ចុះពិនិត្យដល់ទីកន្លែង ឬខកខានមិនបានផ្តល់ព័ត៌មានមកកាន់នាយកដ្ឋានរដ្ឋបាលកំពង់ផែ។

**២.២.១.៤. ដំណាក់កាលនៃការអនុម័ត និងប្រគល់ឯកសារលិខិត**

បន្ទាប់ពីបានទទួលលទ្ធផលវាយតម្លៃត្រឹមត្រូវតាមបច្ចេកទេស និងមានការបង់ថ្លៃសេវាសាធារណៈរួចហើយ មន្ត្រីជំនាញនៃការិយាល័យប្រតិបត្តិការកំពង់ផែ នឹងភ្ជាប់វិក័យបត្របង់ប្រាក់នោះជាមួយសំណុំឯកសារដែលរៀបចំរួចជាស្រេច ដើម្បីលើកយោបល់តាមឋានានុក្រមទៅកាន់ប្រធាននាយកដ្ឋាន អគ្គនាយករងទទួលបន្ទុកនាយកដ្ឋាន និងអគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ។ រួចបន្តស្នើសុំការសម្រេចពីអនុរដ្ឋលេខាធិការ និងរដ្ឋលេខាធិការទទួលបន្ទុកផ្ទាល់ នៃអគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក

ផ្លូវសមុទ្រ និងកំពង់ផែ មុននឹងទទួលបានការចុះហត្ថលេខាលើលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ ដោយឯកឧត្តមរដ្ឋមន្ត្រីផ្ទាល់។ ក្រោយពីទទួលបានការសម្រេចពីរដ្ឋមន្ត្រីហើយ នាយកដ្ឋានរដ្ឋបាលកំពង់ផែនឹងធ្វើការទាក់ទងទៅកាន់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាអ្នកស្នើសុំ ឬអ្នកតំណាងដែលត្រូវបានការផ្ទេរសិទ្ធិស្របច្បាប់ ដើម្បីមកទទួលលិខិតរបស់ខ្លួននៅនាយកដ្ឋានដោយផ្ទាល់។

**២.២.១.៥. ដំណាក់កាលក្រោយប្រគល់ឯកសារលិខិត**

ក្នុងការធ្វើប្រតិបត្តិការកំពង់ផែ នាយសន្តិសុខបបនីយកណ្ឌផែ ត្រូវធ្វើរបាយការណ៍ជាប្រចាំមកកាន់នាយកដ្ឋានរដ្ឋបាលកំពង់ផែ។ នាយកដ្ឋានរដ្ឋបាលកំពង់ផែ មានសិទ្ធិដកហូត និងមិនអនុញ្ញាតឱ្យនាវាចូលចត នៅតាមកំពង់ផែ ក្នុងករណីដូចខាងក្រោម៖[៣៧]

**ក. ដកហូតលិខិតអនុញ្ញាត ឬផ្អាកប្រតិបត្តិការបបនីយកណ្ឌផែបណ្ដោះអាសន្ន**

ការដកហូតលិខិតអនុញ្ញាត ឬផ្អាកប្រតិបត្តិការបបនីយកណ្ឌផែ ក្នុងករណីដូចជា៖ ប្រតិបត្តិការបបនីយកណ្ឌផែ មិនស្របតាមកម្មវត្ថុដែលបានស្នើសុំ និង/ឬ មិនបានបំពេញឯកសារដែលនៅខ្វះខាតតាមកិច្ចសន្យា និង/ឬ បបនីយកណ្ឌផែរបស់ខ្លួនមិនអាចធានាការធ្វើប្រតិបត្តិការបានតាមលក្ខណៈបច្ចេកទេស។

**ខ. មិនអនុញ្ញាតឱ្យនាវាចូល-ចេញចត**

ការមិនអនុញ្ញាតឱ្យមាននាវាចូល-ចេញចតបាន ក្នុងករណី រូបវន្តបុគ្គល ឬនីតិបុគ្គលយឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតប្រតិបត្តិការបបនីយកណ្ឌផែរបស់ខ្លួន ក្រោយទទួលបានដំណឹងពីនាយកដ្ឋានរដ្ឋបាលកំពង់ផែច្រើនលើកច្រើនសារ។ ការចាត់វិធានការនេះ គឺដូចគ្នានឹងការដែលកំពង់ផែ ឬចំណតផែដែលមិនមានលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែដែរ។

**២.២.២. គោលការណ៍ដែលអនុវត្តចំពោះមន្ត្រីដែលផ្តល់សេវា**

ដើម្បីធានាពង្រឹងការបំពេញតួនាទីភារកិច្ចប្រកបដោយក្រមសីលធម៌ខ្ពស់របស់មន្ត្រីរាជការ ក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធិផលកាន់តែប្រសើរឡើង មន្ត្រីបម្រើសេវាទាំងអស់ត្រូវប្រកាន់ភ្ជាប់ឱ្យបាននូវវប្បធម៌សេវាសាធារណៈ គឺសំដៅដល់ការផ្តល់សេវាសាធារណៈរបស់បុគ្គលិកមន្ត្រីរាជការដែលត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ចម្បងៗមួយចំនួនជាចាំបាច់ដូចខាងក្រោម៖

**២.២.២.១. ការផ្លាស់ប្តូរឥរិយាបទរបស់មន្ត្រីរាជការ**

មន្ត្រីរាជការទាំងអស់ ត្រូវធ្វើការផ្លាស់ប្តូរឥរិយាបទរបស់ខ្លួនពី **"អ្នកត្រួតត្រា ទៅជាអ្នកផ្តល់សេវា"** និងត្រូវបំពេញតួនាទីជាអ្នកបម្រើប្រជាពលរដ្ឋ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ភាពស្មោះត្រង់ សេចក្តីថ្លៃថ្នូរ និងទំនួលខុសត្រូវខ្ពស់។ ពួកគេ ត្រូវប្រកាន់ខ្ជាប់នូវឥរិយាបថជាមន្ត្រីល្អ ជាអ្នកបម្រើ និងផ្តល់សេវាល្អជូនប្រជាពលរដ្ឋ

[៣៧] នាយកដ្ឋានរដ្ឋបាលកំពង់ផែ.(២០២០). សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការបបនីយកណ្ឌផែ.

ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ដើម្បីផ្តល់ភាពកក់ក្តៅ ទំនុកចិត្ត និងការគោរពស្រលាញ់ ជូនប្រជាពលរដ្ឋទូទៅ និងមិនត្រូវប្រើប្រាស់តួនាទី ឬមុខតំណែងរបស់ខ្លួន ទៅគំរាមកំហែង ឬបង្កការលំបាកដល់ពួកគាត់ឡើយ។

**២.២.២.២. ភាពឆ្លើយតប**

ក្នុងនាមជាអ្នកផ្តល់សេវា ត្រូវផ្តោតជាសំខាន់ទៅលើសេចក្តីត្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា និងត្រូវឆ្លើយតបប្រកបដោយមនសិការវិជ្ជាជីវៈ និងសេចក្តីថ្លៃថ្នូរបស់មន្ត្រីរាជការ។ លើសពីនេះ គេក៏ត្រូវចេះសម្របសម្រួល និងមានការទំនាក់ទំនងល្អជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ដើម្បីបំពេញតួនាទីបម្រើប្រជាពលរដ្ឋឲ្យបានល្អបំផុត ។

**២.២.២.៣. ភាពច្បាស់លាស់ក្នុងការផ្តល់ព័ត៌មាន**

មន្ត្រីរាជការជាអ្នកប្រឹក្សាយោបល់ ដែលត្រូវយកចិត្តទុកដាក់ក្នុងការផ្តល់ពត៌មាន និងពន្យល់ឱ្យបានច្បាស់លាស់ដល់ប្រជាពលរដ្ឋអំពីនីតិវិធី របៀបរបប និងបែបបទផ្សេងៗដើម្បីទទួលបានសេវា។ ពួកគាត់ត្រូវផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់អំពីនីតិវិធី និងបែបបទទាំងនោះឱ្យស្របតាមបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ ហើយក៏ត្រូវដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់បំផុត។

**២.២.២.៤. ការសម្របសម្រួល**

មន្ត្រីរាជការ ជាអ្នកសម្របសម្រួលទៅលើដំណើរការនៃការផ្តល់សេវា និងការមកទទួលយកសេវាទៅប្រើប្រាស់ ដោយការកាត់បន្ថយនីតិវិធីស្មុគស្មាញ(ការិយាធិបតេយ្យ) ការផ្តល់សេវាមានភាពសាមញ្ញ ខ្លីទាន់ពេលវេលា និងមានភាពរលូននៅក្នុងទម្រង់ការងារទាំងអស់។ ពោលគឺ ពួកគាត់ត្រូវកែសម្រួលរបៀបរបបធ្វើការងាររបស់ខ្លួនតាមបែបនវានុវត្តន៍(Innovation) សំដៅធានាបាននូវភាពឆ្លើយតបឱ្យបានល្អ ទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលមកទទួលសេវា ព្រមទាំងត្រូវចូលរួមអនុវត្តយន្តការកាត់បន្ថយនីតិវិធីស្មុគស្មាញ និងសុំញ៉ាំ ដើម្បីបង្កភាពងាយស្រួលទាំងក្នុងការផ្តល់ និងការទទួលសេវាសាធារណៈ។

# ជំពូកទី៣
# លទ្ធផលនៃការវិភាគ
# លើការផ្តល់សេវា
# លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ

# ជំពូកទី៣
# លទ្ធផល នៃការវិភាគលើការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ

នៅក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាបន្ថែមទៀត ដោយផ្តោតយ៉ាងសំខាន់ទៅលើលទ្ធផលការងារ និង ទិសដៅអនុវត្តបន្ទាប់របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ(ចំណុច៣.១) ការវិភាគទៅលើការអនុវត្តការងាររបស់ នាយកដ្ឋានពាក់ព័ន្ធលើការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ(ចំណុច៣.២) និងសកម្មភាពការងារមួយ ចំនួនដែលយើងខ្ញុំទាំងពីរ នាក់បានចូលរួមធ្វើក្នុងកំឡុងពេលនៃការចុះកម្មសិក្សានៅនាយកដ្ឋានរដ្ឋបាលកំពង់ផែ រយៈពេល១ខែ កន្លះ(ចំណុច៣.៣)។

## ៣.១. លទ្ធផលការងារ និងទិសដៅអនុវត្តបន្ទាប់របស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ

### ៣.១.១. លទ្ធផលការងាររបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែក្នុងការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការផែ

ដើម្បីធ្វើការបកស្រាយឱ្យកាន់តែលម្អិត និងក្បោះក្បាយ អំពីលទ្ធផលការងាររបស់នាយកដ្ឋានរដ្ឋបាល កំពង់ផែក្នុងការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការផែ យើងនឹងធ្វើការសិក្សាទៅលើចំណុចសំខាន់ ២គឺ លទ្ធផល ការងារដែលនាយកដ្ឋានសម្រេចបាន(៣.១.១.១) និងបញ្ហាប្រឈមក្នុងការអនុវត្តការងារនានា(៣.១.១.២) ហើយ ដែលនឹងលំអិតជាបន្តបន្ទាប់ដូចតទៅ៖

#### ៣.១.១.១. លទ្ធផលការងារដែលសម្រេចបាននៅពេលកន្លងមក

នាយកដ្ឋានរដ្ឋបាលកំពង់ផែ ត្រូវបានបង្កើតឡើងតាមរយៈប្រកាសលេខ ២៤៤ សក.ប្រក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ។ ចាប់តាំងពីការបង្កើត មក នាយកដ្ឋានបានខិតខំប្រឹងប្រែងក្នុងការបំពេញមុខងាររបស់ខ្លួន ជាពិសេសការងារទាក់ទងនឹងការចេញសេវា លិខិតជូនដល់ក្រុមហ៊ុនឯកជនជាច្រើនក្នុងដំណើរការបង្កើត ការសាងសង់ និងប្រតិបត្តិកំពង់ផែរបស់ខ្លួន។ ជាក់ស្តែង ក្នុងការបំពេញកាងារនៅឆ្នាំ២០១៩ មកទល់នឹងដើមឆ្នាំ២០២០ នេះ នាយកដ្ឋានបានទទួលលទ្ធផល ដូចខាងក្រោម៖

**ក. ការរៀបចំលិខិតបទដ្ឋានគតិយុត្តិ**

នាយកដ្ឋានបានរៀបចំ និងកែសម្រួលលើសេចក្តីព្រាងច្បាប់ស្តីពីកំពង់ផែរួចជាស្រេច និងរង់ចាំដាក់ឆ្លង ទៅកាន់កិច្ចប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី មុននឹងការសម្រេចអនុម័តចុងក្រោយពីរដ្ឋសភា ដាក់ឱ្យប្រើ ប្រាស់ជាផ្លូវការ។

ក្រៅពីនេះ នាយកដ្ឋានក៏បានរៀបចំសេចក្តីព្រាងប្រកាសសំខាន់ៗ មួយចំនួនទៀតដូចជា៖ សេចក្តីព្រាង ប្រកាសស្តីពីផែនការកម្មកំពង់ផែនៅកម្ពុជា, សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតសាងសង់

និងលិខិតអនុញ្ញាតជួសជុលកំពង់ផែនៅកម្ពុជា, និងសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែនៅកម្ពុជា ផងដែរ។ លើសពីនេះ នាយកដ្ឋានរដ្ឋបាលកំពង់ផែ ក៏បន្តសិក្សាស្រាវជ្រាវលើលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ទាក់ទងនឹងវិស័យកំពង់ផែ ដើម្បីជានាជម្រុញការគ្រប់គ្រងកំពង់ផែទាំងអស់ឱ្យកាន់តែមានប្រសិទ្ធភាព។ បន្ថែមពីលើនោះ លោកប្រធាននាយកដ្ឋានបានមានប្រសាសន៍ថា "សេចក្តីព្រាងដែលនាយកដ្ឋានបានរៀបចំ ត្រូវបានថ្នាក់ដឹកនាំយកចិត្តទុកដាក់និងជម្រុញឱ្យបានចប់រួចរាល់តាមនីតិវិធីដើម្បីប្រើជាប្រយោជន៍ក្នុងការគ្រប់គ្រង និងណែនាំដល់ការអនុវត្តការងាររបស់នាយកដ្ឋាន"។

### ខ. ការងារផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ

យើងសង្កេតឃើញថា ការងារពាក់ព័ន្ធនឹងការចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ នាយកដ្ឋានសម្រេចបានលទ្ធផលធំៗជាច្រើន គួរឱ្យកត់សម្គាល់។ ក្នុងនោះ នាយកដ្ឋានបានប្រឹងប្រែងជម្រុញឱ្យក្រុមហ៊ុនផែទាំងអស់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ឱ្យមកស្នើសុំសេវាផ្តល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ របស់ខ្លួនដោយស្របច្បាប់។ ក្រុមហ៊ុនផែដែលបានមកស្នើសុំធ្វើប្រតិបត្តិការទាំងនោះ គឺមានទាំងកំពង់ផែនៅតាមដងទន្លេ និងនៅតាមសមុទ្រ រួមមានៈ ក្រុមហ៊ុនសុវណ្ណភូមិ អ៊ិនវេសម៉ិន ក្រុមហ៊ុនរំដួលមេគង្គ ក្រុមហ៊ុនវិនិយោគទុន សូគីម៉ិច កម្ពុជា ក្រុមហ៊ុនតូតាល់ ក្រុមហ៊ុនតេលា ក្រុមហ៊ុន ប៉ាប៉ា គេត្រូលៀមកំពង់ផែដឹកធ្យូងថ្មរបស់អគ្គីសនីកម្ពុជា។ល។[៣៨] លោក **ស៊ូ ផល្លី** ប្រធាននាយកដ្ឋានរដ្ឋបាលកំពង់ផែ បានមានប្រសាសន៍បន្ថែមថា "ស្របពេលជាមួយនឹងស្ថានភាពនាពេលបច្ចុប្បន្ន ម្ចាស់ផែនានាមានការភ្ញាក់រលឹកចង់បានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ កាន់តែច្រើនឡើង"។ នេះបញ្ជាក់ថា តាមការខិតខំប្រឹងប្រែងបំពេញការងារផ្សព្វផ្សាយរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ បានធ្វើឱ្យម្ចាស់ផែនានាកាន់តែមានការយល់ដឹងពីអត្ថប្រយោជន៍នៃភាពស្របច្បាប់របស់ខ្លួនក្នុងការប្រកបអាជីវកម្មផែ និងចូលរួមកាន់តែសកម្មក្នុងការលើកកម្ពស់សេវាសាធារណៈក៏ដូចជាចូលរួមក្នុងការបង្កើនចំណូលរដ្ឋ ក្នុងន័យអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។

លើសពីនេះ នាយកដ្ឋានក៏តែងធ្វើការពិនិត្យលើកំពង់ផែដែលគ្មានលិខិតអនុញ្ញាត និងលិខិតអនុញ្ញាតហួសសុពលភាព ដើម្បីផ្តល់ព័ត៌មានឱ្យកំពង់ផែទាំងនោះមកស្នើសុំជាថ្មី ឬបន្តសុពលភាពលើលិខិតរបស់ខ្លួន។ ជាលទ្ធផល ក្នុងឆ្នាំ២០១៩កន្លងទៅនេះ នាយកដ្ឋានរដ្ឋបាលកំពង់ផែ បានចេញលិខិតនេះជូនដល់ក្រុមហ៊ុនបានចំនួន ០៦ មានទឹកប្រាក់សរុបចំនួន២៤ ០០០ ០០០រៀល (តម្លៃសេវា ៤ ០០០ ០០០រៀល) ហើយនៅដើមឆ្នាំ ២០២០ (គិតត្រឹមខែឧសភា) នេះ នាយកដ្ឋានផ្តល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ និងបន្តសុពលភាព

---

[៣៨] នាយកដ្ឋានរដ្ឋបាលកំពង់ផែ,(២០២០). របាយការណ៍ស្តីពីការចុះធ្វើបច្ចុប្បន្នភាព ស្រង់ស្ថិតិ និងចុះផ្សព្វផ្សាយណែនាំដល់កំពង់ផែ និងចំណតផែ ដែលពុំទាន់មានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការ ក្នុងព្រះរាជាណាចក្រកម្ពុជា.

បានចំនួន១១ បន្ថែមទៀត ដែលអាចប្រមូលចំណូលសាធារណៈចូលថវិការដ្ឋបានប្រមាណ ៧៧ ០០០ ០០០ រៀល(តម្លៃសេវាបានតំឡើងដល់ ៧ ០០០ ០០០រៀល)។

ក្រៅពីនេះ នាយកដ្ឋានរដ្ឋបាលកំពង់ផែ តែងបានចុះពិនិត្យដល់ទីតាំងផ្ទាល់នៃកំពង់ផែនានា ដែលបានដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ និងបន្តសុពលភាពប្រតិបត្តិការកំពង់ផែ ជូនក្រុមហ៊ុនទាំងនោះផងដែរ។

**គ. ការពង្រឹងប្រសិទ្ធភាពការងាររបស់នាយកដ្ឋាន**

ដើម្បីឱ្យការផ្តល់សេវាលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ ក៏ដូចជាសេវាផ្សេងៗទៀត របស់នាយកដ្ឋានកាន់តែមានប្រសិទ្ធភាព ថ្នាក់ដឹកនាំរបស់នាយកដ្ឋានតែងពង្រឹងការអនុវត្តការងារផ្តល់សេវារបស់ខ្លួន ឱ្យស្របតាមសារាចរណែនាំលេខ ០៧០ សរណន.សក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអនុវត្តតាមរាល់គោលការណ៍ណែនាំនានាដែលក្រសួងសាធារណការនិងដឹកជញ្ជូនបានដាក់ចេញមក។

ព្រមជាមួយគ្នានោះ នាយកដ្ឋានតែងតែបានបណ្តុះបណ្តាលសមត្ថភាពបន្ថែមជូនដល់មន្ត្រីជំនាញ និងមន្ត្រីផ្នែករដ្ឋបាលទាំងអស់ ឱ្យកាន់តែមានការយល់ដឹងលើកិច្ចការរបស់ខ្លួនជាប្រចាំ ហើយមន្ត្រីរបស់នាយកដ្ឋានមានការសហការគ្នាល្អក្នុងការបំពេញការងារ និងតែងតែធ្វើការផ្លាស់ប្តូរបទពិសោធន៍ឱ្យគ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍រួមរបស់នាយកដ្ឋាន។

នាយកដ្ឋាន បានចុះធ្វើបច្ចុប្បន្នភាព ស្រង់ស្ថិតិ និងចងក្រងទិន្នន័យកំពង់ផែទូទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រង តាមដានរាល់សកម្មភាព និងរាល់ព័ត៌មាននានារបស់កំពង់ផែទាំងអស់នោះ។ ក្រៅពីនេះ នាយកដ្ឋានរដ្ឋបាលកំពង់ផែ ក៏បានចុះផ្សព្វផ្សាយណែនាំដល់កំពង់ផែ និងចំណតផែដែលពុំទាន់មានលិខិតអនុញ្ញាតប្រតិបត្តិការ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ។

**៣.១.១.២.បញ្ហាប្រឈមក្នុងការអនុវត្តការងាររបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ**

ទោះបីនាយកដ្ឋានបានបំពេញការងារ ដោយសម្រេចជាលទ្ធផលល្អគួរឱ្យកត់សម្គាល់យ៉ាងនេះក្តី ក៏នាយកដ្ឋានបានជួបប្រទះបញ្ហាមួយចំនួនពាក់ព័ន្ធនឹង ការចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែផងដែរ។ បញ្ហាដែលចម្បងជាងគេនោះគឺ ការមិនមានថវិកាគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ការចំណាយលើតម្រូវការចាំបាច់មួយចំនួនរបស់នាយកដ្ឋាន ហើយសមត្ថភាពរបស់មន្ត្រីមួយចំនួននៅមានកម្រិតនៅឡើយ ដែលធ្វើឱ្យការបំពេញការងារ មិនបានសម្រេចគ្រប់ជ្រុងជ្រោយដូចអ្វីដែលបានគ្រោងទុក។ បន្ថែមពីលើនេះ នាយកដ្ឋានតែងជួបប្រទះការខ្វះខាតលើថវិកា និងមិនទាន់មានមធ្យោបាយធ្វើដំណើរ(រថយន្ត) សម្រាប់ចុះបេសកកម្មចាំបាច់នានា ជាពិសេសថវិកាសម្រាប់ចុះបេសកកម្មត្រួតពិនិត្យរាល់បណ្តាកំពង់ផែនានា ដែលពេលខ្លះមន្ត្រីរបស់នាយកដ្ឋាន

ប្រើប្រាស់ថវិកាផ្ទាល់ខ្លួនសម្រាប់ផ្គត់ផ្គង់ការចំណាយដោយខ្លួនឯង និងតែងតែប្រើប្រាស់រថយន្តផ្ទាល់របស់ខ្លួនក្នុងចុះបេសកកម្មផងដែរ។ ការខ្វះខាតលើផ្នែកថវិកាបេសកកម្មនេះ បានធ្វើឱ្យនាយកដ្ឋានគ្មានដំណោះស្រាយអ្វីក្រៅពីការកាត់បន្ថយចំនួនមន្ត្រីបច្ចេកទេសដែលត្រូវចុះត្រួតពិនិត្យកំពង់ផែដែលស្នើសុំឡើយ។

បច្ចុប្បន្ន នាយកដ្ឋានមិនមានសម្ភារៈបច្ចេកទេសគ្រប់គ្រាន់ ជាពិសេសកុំព្យូទ័រសម្រាប់ឱ្យបុគ្គលិកមន្ត្រីរាជការនៅក្រោមចំណុះ ប្រើប្រាស់នៅក្នុងការងាររបស់ខ្លួន។ ក្នុងករណីនេះ យើងសង្កេតឃើញថា មានការិយាល័យមួយចំនួនមានកុំព្យូរតែ១គ្រឿងប៉ុណ្ណោះ សម្រាប់មន្ត្រី-បុគ្គលិករបស់ខ្លួនប្រើប្រាស់។ ក្នុងការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ ក៏ដូចជាលិខិតអនុញ្ញាតផ្សេងៗទៀត នាយកដ្ឋានមិនទាន់មានម៉ាស៊ីនបោះពុម្ពប្រភេទក្រដាសលិខិតទាំងនោះនៅឡើយទេ។ ពោលគឺ ត្រូវទៅប្រើប្រាស់សេវាបោះពុម្ពពីក្រុមហ៊ុនឯកជនខាងក្រៅ ដែលធ្វើឱ្យមានការខាតបង់ថវិកា និងងាយបង្កឱ្យមានបញ្ហាកើតឡើងដូចជាការបែកធ្លាយព័ត៌មានសំងាត់របស់ក្រុមហ៊ុនផែជាដើម។

**៣.១.១.៣. ដំណោះស្រាយ**

ដើម្បីធ្វើការដោះស្រាយនូវបញ្ហាប្រឈមដែលបានជួបប្រទះខាងលើ នាយកដ្ឋានបានខិតខំព្យាយាមស្វែងរកដំណោះស្រាយផ្សេងៗទៅតាមលទ្ធភាពដែលខ្លួនអាចធ្វើទៅបាន។ ដំណោះស្រាយទាំងនោះរួមមាន៖ ស្នើឱ្យមន្ត្រីរួមចំណែកបរិច្ចាកមួយចំណែកតូចនៃថវិកាប្រចាំខែរបស់ខ្លួន សម្រាប់ផ្គត់ផ្គង់តម្រូវការចាំបាច់របស់នាយកដ្ឋាន។ ដើម្បីឆ្លើយតបនឹងភាពខ្វះខាតសម្ភារៈប្រើប្រាស់ នាយកដ្ឋាន ក៏បានធ្វើការផ្លាស់ប្តូរវិធីសាស្ត្របំពេញការងារដោយផ្តោតលើលទ្ធផល(Result Base) ហើយវិធីសាស្ត្រនេះក៏បានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគកូវីដ-១៩ នៅដើមឆ្នាំ២០២០ នេះផងដែរ។

ស្របគ្នានោះផងដែរ នាយកដ្ឋានក៏តែងស្នើសុំមន្ត្រីក្របខណ្ឌបន្ថែមទៀត មកបម្រើការក្នុងនាយកដ្ឋានដើម្បីឱ្យការបំពេញការងារកាន់តែមានប្រសិទ្ធភាព និងភាពឆ្លើយតប។ ចំពោះការបង្កើនសមត្ថភាពរបស់មន្ត្រីនាយកដ្ឋាន តែងចាត់មន្ត្រី និងបុគ្គលិករបស់ខ្លួនឱ្យចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជំនាញជាញឹកញាប់ សម្រាប់អភិវឌ្ឍ និងពង្រឹងសមត្ថភាពរបស់ពួកគេ ឱ្យកាន់តែខ្លាំងពូកែថែមទៀត។ លើសពីនេះទៅទៀតថ្នាក់ដឹកនាំរបស់នាយកដ្ឋានតែងធ្វើការលើកទឹកចិត្ត និងផ្តល់ឱកាស ដល់មន្ត្រីដែលខិតខំបំពេញការងារ ដោយមើលលើភាពសកម្ម និងសមិទ្ធិផលដែលគេបានបំពេញ។

**៣.១.២. ទិសដៅការងារដើម្បីអនុវត្តបន្ទាប់**

ដើម្បីផ្តល់ភាពងាយស្រួលដល់ការបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត នាយកដ្ឋានតែងបានរៀបចំផែនការសកម្មភាពរបស់ខ្លួនយ៉ាងទៀងទាត់។ ក្នុងនោះ នាយកដ្ឋានរដ្ឋបាលកំពង់ផែ បានដាក់ចេញនូវទិសដៅការងារយ៉ាងច្រើនជាបន្តបន្ទាប់ទៀត រួមមាន៖ ការបន្តជម្រុញណែនាំកំពង់ផែឯកជនឱ្យត្រូវមានលិខិត

អនុញ្ញាតប្រតិបត្តិការកំពង់ផែ និងបន្តធ្វើបច្ចុប្បន្នភាពកំពង់ផែ តាមរយៈការប្រមូលចងក្រងស្ថិតិកំពង់ផែ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នាយកដ្ឋាន បានគ្រោងចុះផ្សព្វផ្សាយប្រកាសលេខ៤៣២ ប្រក.សក.ដជទ ស្តីពីសន្តិសុខឋបនីយភណ្ឌផែ នៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រតិបត្តិករផែ ដើម្បីឱ្យពួកគាត់ចូលរួមជាមួយនឹងនាយកដ្ឋាន ក្នុងកិច្ចអភិវឌ្ឍកំពង់ផែនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។ បន្ថែមនោះ នាយកដ្ឋានក៏នឹងចុះបណ្តុះបណ្តាលដល់នាយសន្តិសុខ និងបុគ្គលិកសន្តិសុខផែ អំពីតួនាទីភារកិច្ច របស់ពួកគាត់ក្នុងការរក្សាសន្តិសុខ និងសុវត្ថិភាពនៅក្នុងតំបន់កំពង់ផែរបស់ខ្លួន ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាលដល់ប្រតិបត្តិករកំពង់ផែ ស្តីពីសន្តិសុខឋបនីយភណ្ឌផែ នៅតាមកំពង់ផែឯកជនឱ្យកាន់តែប្រសើរឡើង។ នាយកដ្ឋាន នឹងបន្តបណ្តុះបណ្តាលមន្ត្រីផ្ទៃក្នុងបន្ថែមទៀត ដើម្បីឱ្យមានសមត្ថភាពឆ្លើយតបនឹងការរីកចម្រើន និងតម្រូវការចាំបាច់ជាក់ស្តែង ព្រមទាំងបន្តសហការជាមួយដៃគូរអភិវឌ្ឍន៍ ដើម្បីរៀបចំផែនការមេស្តីពីកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ត្រៀមខ្លួនក្នុងការប្រកួតប្រជែងជាមួយប្រទេសដទៃ។

## ៣.២. ការវិភាគទៅលើការអនុវត្តការងាររបស់នាយកដ្ឋាន និងការផ្តល់លិខិត

ដើម្បីធ្វើការបកស្រាយទៅលើរបបគំហើយរបស់ពួកយើងទាំងពីរឱ្យរិតតែលម្អិត និងក្បោះក្បាយបន្ថែមទៀតនោះ យើងខ្ញុំបានជ្រើសរើសយកការវិភាគបែប SWOT ដើម្បីមកធ្វើការបកស្រាយ។ ក្នុងនោះការសិក្សាទៅលើ ភាពខ្លាំងរបស់នាយកដ្ឋានក្នុងការអនុវត្តការងារ(៣.២.២.១) ភាពខ្សោយរបស់នាយកដ្ឋានក្នុងការអនុវត្តការងារ(៣.២.២.២) ភាពគំរាមកំហែង(៣.២.២.៣) និងកាលានុវត្តភាព(៣.២.២.៤) នឹងលើកយកមកបកស្រាយនៅក្នុងចំណុចនេះ។

### ៣.២.១ តារាងនៃការវិភាគ SWOT

| ភាពខ្លាំង | ភាពខ្សោយ |
|---|---|
| - សមត្ថភាពខ្ពស់របស់ថ្នាក់ដឹកនាំ<br>- ការគ្រប់គ្រងតាមបែបនវានុវត្តន៍<br>- ការចូលរួមពិគ្រោះយោបល់<br>- ការអភិវឌ្ឍសមត្ថភាព និងឥរិយាបទមន្ត្រី | - ពុំមានផែនការមេសម្រាប់គ្រប់គ្រងកំពង់ផែ<br>- ពុំទាន់មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់សម្រាប់គ្រប់គ្រងវិស័យផែ |
| **ភាពគំរាមកំហែង** | **កាលានុវត្តភាព** |
| - ការនិយមប្រើប្រាស់ការធ្វើដំណើរតាមផ្លូវគោក<br>- កង្វះការសហការជាមួយក្រុមហ៊ុនមួយចំនួន<br>- ភាពមិនអាចធ្វើប្រតិភូកម្មហត្ថលេខាលើការចេញលិខិតបាន | - ភាពរីកចម្រើននៃប្រព័ន្ធគ្រប់គ្រងកំពង់ផែ<br>- ការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល<br>- កំណើនសកម្មភាពពាណិជ្ជកម្មលក្ខណៈអន្តរជាតិ |

### ៣.២.២ ការបកស្រាយលើលទ្ធផលនៃការវិភាគ

នៅក្នុងផ្នែកនេះ យើងនឹងបន្តធ្វើការបកស្រាយលម្អិតជាបន្តទៀត ទៅលើការវិភាគអង្គភាពតាមបែប SWOT ដើម្បីមើលឱ្យឃើញច្បាស់បន្ថែមលើចំណុចនីមួយៗនៃ ភាពខ្លាំងរបស់នាយកដ្ឋានក្នុងការអនុវត្តការងារ (៣.២.២.១.) ភាពខ្សោយរបស់នាយកដ្ឋានក្នុងការអនុវត្តការងារ(៣.២.២.២.) ភាពគំរាមកំហែងមកលើការអនុវត្តការងាររបស់នាយកដ្ឋាន(៣.២.២.៣.) និងកាលានុវត្តភាពនានា ពាក់ព័ន្ធនឹងការផ្ដល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ(៣.២.២.៤.) ហើយដែលនឹងត្រូវបកស្រាយតាមផ្នែកនីមួយៗដូចខាងក្រោម៖

#### ៣.២.២.១. ភាពខ្លាំងរបស់នាយកដ្ឋានក្នុងការអនុវត្តការងារ

ក្នុងការអនុវត្តការងារ នាយកដ្ឋានមានចំណុចខ្លាំងជាច្រើន ដែលបង្កើតឱ្យបានជាផលវិជ្ជមានសម្រាប់ដំណើរវឌ្ឍនភាពការងាររបស់ខ្លួន។ ចំណុចខ្លាំងទាំងនោះរួមមាន៖

**ក. សមត្ថភាពរបស់ថ្នាក់ដឹកនាំ**

ថ្នាក់ដឹកនាំ ជាបុគ្គលមានចំណេះដឹង និងបទពិសោធន៍ខ្ពស់ ហើយធ្វើការដឹកនាំប្រកបដោយភាពហ្មត់ចត់ មានគុណធម៌ និងធ្វើការគ្រប់គ្រងអង្គភាពដោយភាពបត់បែន ទោះបីជាមានបញ្ហាប្រឈមមួយចំនួនកំពុងតែជួបប្រទះក៏ដោយ។  លើសពីនេះទៅទៀត ថ្នាក់ដឹកនាំនាយកដ្ឋាន បានរៀបចំប្រគល់ការទទួលខុសត្រូវដោយបែងចែកតួនាទី និងភារកិច្ចច្បាស់លាស់លើការកាន់កាប់សំណុំឯកសារ និងបែបបទនីតិវិធីនៃការស្នើសុំតាមដំណាក់កាលនីមួយៗដល់មន្ត្រីរាជការស្ថិតនៅក្រោមឱវាទ បាននាំឱ្យមានប្រសិទ្ធភាពការងារកាន់តែខ្ពស់។

**ខ. ការគ្រប់គ្រងតាមបែបនវានុវត្តន៍**

ការគ្រប់គ្រងនៅនាយកដ្ឋានរដ្ឋបាលកំពង់ផែ នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ គឺមានប្រសិទ្ធភាពខ្ពស់ បើធៀបទៅនឹងស្ថាប័នមួយចំនួនផ្សេងទៀតនៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងការគ្រប់គ្រងនេះ យើងបានបែងចែកជាពីរធំៗ គឺការគ្រប់គ្រងមន្ត្រី និងការគ្រប់គ្រងឯកសារ។ ជាក់ស្ដែង ក្នុងការគ្រប់គ្រងបុគ្គលិក នាយកដ្ឋានរដ្ឋបាលកំពង់ផែ តាមរយៈកំណែទម្រង់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន បានផ្លាស់ប្ដូរការគ្រប់គ្រងវត្តមានមន្ត្រីរបស់ខ្លួនតាមបែបបច្ចេកវិទ្យា ស្កេនម្រាមដៃ ដែលនាំឱ្យមន្ត្រីទាំងអស់គោរពពេលវេលាបានល្អ។ ចំណែកឯកសារវិញ នាយកដ្ឋានបានរៀបចំគ្រប់គ្រងនៅក្នុងប្រព័ន្ធកុំព្យូទ័រ បន្ថែមលើការរក្សាទុកនៅក្នុងក្រូណូយ៉ាងមានសណ្ដាប់ធ្នាប់ ដែលផ្ដល់នូវសុវត្ថិភាព និងភាពងាយស្រួលក្នុងការស្វែងរកឯកសារ។

**គ. ការចូលរួមពិគ្រោះយោបល់**

រាល់កិច្ចប្រជុំនានា មន្ត្រី-បុគ្គលិកនៅតាមការិយាល័យនីមួយៗនៃនាយកដ្ឋានរដ្ឋបាលកំពង់ផែ ត្រូវបានលើកទឹកចិត្តសម្រាប់ការចូលរួមបញ្ចេញមតិ និងលើកឡើងនូវបញ្ហាប្រឈមផ្សេងៗ ដើម្បីធ្វើការពិភាក្សារកដំណោះស្រាយ និងជាធាតុចូលថ្មីៗ សម្រាប់ជាមូលដ្ឋានក្នុងការពិចារណាយកទៅអភិវឌ្ឍប្រសិទ្ធភាពការងារ

របស់នាយកដ្ឋានឱ្យកាន់តែរីកចម្រើន។ ការធ្វើបែបនេះ បានជម្រុញឱ្យមន្ត្រីទាំងអស់មានការសហការគ្នាបានល្អ ក្នុងការបំពេញការងារ។

**ឃ. ការអភិវឌ្ឍសមត្ថភាព និងឥរិយាបថមន្ត្រី**

ក្រោមការគ្រប់គ្រង និងការរៀបចំរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ គ្រប់មន្ត្រីទាំងអស់ ទាំងមន្ត្រីជំនាញបច្ចេកទេស និងមន្ត្រីរដ្ឋបាលតែងទទួលបានការអប់រំបណ្តុះបណ្តាលសមត្ថភាពរបស់ខ្លួនបន្ថែម តាមរយៈទទួលបានអាហាររូបករណ៍ទៅសិក្សានៅក្រៅប្រទេស និងវគ្គសិក្សាបណ្តុះបណ្តាលបែបខ្លីមួយចំនួនទៀត។ ព្រមជាមួយគ្នានោះ មន្ត្រីដែលមានសមត្ថភាព ក៏នឹងទទួលបាននូវការឡើងតំណែងជាបន្តបន្ទាប់ផងដែរ។ យោងតាមលោក **ស៊ូ ផល្លី** ប្រធាននាយកដ្ឋានរដ្ឋបាលកំពង់ផែ បានមានប្រសាសន៍ថា "មន្ត្រីរបស់នាយកដ្ឋានតែងត្រូវបានណែនាំឱ្យប្រកាន់ខ្ជាប់នូវការចែករំលែក និងទទួលយកនូវបទពិសោធន៍ពីគ្នាទៅវិញទៅមកដើម្បីបង្កើនសមត្ថភាពរបស់ខ្លួន ស្របតាមទ្រឹស្តីអ្នកចេះច្រើនបង្រៀនអ្នកចេះតិច"។ គួបផ្សំនឹងការគ្រប់គ្រងអង្គភាពប្រកបដោយនវានុវត្តន៍ បានធ្វើអោយមន្ត្រី-បុគ្គលិកគ្រប់រូប គោរពវិន័យ និងមានក្រមសីលធម៌ល្អ។ បន្ថែមពីលើនេះទៀត មន្ត្រី-បុគ្គលិកគ្រប់រូបនៅក្នុងនាយកដ្ឋាន មានភាពខិតខំប្រឹងប្រែងបំពេញការងារ ចេះជួយ និងចេះចែករំលែកនូវចំណេះដឹង បទពិសោធន៍ឱ្យគ្នាទៅវិញទៅមក និងការបំពេញការងារប្រកបដោយឆន្ទៈ មនសិការ និងវិជ្ជាជីវៈខ្ពស់។

**៣.២.២.២. ភាពខ្សោយរបស់នាយកដ្ឋានក្នុងការអនុវត្តការងារ**

យើងសង្កេតឃើញថា ក្នុងការអនុវត្តការងាររបស់នាយកដ្ឋាននៅមានភាពទន់ខ្សោយមួយចំនួន ដែលបង្កជាផលអវិជ្ជមាន សម្រាប់ដំណើរវឌ្ឍនភាពការងាររបស់ខ្លួនផងដែរ។ ចំណុចខ្សោយទាំងនោះរួមមាន៖

**ក. ពុំទាន់មានផែនការមេសម្រាប់គ្រប់គ្រងកំពង់ផែ**

ផែនការមេកំពង់ផែ(Port Master Plan) ជាបទដ្ឋានគោលសំខាន់ដើម្បីកំណត់ពីតំបន់ដែលអាចសាងសង់កំពង់ផែបាន។ បច្ចុប្បន្ន យើងសង្កេតឃើញថាកម្ពុជា ពុំទាន់បានកសាងនូវផែនការមេនេះឱ្យបានចេញជារូបរាងនៅឡើយទេ ជាហេតុធ្វើឱ្យការសាងសង់កំពង់ផែ និងចំណតផែនានានៅតាមដងផ្លូវទឹកសាប និងសមុទ្រនៅកម្ពុជា គឺពុំទាន់មានរបៀបរៀបរយនៅឡើយ។

**ខ. ពុំទាន់មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់សម្រាប់គ្រប់គ្រងវិស័យផែ**

កម្ពុជាពុំទាន់មានច្បាប់មកធ្វើការគ្រប់គ្រងវិស័យកំពង់ផែនៅឡើយទេ ហើយលិខិតបទដ្ឋានសំខាន់ៗពាក់ព័ន្ធនឹងការផ្តល់សេវារបស់នាយកដ្ឋាន ជាពិសេសប្រកាសស្តីពីផែនការកម្មកំពង់ផែ ប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ និងជួសជុលបបនីយកណ្ឌផែ និងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតក្នុង ការធ្វើប្រតិបត្តិការបបនីយកណ្ឌផែ គឺនៅត្រឹមតែជាសេចក្តីព្រាងនៅឡើយ។ រហូតមកទល់នឹងពេលបច្ចុប្បន្ន នាយកដ្ឋានរដ្ឋបាលកំពង់ផែ អនុវត្តការងាររបស់ខ្លួនក្នុងការគ្រប់គ្រងរាល់ផែទាំងអស់ ដោយផ្អែកតាម

សារាចរលេខ០៧០ សរណន.សក ដែលនេះគឺមិនទាន់មានទម្ងន់គ្រប់គ្រាន់នៅឡើយសម្រាប់ចាប់បង្ខំអោយវិស័យឯកជន ក៏ដូចជាកំពង់ផែដែលមិនមានលិខិតអនុញ្ញាតប្រតិបត្តិការផែ ត្រូវតែមកស្នើសុំតាមនីតិវិធីនោះទេ។

**៣.២.២.៣. ភាពគំរាមកំហែង**

**ក. ការនិយមប្រើប្រាស់ការធ្វើដំណើរតាមផ្លូវគោក**

ការផ្លាស់ប្តូររបបនយោបាយញឹកញាប់នៅកម្ពុជា បានធ្វើឱ្យការអភិវឌ្ឍវិស័យដឹកជញ្ជូនផ្លូវទឹកមានភាពអន់ថយជាខ្លាំង។ បច្ចុប្បន្ន សេដ្ឋកិច្ចកម្ពុជា បាននឹងកំពុងមានការបោះពួយទៅមុខយ៉ាងលឿន ដែលជម្រុញឱ្យរាជរដ្ឋាភិបាលចាប់ផ្តើមសារជាថ្មីម្តងទៀតក្នុងការអភិវឌ្ឍវិស័យនេះឡើងវិញ។ ប៉ុន្តែ ដោយសារវិស័យដឹកជញ្ជូនតាមផ្លូវទឹកទើបតែមានការរីកចម្រើន រួមផ្សំជាមួយនឹងការដែលប្រជាជនមិនទាន់យល់ដឹងពីផលប្រយោជន៍របស់វាឱ្យបានទូលំទូលាយ បានធ្វើឱ្យពួកគាត់ភាគច្រើននៅតែបន្តប្រើប្រាស់ការធ្វើដំណើរតាមរយៈផ្លូវថ្នល់ដដែល។

**ខ. កង្វះការសហការជាមួយម្ចាស់ក្រុមហ៊ុនមួយចំនួន**

ក្នុងការអនុវត្តការងារកន្លងមក ការខ្វះខាតនូវឯកសារភ្ជាប់ដែលជាការតម្រូវចាំបាច់ និងភាពយឺតយ៉ាវនៃការមកបង់ប្រាក់កម្រៃសេវាសាធារណៈពីសំណាក់ភាគីក្រុមហ៊ុនគឺជាបញ្ហាចម្បង ដែលបានធ្វើឱ្យរាំងស្ទះដល់ការបន្តនីតិវិធីដើម្បីផ្តល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ។ យើងសង្កេតឃើញថា មានក្រុមហ៊ុនផែមួយចំនួនមិនបានមិនទាន់បានបំពេញឯកសារបានគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវឱ្យបានរួចរាល់នោះទេ មុននឹងដាក់ពាក្យស្នើសុំសេវាធ្វើប្រតិបត្តិការកំពង់ផែ។ ការនេះ បានធ្វើឱ្យដំណើរការចេញលិខិតកាន់តែមានភាពយឺតយ៉ាវមិនគោរពតាមរយៈពេលកំណត់នោះឡើយ។

**គ. ភាពមិនអាចធ្វើប្រតិភូកម្មហត្ថលេខាលើការចេញលិខិតបាន**

ការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ ត្រូវតែទទួលបានការចុះហត្ថលេខាដោយផ្ទាល់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។ ការកំណត់បែបនេះ អាចនឹងក្លាយជាបញ្ហាមួយនៅពេលដែលរដ្ឋមន្ត្រីមានភារកិច្ចច្រើន ឬមានធុរៈត្រូវបំពេញបេសកកម្មនៅក្រៅប្រទេសយូរថ្ងៃ ដែលជាហេតុនាំឱ្យការចេញសេវាប្រតិបត្តិការកំពង់ផែ មិនទាន់តាមពេលវេលាដូចដែលបានកំណត់។

**៣.២.២.៤. កាលានុវត្តភាព**

ក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ យើងសង្កេតឃើញថា ការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែជូនដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំ គឺបាននឹងកំពុងមានការកើនឡើងជាលំដាប់។ ការកើនឡើងនេះ គឺអាស្រ័យដោយកត្តាកាលានុវត្តភាពមួយចំនួនដូចខាងក្រោមៈ

**ក. ភាពរីកចម្រើននៃប្រព័ន្ធគ្រប់គ្រងកំពង់ផែ**

បច្ចុប្បន្នក្រសួងសារធារណការនិងដឹកជញ្ជូន បាននឹងកំពុងសហការជាមួយទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) ក្នុងការបង្កើតនូវប្រព័ន្ធ Port EDI System ដែលមានតួនាទីក្នុងការជួយសម្រួលដល់

ម្ចាស់កំពង់ផែ និងស្ថាប័នរដ្ឋដែលទទួលបន្ទុកគ្រប់គ្រងទិន្នន័យផ្សេងៗរបស់កំពង់ផែ ក៏ដូចជាផ្តល់នូវភាពងាយស្រួលក្នុងការចេញលិខិតអនុញ្ញាតចេញ-ចូលនាវានៅកម្ពុជា។ ប្រព័ន្ធនេះ បានជួយចូលរួមកាត់បន្ថយនូវការចំណាយផ្សេងៗ និងចំណេញពេលវេលា ព្រមទាំងធានានូវសុវត្ថិភាពទំនិញ និងអ្នកដំណើរផងដែរ។ ការនេះ បានធ្វើឱ្យក្រុមហ៊ុនកាន់តែមានការចាប់អារម្មណ៍ច្រើនឡើង ក្នុងការចូលរួមប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនផ្លូវទឹក សម្រាប់សម្រួលដល់ការប្រកបអាជីវកម្មរបស់ខ្លួន។

**ខ. ការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល**

ជាមួយនឹងគោលនយោបាយបើកចំហរជើងមេឃ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងជម្រុញលើកទឹកចិត្តឱ្យក្រុមហ៊ុន-សហគ្រាសខ្នាតធំនានា មានកំពង់ផែផ្ទាល់ខ្លួនដើម្បីសម្រួលដល់ការដឹកជញ្ជូនកាន់តែមានភាពងាយស្រួល ព្រមទាំងមានសក្តានុពលឆ្លើយតបជាមួយក្រុមហ៊ុនដៃគូប្រកួតប្រជែងផ្សេងទៀត។ ជាងនេះផងដែរ តាមរយៈការរំសាយភ្នាក់ងារនាវាចរណ៍កម្ពុជា ហៅកាត់ថា"**កាំសាប**" នាពេលថ្មីៗនេះ បានបើកឱកាសឱ្យក្រុមហ៊ុនទទួលបានផលចំណូលកាន់តែច្រើន ដោយសារនាវាកាន់តែមានភាពងាយស្រួលក្នុងការចូលចតក្នុងកំពង់ផែ ហើយក៏បានជម្រុញឱ្យមានកំណើនកំពង់ផែរបស់ក្រុមហ៊ុនផលិតកម្មក្នុងស្រុកផងដែរ។

**គ. កំណើនសកម្មភាពពាណិជ្ជកម្មលក្ខណៈអន្តរជាតិ**

នៅក្នុងរយៈពេលថ្មីៗនេះ សកម្មភាពបញ្ជាទិញផលិតផលពីក្រៅស្រុក សម្រាប់ការបំពេញតម្រូវការទីផ្សារកម្ពុជា គឺកំពុងតែមានការកើនឡើងគួរអោយកត់សម្គាល់។ ជាក់ស្តែង ការបញ្ជាទិញទំនិញមួយចំនួនពីប្រទេសចិនតាមរយៈគេហទំព័រអាជីវកម្មអេឡិចត្រូនិច(Online Shopping) ដូចជា៖ Tao Bao, Alibaba, Amazon, LODA ជាដើម។ ក្រុមហ៊ុនទាំងនោះ តែងធ្វើការដឹកជញ្ជូនទំនិញមកកាន់កម្ពុជាតាមរយៈច្រកផ្លូវសំខាន់ៗដូចជា ផ្លូវទឹក៧០% ផ្លូវគោក២៧% និងផ្លូវអាកាស៣%។[៣៩] មួយវិញទៀត ដោយសារការកើនឡើងទំហំពាណិជ្ជកម្មអន្តរជាតិ និងផលអនុគ្រោះពន្ធនាំចូលទៅកាន់ទីផ្សារក្នុងស្រុករបស់ប្រទេសធំៗមួយចំនួន សម្រាប់កកម្ពុជា បានផ្តល់ឱកាសកាន់តែច្រើនដល់ក្រុមហ៊ុន-សហគ្រាស ដែលមានសក្តានុពលក្នុងការផលិត។

## ៣.៣. សកម្មភាពចូលរួមអនុវត្តការងារជាក់ស្តែងនៅនាយកដ្ឋានរដ្ឋបាលកំពង់ផែ

ដោយមានការជួយជ្រោមជ្រែង និងតម្រង់ទិសដៅពី **លោកប្រធាននាយកដ្ឋាន** និង **លោក-លោកស្រីអនុប្រធាននាយកដ្ឋាន** ព្រមទាំងមានការណែនាំពីលោកប្រធានការិយាល័យនីមួយៗ យើងខ្ញុំបានសិក្សា និងឈ្វេងយល់បានយ៉ាងច្រើនអំពីតួនាទី ភារកិច្ចរបស់នាយកដ្ឋាន និងការងារការិយាល័យជាច្រើនទៀត។ ក្នុងរយៈពេលមួយខែកន្លះ នៃការចុះកម្មសិក្សានៅនាយកដ្ឋានកំពង់ផែ យើងខ្ញុំត្រូវបានតម្រូវឱ្យជួយ បំពេញការងារនៅតាមការិយាល័យនានារបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ ដើម្បីយល់ដឹងពីបែបបទការងារ និងដកស្រង់បទពិសោធន៍

[៣៩] លោក ស៊ូ ផល្លី ប្រធាននាយកដ្ឋានរដ្ឋបាលកំពង់ផែ. ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០.

ពីការបំពេញការងារទាំងនោះផងដែរ។ តាមរយៈការចូលរួមអនុវត្តការងារជាមួយនឹងមន្ត្រី បុគ្គលិករបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ ធ្វើឱ្យយើងខ្ញុំទទួលបានលទ្ធផលដូចខាងក្រោម៖

### ៣.៣.១. ការងាររៀប

ក្នុងរយៈពេលនៃការចុះកម្មសិក្សានេះ យើងខ្ញុំទាំងពីរបានចូលរួមក្នុងសកម្មភាពដូចខាងក្រោម៖

- ចុះលេខលើលិខិតចូល និងលិខិតចេញ ដើម្បីរក្សាទុកឯកសារជាកាលប្បវត្តិ
- ធ្វើការងារថតចម្លង និងស្កេនរាល់ឯកសារចេញ-ចូល (ទាំងទម្រង់ជាSOFT និងHARD)
- បានចូលរួមជាជំនួយដល់មន្ត្រីបច្ចេកទេសរបស់នាយកដ្ឋានក្នុងការធ្វើកំណត់បង្ហាញរឿង ដើម្បីលើកយោបល់ពីបញ្ហាជាក់លាក់ណាមួយ សម្រាប់ជាជំនួយស្មារតីដល់ថ្នាក់ដឹកនាំក្នុងការសម្រេច
- តាក់តែងលិខិតរដ្ឋបាលមួយចំនួនដូចជា៖ លិខិតបញ្ជាបេសកកម្ម លិខិតផ្ទេរសិទ្ធិ លិខិតឆ្លើយតប និងលិខិតអញ្ជើញ
- រៀបចំឯកសារ ស្តីពីការធ្វើផែនការក្របខណ្ឌប្រចាំឆ្នាំ២០២១ ដែលក្នុងនោះរួមមាន៖ លិខិតស្នើសុំមួយច្បាប់ដាក់ជូនទៅឯកឧត្តមអគ្គនាយក តារាងឧបសម្ព័ន្ធ ស្តីពីក្របខណ្ឌប្រចាំឆ្នាំ២០២០ និងគម្រោងផែនការក្របខណ្ឌប្រចាំឆ្នាំ២០២១ តារាងស្នើសុំជ្រើសរើសក្របខណ្ឌមន្ត្រីរាជការថ្មី ការប្រឡងប្រជែងដើម្បីប្តូរប្រភេទក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាប្រចាំឆ្នាំ២០២១ និងបញ្ជីឈ្មោះមន្ត្រីរាជការស្នើសុំប្រឡងប្រជែងដើម្បីប្តូរប្រភេទក្របខណ្ឌ។

### ៣.៣.២. ការងារប្រជុំ និងធ្វើរបាយការណ៍

ក្នុងកិច្ចការពិធីការ យើងខ្ញុំបានចូលរួមរៀបចំបន្ទប់ តុ ទឹក និង LCD Projector សម្រាប់កិច្ចប្រជុំនានារបស់នាយកដ្ឋាន ដូចជា៖

- កិច្ចប្រជុំរវាងថ្នាក់ដឹកនាំនាយកដ្ឋាន ជាមួយនឹងតំណាងក្រុមហ៊ុន
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាស ស្តីពីផែនកាកម្មកំពង់ផែ នៃព្រះរាជាណាចក្រកម្ពុជា
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ឋបនីយភណ្ឌផែ និងលិខិតអនុញ្ញាតជួសជុលឋបនីយភណ្ឌផែ
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការឋបនីយភណ្ឌផែ នៃព្រះរាជាណាចក្រកម្ពុជា រួមទាំងកិច្ចប្រជុំមួយចំនួនផ្សេងទៀត
- ធ្វើរបាយការណ៍ប្រជុំ និងរបាយការណ៍ប្រចាំខែរបស់នាយកដ្ឋាន
- រៀបចំបដិសណ្ឋារកិច្ចភ្ញៀវដែលមកទទួលសេវា។ល។

### ៣.៣.៣. ការងារផ្សេងៗ

នៅក្នុងការងារផ្សេងៗនេះ គឺសំដៅដល់កិច្ចការបន្ទាប់បន្សំដែលជាជំនួយដល់កិច្ចការរដ្ឋបាលរបស់អង្គភាព ដែលកិច្ចការទាំងនោះរួមមានដូចជា៖

- រៀបចំឯកសារដាក់ក្នុងក្រូណូ តាមប្រភេទឯកសារនីមួយៗ
- ត្រួតពិនិត្យមើលឯកសារ
- រៀបចំ កែសម្រួលទម្រង់ និងអក្ខរាវិរុទ្ធ នៃលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងការងារដឹកជញ្ជូនមួយចំនួនដូចជា ប្រកាសជាដើម
- បានចូលរួមប្រជុំស្តីពី ការផ្តល់សេវាសាធារណៈ ជាមួយសវនកម្មផ្ទៃក្នុង។

# សេចក្តីសន្និដ្ឋាន
# និង
# អនុសាសន៍

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ និងការអនុវត្តជាក់ស្ដែងនៅក្នុងនាយកដ្ឋានរដ្ឋបាលកំពង់ផែ ដើម្បីធ្វើការសិក្សាឈ្វេងយល់ប្រធានបទស្ដីពី **"ការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ"** រួចមក យើងខ្ញុំសង្កេតឃើញថា គ្រប់កំពង់ផែទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនអាចដំណើរការប្រតិបត្តិការអាជីវកម្មកំពងផែរបស់ខ្លួនដោយមិនមានលិខិតអនុញ្ញាតដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន បានឡើយ។ មានន័យថា ដើម្បីឱ្យបបនីយកណ្ឌផែដែលបានសាងសង់ ឬផ្នែកណាមួយដែលបានសាងសង់រួច ធានាបាននូវសុវត្ថិភាព សន្តិសុខ និងបរិស្ថាន មុនដាក់ឱ្យធ្វើប្រតិបត្តិការ បបនីយកណ្ឌផែទាំងអស់ត្រូវមានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការបបនីយកណ្ឌផែ ដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូនជាដាច់ខាត។ ករណីដែលពួកគាត់មិនបានមកធ្វើការស្នើសុំលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែរបស់ខ្លួន ឬដែលបានប្រតិបត្តិការដោយគ្មានលិខិតអនុញ្ញាត ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងពុំអនុញ្ញាតឱ្យមាននាវាចូលចតបានឡើយ។ ក្នុងករណីនេះដែរ កំពង់ផែដែលពុំទាន់មានលិខិតអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ ឬលិខិតអនុញ្ញាតប្រតិបត្តិការហួសសុពលភាព ក្រសួងនឹងចេញលិខិតមួយផ្ញើរទៅកាន់ក្រុមហ៊ុន ដើម្បីជម្រុញឱ្យក្រុមហ៊ុនផែទាំងនោះរូតរះមកស្នើសុំលិខិតអនុញ្ញាតឱ្យបានទាន់ពេលវេលា។ ម្យ៉ាងទៀត លិខិតអនុញ្ញាតធ្វើប្រតិបត្តិការបបនីយកណ្ឌផែនេះ គឺមានសុពលភាព ២(ពីរ)ឆ្នាំប៉ុណ្ណោះ ដូចនេះម្ចាស់អាជីវកម្ម ឬម្ចាស់នៃកំពង់ផែ ត្រូវមកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបន្តធ្វើប្រតិបត្តិការផែរបស់ខ្លួន រៀងរាល់ពីរឆ្នាំម្ដង។ ការកំណត់រយៈពេលពីរឆ្នាំនេះ គឺក្នុងន័យធ្វើបច្ចុប្បន្នភាពគុណភាពរបស់កំពង់ផែ និងចំណតផែទាំងឡាយ ដើម្បីឱ្យក្រសួងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងកំពង់ផែទាំងអស់ សម្រាប់ឱ្យនាវាអាចចូលចតនៅចំណតផែប្រកបដោយសុវត្ថិភាព។ ក្នុងរយៈពេលនៃការធ្វើប្រតិបត្តិការនេះ អង្គគ្រប់គ្រងកំពង់ផែ ត្រូវធ្វើរបាយការណ៍អំពីប្រតិបត្តិការបបនីយកណ្ឌផែ មកក្រសួងសាធារណការនិងដឹកជញ្ជូនជាប្រចាំ តាមកាលកំណត់។

ក្នុងការដាក់ឱ្យដំណើរការសេវាកម្មចេញលិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ ដោយនាយកដ្ឋានរដ្ឋបាលកំពង់ផែនេះ គឺមានគោលបំណង គ្រប់គ្រងរាល់ប្រតិបត្តិការកំពង់ផែទាំងអស់ឱ្យកាន់តែមានប្រសិទ្ធភាព ស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីធានាបានថា រាល់បបនីយកណ្ឌ ដែលបានសាងសង់ ឬផ្នែកណាមួយដែលបានសាងសង់រួច គឺរក្សាបាននូវគោលការណ៍សុវត្ថិភាព សន្តិសុខ និងបរិស្ថាន មុននឹងដាក់ឱ្យនាវាអាចចូល-ចេញ ចតបាន។ ការធ្វើបែបនេះ ក៏ជាការរួមចំណែកយ៉ាងសំខាន់ ក្នុងការអនុវត្តគោលនយោបាយជាតិស្ដីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ របស់ព្រះរាជាណាចក្រកម្ពុជា ក្នុងន័យធ្វើយ៉ាងណាឱ្យការគ្រប់គ្រង និងការអភិវឌ្ឍកំពង់ផែ ឆ្ពោះទៅរកវឌ្ឍនភាពប្រកបដោយនិរន្តរភាព សមធម៌ និងទំនើបកម្ម សំដៅចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងពាណិជ្ជកម្មអន្តរជាតិ។ លើសពីនេះទៀត ការចេញលិខិតនេះជូនដល់ប្រតិបត្តិករផែ គឺជាធាតុសត្យានុម័តក្នុងការ

ប្រែក្លាយវិស័យកំពង់ផែឱ្យទៅជាកម្លាំងចលករសម្រាប់អភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពនិងសមត្ថភាពរបស់កំពង់ផែ សំដៅកសាងកំពង់ផែឱ្យមានឧត្តមានុភាពប្រកួតប្រជែង អាចចូលរួមប្រជែងជាមួយនឹងកំពង់ផែនៅក្នុងតំបន់។ ឈរលើស្មារតីនេះ នាយកដ្ឋានរដ្ឋបាលកំពង់ផែ ក្នុងនាមជាសេនាធិការឱ្យក្រសួងសាធារណការនិងដឹកជញ្ជូន តែងខិតខំប្រឹងប្រែងក្នុងការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែជូនដល់ក្រុមហ៊ុន និងម្ចាស់កំពង់ផែនានា ដើម្បីធ្វើឱ្យប្រាកដថា កំពង់ផែទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានត្រួតពិនិត្យ និងធានានូវគុណភាពសុវត្ថិភាពសម្រាប់នាវាជាលក្ខណៈជាតិ ឬអន្តរជាតិ ក្នុងការចូល-ចេញចតប្រកបដោយទំនុកចិត្តខ្ពស់។

ដើម្បីធ្វើការស្នើសុំលិខិតប្រភេទនេះបាន ម្ចាស់ក្រុមហ៊ុនផែ ឬម្ចាស់ចំណតផែ ត្រូវរៀបចំឱ្យបានគ្រប់គ្រាន់រាល់សំណុំឯកសារតម្រូវ ដែលជាមូលដ្ឋានដ៏ចាំបាច់សម្រាប់ឱ្យថ្នាក់ដឹកនាំធ្វើការវិនិច្ឆ័យ។ ការស្នើសុំ ត្រូវឆ្លងកាត់ការត្រួតពិនិត្យយ៉ាងល្អិតល្អន់ជាទីបំផុតពីសំណាក់មន្ត្រីជំនាញ មុននឹងដាក់ឆ្លងសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ហើយម្ចាស់ក្រុមហ៊ុនផែ ឬម្ចាស់ចំណតផែ ត្រូវគោរពតាមលក្ខខណ្ឌនៃបទដ្ឋានបច្ចេកទេសក្នុងការសាងសង់ដូចមានចែងក្នុងសារាចរណែនាំលេខ០៧០ និងប្រកាសស្តីពីសន្តិសុខបរិស្ថានយកណ្ដាផែ។

# អនុសាសន៍

ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តការងារតែងជួបប្រទះនូវបញ្ហាប្រឈម និងកង្វះខាតមួយចំនួន ហើយនាយកដ្ឋានបាននឹងកំពុងខិតខំប្រឹងប្រែងក្នុងការដោះស្រាយជាបន្តបន្ទាប់។ ប៉ុន្តែ អ្វីដែលជាបញ្ហាធំចម្បងជាងគេនោះគឺ ភាពខ្វះខាតលើមធ្យោបាយ ធនធានមនុស្ស និងថវិកាសម្រាប់ទ្រទ្រង់ដល់ដំណើរការផែនការសកម្មភាពការងាររបស់ខ្លួន ដែលនាយកដ្ឋានពិតជាមានការលំបាកយ៉ាងខ្លាំងក្នុងការដោះស្រាយ។ មួយវិញទៀត បញ្ហាដែលនាយកដ្ឋានតែងតែជួបប្រទះ ហើយដែលនាំឱ្យការផ្តល់សេវាមិនអាចគោរពតាមពេលវេលាដែលកំណត់នោះគឺការមិនចូលរួមសហការល្អរបស់ម្ចាស់ផែមួយចំនួន ពិសេសការខ្វះខាតនូវឯកសារភ្ជាប់ដែលតម្រូវឱ្យយើងធ្វើការរង់ចាំការបំពេញភាពខ្វះខាតទាំងនោះជាមុនសិន។ ដើម្បីរួមចំណែកក្នុងការដោះស្រាយលើបញ្ហានានាដែលនាយកដ្ឋានកំពុងជួបប្រទះ យើងខ្ញុំទាំងពីរសូមដាក់ជូននូវសំណូមពរមួយចំនួនដូចខាងក្រោម៖

ចំពោះការដោះស្រាយលើបញ្ហាធនធានមនុស្ស គប្បីមានការរៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់នាយកដ្ឋានផ្ទាល់ ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងបុគ្គលិក និងមន្ត្រីរាជការដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន។ ម៉្យាងទៀត ចំពោះភាពខ្វះខាតផ្នែកធនធានមនុស្ស សូមឱ្យក្រសួងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយបន្ថែមទៀតដោយណែនាំពីនាយកដ្ឋានទៅកាន់សាធារណជន ពិសេសសិស្សនិស្សិតដែលកំពុងសិក្សាលើជំនាញបច្ចេកទេសតាមតម្រូវការជាក់ស្តែង ដូចជា៖ វិស្វករសំណង់ស៊ីវិល ស្ថាបត្យកម្ម ច្បាប់ និងរដ្ឋបាលជាដើម ហើយដែលមានបំណងចង់ចុះធ្វើកម្មសិក្សានៅក្រសួងសាធារណការនិងដឹកជញ្ជូន ឱ្យពួកគេមានចំណាប់អារម្មណ៍មកបម្រើការជានិស្សិតកម្មសិក្សា ក្នុងន័យជម្រុញការអភិវឌ្ឍចំណេះដឹងរបស់ពួកគេបន្ថែម និងកាត់បន្ថយបញ្ហាប្រឈមរបស់នាយកដ្ឋានដែលកំពុងជួបប្រទះភាពខ្វះខាតលើមន្ត្រីជំនាញ។

ចំណែកឯការបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាវិញ ក្រសួងសាធារណការនិងដឹកជញ្ជូន គប្បីធ្វើការកាត់បន្ថយនីតិវិធីក្នុងការដាក់លិខិតស្នើសុំរបស់ខ្លួន ដោយមកនៅត្រឹមការដាក់ដោយផ្ទាល់ទៅកាន់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ឬទៅកាន់នាយកដ្ឋានផ្ទាល់ ដើម្បីឱ្យពេលវេលានៃការរៀបចំនីតិវិធីផ្តល់លិខិតស្នើសុំកាន់តែមានពេលច្រើនគ្រប់គ្រាន់។ លើសពីនេះទៀត ក្រសួងគួរផ្លាស់ប្តូរនីតិវីធីស្នើសុំនេះតាមប្រព័ន្ធOnline វិញ ដោយតម្រូវឱ្យក្រុមហ៊ុនដែលបានស្នើសុំស្កេនឯកសារពាក់ព័ន្ធទាំងអស់ភ្ជាប់ជាមួយនឹងការបំពេញពាក្យស្នើសុំតាមប្រព័ន្ធអ៊ីនធឺណែត។ ក្រោយពិនិត្យឃើញថាត្រឹមត្រូវរួចហើយ ផ្នែកទទួលបន្ទុកលើការទទួលលិខិតស្នើសុំគ្រាន់តែកំណត់ថ្ងៃសម្រាប់តម្រូវឱ្យក្រុមហ៊ុនយកច្បាប់ដើមនៃឯកសារភ្ជាប់មកធ្វើការផ្ទៀងផ្ទាត់ និងកំណត់ថ្ងៃដើម្បីចុះពិនិត្យទីតាំងកំពង់ផែ ឬចំណតផែនៅពេលបន្ទាប់។ ការធ្វើបែបនេះ ធានាបានថាក្រុមហ៊ុនដែលបានស្នើសុំគឺមានឯកសារគ្រប់គ្រាន់ ដោយមិនចាំបាច់រង់ចាំក្រុមហ៊ុនបំពេញនូវឯកសារដែលខ្វះខាត និងមិនខាតពេលវេលាសម្រាប់ឱ្យនាយកដ្ឋានរៀបចំនីតិវិធីជាបន្តបន្ទាប់របស់ខ្លួន។ មួយវិញទៀត វាក៏នឹងអាចក្លាយជា

ដំណោះស្រាយមួយបែបសម្រាប់ជួយបង្កើនចំនួនការងារបន្ថែមសម្រាប់ឱ្យក្រុមការងារបច្ចេកទេស និងជួយកាត់បន្ថយការលំបាកចំពោះបញ្ហាដែលនាយកដ្ឋាន មិនទាន់មានម៉ាស៊ីនថតចម្លងឯកសារប្លង់កំពង់ផែដែលជាប្រភេទក្រដាសមានទំហំធំៗ ផងដែរ។

បន្ថែមពីលើនេះផងដែរ យើងខ្ញុំក៏សូមសំណូមពរដល់អង្គភាពពាក់ព័ន្ធ ជួយជម្រុញពន្លឿនដំណើរការនៃការរៀបចំច្បាប់ស្តីពីកំពង់ផែ និងលិខិតបទដ្ឋានពាក់ព័ន្ធនានាក្នុងវិស័យកំពង់ផែនេះ ឱ្យកាន់តែបានឆាប់រហ័សដើម្បីឱ្យនាយកដ្ឋានមានលទ្ធភាព និងសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការណែនាំឱ្យកំពង់ផែទាំងអស់ត្រូវគោរពតាម។

# គន្ថនិទេស

# គន្ថនិទេស

## ១. ឯកសារដែលមានលក្ខណៈជាច្បាប់ និងគោលនយោបាយ

- សេចក្តីព្រាងច្បាប់ស្តីពីកំពង់ផែ ឆ្នាំ២០២០.
- សេចក្តីព្រាងច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ឆ្នាំ២០២០.
- រាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន.

## ២.ឯកសារដែលមានលក្ខណៈជាលិខិតបទដ្ឋានគតិយុត្ត

- នាយកដ្ឋានរដ្ឋបាលកំពង់ផែ.(២០២០). សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការឋបនីយភណ្ឌផែ.
- ប្រកាសអន្តរក្រសួងលេខ១៤៦០ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងសាធារណការ និងដឹកជញ្ជូន.
- ប្រកាសលេខ ២៤៤ សក.ប្រក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានរដ្ឋបាលកំពង់ផែ.
- ប្រកាសលេខ ៤៣២ ប្រក.សក.ដជទ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីសន្តិសុខឋបនីយភណ្ឌផែ នៃព្រះរាជាណាចក្រកម្ពុជា.
- អនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន.
- រាជរដ្ឋាភិបាលកម្ពុជា.(២០១៣).គោលនយោបាយជាតិស្តីពីកំពង់ផែ.ភ្នំពេញ.
- សារាចរណែនាំលេខ ០៧០ សរណន.សក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពី ផែនការកម្ម ការសាងសង់ និងប្រតិបត្តិការកំពង់ផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា.
- អនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៦ ស្តីពីសន្តិសុខនាវា និងសន្តិសុខឋបនីយភណ្ឌផែ.

## ៣.ឯកសារដែលមានលក្ខណៈជារបាយការណ៍

- របាយការណ៍ស្តីពីលទ្ធផលការងាររបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ប្រចាំខែកុម្ភៈ ឆ្នាំ២០២០.
- នាយកដ្ឋានរដ្ឋបាលកំពង់ផែ.(២០២០). តារាងស្ថិតិកំពង់ផែ ចំណតផែនៅតាមផ្លូវទឹក និងឆ្នេរសមុទ្រក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២០.ភ្នំពេញ.
- នាយកដ្ឋានរដ្ឋបាលកំពង់ផែ.(២០២០). របាយការណ៍ស្តីពីការចុះធ្វើបច្ចុប្បន្នភាព ស្រង់ស្ថិតិ និងចុះផ្សព្វផ្សាយណែនាំដល់កំពង់ផែ ចំណតផែ ដែលពុំទាន់មានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា.ភ្នំពេញ.

- របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ.
- ក្រសួងសាធារណការនិងដឹកជញ្ជូន.(២០២០). របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និង ទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន.

**៤. ឯកសារផ្សេងៗ**

- សាស្ត្រាចារ្យ ឌៀក ពិដោរ.(២០២០). នីតិវិធីរដ្ឋបាល. ភ្នំពេញ.
- សាស្ត្រាចារ្យ បណ្ឌិត ឈុន ណារ៉េត.(២០១៩). គោលនយោបាយសាធារណៈ. ភ្នំពេញ.
- នាយកដ្ឋាននាវាជំនួញសមុទ្រ.(២០១៩).“The Waterways Infrastructure Development in Cambodia”. ភ្នំពេញ. បកប្រែដោយ តាន់ សម្បត្តិសុភ័កត្រា.
- សាស្ត្រាចារ្យ ហៀង សាង.(២០១៨). "នីតិរដ្ឋបាលសាធារណៈ". ភ្នំពេញ. បោះពុម្ពលើកទី១.
- បណ្ឌិត សាយ បូរី.(២០០៧). វិទ្យាសាស្ត្ររដ្ឋបាល. បណ្ណាគារអង្គរ, ភ្នំពេញ. បោះពុម្ពលើកទី១.
- សាស្ត្រាចារ្យ ឌៀក ពិដោរ.(n.a). នីតិរដ្ឋបាលទូទៅ. ភ្នំពេញ.បោះពុម្ពលើកទី២.
- សម្តេចសង្ឃរាជ ជួន ណាត.(១៩៦៧). វចនានុក្រមខ្មែរ ភាគទី១-២. ភ្នំពេញ. ពុទ្ធសាសនបណ្ឌិតកម្ពុជា.